**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ពិត ជននីនាថ**

**គង់វិរៈរតនៈ សម្បត្តិ**

សាស្ត្រាចារ្យណែនាំ

លោក **ខាត់ ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ពិត ជននីនាថ** និងខ្ញុំបាទឈ្មោះ **គង់វិរៈរតនៈ សម្បត្តិ** ជានិស្សិតនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលនឹងត្រូវបញ្ចប់ការសិក្សានៅក្នុងឆ្នាំ ២០២៣។

**សូមគោរពប្រណិប័តន៍ និងសេចក្តីកត្តញ្ញូតាធម៌ចំពោះលោកឳពុក និងអ្នកម្តាយ**

លោកឳពុក **ពិត សារដ្ឋ** និងអ្នកម្តាយ **ឡៅ គីមយ៉ាន**

លោកឳពុក **សាន ខុនធឿន** និងអ្នកម្តាយ **រស់ ឆាយ**

កូនសូមលំឱនកាយគោរពដោយកិច្ចប្រណិប័តន៍ និងកតញ្ញូធម៌ដ៏ឧត្តុង្គឧត្តម ចំពោះ លោកឳពុក អ្នកម្តាយ ដែលលោកទាំងពីរបានផ្តល់ជីវិត និងបានលះបង់នូវកាយពល ខិតខំចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងឧបត្ថម្ភគ្រប់បែបយ៉ាង ផ្តល់ជំនួយកម្លាំងចិត្ត និងការគាំទ្រទាំងផ្នែកស្មារតី ព្រមទាំង ពុះពាររាល់ឧបសគ្គ គ្រប់បែបយ៉ាងដោយមិនត្អូញត្អែរ មិនខ្លាចនឿយហត់ ដើម្បីឱ្យកូនបានសិក្សារៀនសូត្រចាប់តាំង ពីកុមារភាព និងបានបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលបច្ចុប្បន្ន។ កូនពិតជាមានមោទនភាព និងមានការស្ងើចសរសើរចំពោះការលះបង់ក៏ធំធេងក្រៃលែងនេះ ហើយ កូនសូមគោរពជូនពរ លោកទាំងពីរ ឱ្យជួបតែ តែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពដឹងគុណ**

**ជូនចំពោះ**

**សាស្ត្រាចារ្យគ្រប់មុខវិជ្ជា**

យើងខ្ញុំ សូមថ្លែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គ្រប់មុខវិជ្ជាទាំងអស់ ដែលលោកបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀននាងខ្ញុំ អស់ពីកម្លាំងកាយចិត្ត ដែលបានផ្ទេរចំណេះដឹង បទពិសោធន៍ និងទ្រឹស្តីផ្សេងៗជាច្រើនដែលជួយបង្កើនពុទ្ធិ សម្រាប់ធ្វើជាដើមទុនក្នុងការពិចារណា ថ្លឹងថ្លែងរហូតដល់នាងខ្ញុំមានឱកាសបានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

យើងខ្ញុំសូមធ្វើការគោរពដឹងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ និងថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ខាត់ ធី** យ៉ាងអនេកប្បការ ដែលជាលោកសាស្ត្រាចារ្យបានធ្វើការចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ទទួលណែនាំសរសេរសារណានេះដោយមិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ ពិភាក្សាពិនិត្យពិច័យ តម្រែតម្រង់ទិស ក្នុងការស្វែងរក និងផ្តល់ឯកសារ បន្ទុកមួយចំនួនអោយ ប្រធានបទមួយនេះ មានភាពផ្លូវការ

ស្របតាមស្តង់ដារត្រឹមត្រូវដែលបានកំណត់ក្នុងកាធ្វើកិច្ចការសារណានេះចាប់តាំងពីពេលចាប់ផ្តើម និងរហូតដល់ក្តីបញ្ចប់ស្តាពរ។

ជាចុងក្រោយនេះយើងខ្ញុំ សូមឡើងដៃគោរពបួងសួងដល់បារមីវត្ថុសក្តិសិទ្ធិទាំងពួងទាំងឡាយ សូមប្រសិទ្ធិពរជ័យ ជូនដល់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ទាំងអស់ឱ្យជួបតែសេចក្តីសុខ សុខភាពបវររុងរឿង ព្រមទាំងសូមអោយលោកជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សា អស់រយៈ ៤ ឆ្នាំ ចាប់តាំងពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងកំឡុងពេលនោះ មានផលលំបាកក្នុងការសិក្សាក៏ពិតមែន ដោយសារតែការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ១៩ ក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ប៉ុន្តែយើងខ្ញុំបានខិតខំសិក្សាយ៉ាងស្វាប៉ាប់។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាស់ស្ទង់សមត្ថភាពរបស់យើងខ្ញុំ យើងខ្ញុំបានចងក្រងបានជាសិមិទ្ធផលស្នាដៃស្រាវជ្រាវមួយ ក្នុងគោលបំណង បង្ហាញបរិបទមជ្ឈត្តការពាណិជ្ជកម្មនៅប្រទេសកម្ពុជា ដើម្បីចែករំលែកការយល់ដឹងប្រធានបទនេះឱ្យមានការយល់ដឹងកាន់តែទូលំទូលាយ ក្នុងសារណាដែលមានចំណងជើងថា **មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា** ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ។

ដើមចមនៃការសរសេរចងក្រងឡើងនូវស្នាដៃមួយនេះ គឺយើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងរឹងពឹង ថាកម្រងស្នាដៃនៃការស្រាវជ្រាវមួយនេះនឹងធ្វើជាប្រយោជន៍យ៉ាងសំខាន់ ក្នុងការរួមចំណែកផ្សព្វផ្សាយចែករំលែកចំណេះដឹងក្នុងវិស័យមជ្ឈត្តការក្នុងផ្នែកពាណិជ្ជកម្ម និងវិធាន នីតិវិធី និងបទបញ្ញានៃមជ្ឈមណ្ឌលមជ្ឈត្តការនៅកម្ពុជា ដើម្បីជូនជាពុទ្ធិនិងជាស្ពានចម្លងដឹកនាំសិស្សានុសិស្ស និងអ្នកអានអត្ថបទនេះទាំងអស់ បានជ្រាបយល់បន្ថែមទៀតអោយកាន់តែជ្រាលជ្រៅ។ តាមរយៈស្នាដៃរបស់យើងខ្ញុំ គឺមិនប្រាថ្នាអ្វីក្រៅពីការផ្តល់ចំណេះដឹងថ្មីគុណប្រយោជន៍ដ៏មានប្រសិទ្ធភាពមួយ និងជាថ្នាលសម្រាប់ប្រកបវិជ្ជាជីវៈក្នុងពេលអនាគតកាលព្រោះថា ជាការពិតដែលមិនអាចបដិសេធបាន គឺធនធានមនុស្ស ពិតជាមានសារៈសំខាន់លើគ្រប់វិស័យដើម្បីឱ្យមានវិឌ្ឍនភាពក្នុងប្រទេស និងពិសេសជាងនេះទៀតទៅនោះសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលនិស្សិត ផ្តល់ចំណេះវិជ្ជាសិក្សាមុខជំនាញសេដ្ឋកិច្ច និងនីតិសាស្ត្រ។

ជាទូទៅរាល់កម្រងឯកសារស្នាដៃទាំងប៉ុន្មាន រមែងតែងតែជៀសមិនផុតពីការមានកំហុសឆ្គងអក្ខរាវិរុទ្ធ និងខ្លឹមសារបញ្ញត្តិច្បាប់មិនមានគ្រប់គ្រាន់ ដោយសារតែអាចមកពីសមត្ថភាពយើងខ្ញុំនៅមានភាពខ្វះខាត ឬយល់មិនដល់នូវប្រការណាមួយ ហើយពេលវេលាក្នុងការធ្វើការស្រាវជ្រាវមានរយៈពេលខ្លី។ ដោយហេតុនេះហើយ រាល់មតិរិះគន់ និងកែប្រែចំណុចខ្វះខាតដែលកើតមានដោយចេតនាក្តី ដោយអចេតនាក្តីពីសំណាក់លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ លោកលោកស្រី និងមិត្តអ្នកអាន យើងខ្ញុំនឹងទទួលស្វាគមន៍ដោយសេចក្តីរីករាយយ៉ាងអនេក និងធ្វើការចាត់ទុកថាមតិទាំងអស់ជាការរិះគន់បែបស្ថាប័នតែប៉ុណ្ណោះ។

# មាតិកា

**សេចក្តីផ្តើម** ........ ១
១. លំនាំនៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា ........ ៣
៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣
៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**គោលការណ៍ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

**១.១. ការចរចា** ........ ៥
**១.២. នីតិវិធីក្នុងការចរចា** ........ ៥
១.២.១. ដំណើរការក្នុងការចរចា ........ ៧
១.២.៣. គុណសម្បត្តិនៃការចរចា ........ ៩
១.២.៤. គុណវិបត្តិនៃការចរចា ........ ១០
**១.៣. សន្ធានកម្ម** ........ ១១
១.៣.១. នីតិវិធី និងដំណើរការនៃសន្ធានកម្ម ........ ១២
១.៣.២. គុណសម្បត្តិនៃសន្ធានកម្ម ........ ១៣
១.៣.៣. គុណវិបត្តិនៃសន្ធានកម្ម ........ ១៤
**១.៤. ការផ្សះផ្សា** ........ ១៤
១.៤.១. នីតិវិធីនៃការផ្សះផ្សា ........ ១៥
១.៤.២. គុណសម្បត្តិនៃការផ្សះផ្សា ........ ១៥
១.៤.៣. គុណវិបត្តិនៃការផ្សះផ្សា ........ ១៥

## ជំពូកទី២
## ការចាប់ផ្តើមមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា


**២.១. សញ្ញាណទូទៅនៃមជ្ឈត្តការ** ........ ១៦
២.១.១. និយមន័យមជ្ឈត្តការ និងប្រវត្តិនៃមជ្ឈត្តការ ........ ១៦
២.១.២. ការបង្កើតមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា ........ ១៨
២.១.៣. គុណសម្បត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម ........ ១៩
២.១.៤. គុណវិបត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម ........ ២០
២.១.៥. លក្ខណៈទម្រង់នៃម.ជ.ម. ........ ២១
២.១.៥.១. ក្រុមប្រឹក្សាប្រតិបត្តិ ........ ២១
២.១.៥.២. គណៈកម្មាធិការ ........ ២១
២.១.៥.៣. អគ្គលេខាធិការដ្ឋាន ........ ២២
២.១.៥.៤. សមាជិកភាពរបស់ ម.ជ.ម. ........ ២២
**២.២. មជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា** ........ ២៣
២.២.១. គោលបំណងនៃការស្ថាបនាមជ្ឈត្តការនៅកម្ពុជា ........ ២៣
២.២.២. ចក្ខុវិស័យ និងបេសកម្មរបស់ម.ជ.ម. ........ ២៤
២.២.៣. មជ្ឈត្តករនៅម.ជ.ម. ........ ២៤
២.៣.២.១. ការដាក់បញ្ចូលមជ្ឈត្តករ ........ ២៥
២.៣.២.២. លក្ខន្តិកៈរបស់មជ្ឈត្តករ ........ ២៦
២.៣.២.៣. ការបញ្ចប់អាណត្តិរបស់មជ្ឈត្តករ ........ ២៧
២.៣.២.៤. ការជំទាស់ដោយដាក់មជ្ឈត្តករជំនួស ........ ២៨


## ជំពូកទី៣
## ការដោះស្រាយវិវាទមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា


**៣.១. នីតិវិធីដោះស្រាយវិវាទដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ........ ៣៣
៣.១.១. ការប្រើប្រាស់ភាសា ........ ៣៣
៣.១.២. ទីកន្លែងធ្វើមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........ ៣៣

៣.១.៣. ការកំណត់យកច្បាប់មកប្រើប្រាស់ ៣៤
៣.១.៤. ការកំណត់ពេលវេលាដំណើរការមជ្ឈត្តការ ៣៦
៣.១.៥. អានុភាពនៃខចែងមជ្ឈត្តកម្ម ៣៧
**៣.២. ដំណើរការមុនការចាប់ផ្តើមមជ្ឈត្តកម្ម** ៣៨
៣.២.១. ពាក្យបណ្តឹងរបស់ភាគី ៣៨
៣.២.២. ភាគីឆ្លើយតប ៣៩
៣.២.៣. ការកែប្រែពាក្យបណ្តឹងតប ៤០
៣.២.៤. ការដកពាក្យបណ្តឹង ៤០
**៣.៣. ដំណើរការមជ្ឈត្តការ** ៤០
៣.៣.១. ការដាក់ពាក្យស្នើសុំរបស់ភាគី ៤០
៣.៣.២. ដំណើរការត្រៀមមជ្ឈត្តការ ៤១
៣.៣.៣. ដំណើរការសវនាការ ៤១
**៣.៤. ការបញ្ចប់មជ្ឈត្តវិនិច្ឆ័យ** ៤២
៣.៤.១. សេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ ៤៣
៣.៤.២. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ ៤៣
៣.៤.៣. ការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ៤៤
៣.៤.៤. អានុភាពមជ្ឈត្តវិនិច្ឆ័យ ៤៥
**សេចក្តីសន្និដ្ឋាន** ៤៦
**អនុសាសន៍** ៤៨

# តារាងពាក្យកាត់

| | |
|---|---|
| ម.ជ.ម. | មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា |
| ADR | Alternative Dispute Resolution |
| CIETAC | Chinese International Economic and Trade Arbitration Commission |
| FAA | Federal Arbitration Act |
| GMT | Greenwich Mean Time |
| HKIAC | Hong Kong International Arbitration Centre |
| ICC | International Chamber at Commerce |
| IFC | International Finance Corporation |
| LCIA | The London Court of International Arbitration |
| NCAC | National Commercial Arbitration Centre |
| NYC | New York Convention |
| NYCC | New York Chamber at Commerce |
| NYIAC | New York International Arbitration Centre |
| SIAC | Singapore International Arbitration Centre |
| SIArb | Singapore Institute of Arbitrators |
| TOOLS | Technology Resources for Arbitration Practitioners |
| UNCITRAL | United Nations Commission on International Trade Law |

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## គោលការណ៍ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដើម្បីដោះស្រាយវិវាទដែលកើតមានឡើងនៅក្នុងផ្នែកពាណិជ្ជកម្ម ភាគីមិនមែនសុទ្ធតែពឹងផ្អែកទៅលើតុលាការទាំងស្រុងនោះទេ គឺគេអាចធ្វើការដោះស្រាយតាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបាន។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានច្រើនទម្រង់សំរាប់យកមកដោះស្រាយវិវាទដូចជាការចរចា សន្ធានកម្ម ការផ្សះផ្សា និងមជ្ឈត្តកម្ម។ ការដោះស្រាយតាមវិធីទាំងអស់នេះ សុទ្ធតែជាមូលដ្ឋានគ្រឹះនៃការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ។ មុននឹងឈានដល់ការដោះស្រាយតាមរយៈមជ្ឈត្តកម្ម ជាទូទៅភាគីវិវាទតែងតែជ្រើសរើសយកការចរចា ឬសន្ធានកម្មយកមកធ្វើមធ្យោបាយក្នុងការដោះស្រាយវិវាទជាមុនសិន ព្រោះថាការចរចា ឬសន្ធានកម្ម មានលក្ខណៈងាយស្រួលចំណាយតិច និងចំនេញពេលវេលា ព្រមទាំងក្នុងគោលបំណងរក្សាទំនាក់ទំនងរបស់ភាគីទាំងពីរ។ ទោះជាយ៉ាងនេះក្ដី មជ្ឈត្តកម្មនៅតែត្រូវការយកមកធ្វើជាមធ្យោបាយ ក្នុងការដោះស្រាយវិវាទ ព្រោះការចរចា ឬសន្ធានកម្ម មិនមានលក្ខណៈចាប់បង្ខំដល់ភាគីវិវាទ ទោះបីជាភាគីទាំងពីរបានព្រមព្រៀងគ្នាហើយក៏ដោយ។ ផ្ទុយទៅវិញដំណោះស្រាយមជ្ឈត្តកម្ម គឺមានលក្ខណៈចាប់បង្ខំទៅដល់ភាគីដែលមិនព្រមគោរព និងអនុវត្តតាមសេចក្ដីសម្រេចរបស់មជ្ឈត្តការ គឺមជ្ឈត្តវិនិច្ឆ័យ។ នៅក្នុងជំពូកនេះយើងនឹងសិក្សាជំហាននីតិវិធីនីមួយៗ ព្រមទាំងលើកឡើងនូវគុណសម្បត្តិ និងគុណវិបត្តិនៃដំណើរការនៃការដោះស្រាយវិវាទ។

## ១. លំនាំនៃការស្រាវជ្រាវ

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស (Paris Convention) ឆ្នាំ១៩៩១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើនដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ ១៩៩៩ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ ២០២១ គណៈរដ្ឋមន្ត្រីក៏បានធ្វើការអនុម័តទៅលើ កំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងឆ្នាំ ២០០៣ និងផែនការសកម្មភាពនៅក្នុងឆ្នាំ ២០០៥។ គោលបំណងនៃកំណែទម្រង់យុត្តិធម៌ និងតុលាការ គឺជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុពល និងស្ថេរភាព ច្បាប់ និងយុត្តិធម៌ប្រកាន់ភ្ជាប់នូវគោលការណ៍សិទ្ធិបុគ្គល នីតិរដ្ឋ និងភាពចែកដាច់ពីគ្នានៃអំណាចនៅក្នុង ប្រព័ន្ធប្រជាធិប្បតេយ្យ ដែលនេះគឺជួយជម្រុញដល់វិស័យឯកជនដើម្បីទទួលបាននូវភាពរីកចម្រើនសេដ្ឋកិច្ច។ ដើម្បីទទួលបាននូវភាពជោគជ័យក្នុងការអនុវត្តនូវគោលបំណងនេះ គោលដៅចំនួនប្រាំពីរត្រូវបានបង្កើតដែលក្នុងនោះ ការណែនាំនូវវិវាទដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាគោលដៅទីប្រាំមួយ។ ចំណែកឯផែនការសកម្មភាពមានគោលបំណង ស៊ើបអង្កេត បង្កើត និងពង្រឹងវិធីផ្សេងៗនៃការដោះស្រាយវិវាទក្រៅតុលាការ និង

ការដោះស្រាយវិវាទបែបប្រពៃណី។ មានមូលហេតុជាច្រើន ដែលជម្រុញឲ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទក្រៅផ្លូវតុលាការដោយក្នុងនោះមានដូចជា បញ្ហាទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាជនក្រីក្រ និងក្រុមជនដែលងាយរងគ្រោះ។ មូលហេតុទាំងនេះជម្រុញឲ្យប្រជាជនមិនប្រើប្រាស់ប្រព័ន្ធតុលាការនៅក្នុងការដោះស្រាយវិវាទ។ បញ្ហានេះ គឺមកពីការកកស្ទះសំណុំរឿង និងកង្វះខាតធនធានមនុស្សនៅតុលាការ។ ការកែទម្រង់ច្បាប់ និងយុត្តិធម៌របស់រាជរដ្ឋាភិបាលហាក់បីដូចជាផ្តោតសំខាន់ទៅលើមូលហេតុដែលថា តុលាការមិនគួរដោះស្រាយគ្រប់ជម្លោះដែលកើតឡើងនោះទេ ហើយដំណោះស្រាយក្រៅប្រព័ន្ធតុលាការគួរតែត្រូវបានយកចិត្តទុកដាក់។

ដើម្បីឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មប្រព្រឹត្តទៅយ៉ាងរលូន និងមានភាពងាយស្រួលក្នុងការអនុវត្ត ច្បាប់មជ្ឈត្តការ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៦។ ដោយអនុលោមទៅតាមច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៤ អនក្រ.បក។ គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ២២៣ MOC/SM ២០០៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ២០០៩។

## ២. ចំណោទបញ្ហា

តាមការបកស្រាយខាងនេះ យើងអាចដឹងថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានតាំងពីយូរលង់មកហើយ ហើយចំពោះការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មនៅកម្ពុជាដំបូង ក្នុងឆ្នាំ ២០១៤ គឺមានតែ២៥ ករណីតែប៉ុណ្ណោះ ហើយស្ថិតក្នុងចំនួនទឹកប្រាក់ចំនួន៧២លានដុល្លារ។ ដូចនេះដើម្បីជាចង្កៀងបំភ្លឺផ្លូវក្នុងការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មនៅកម្ពុជា ក្នុងនាមជាអ្នកអានគួរគប្បីយល់ដឹងពីចំណោទបញ្ហាដែលចោទឡើងថា តើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាអ្វី? តើការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មមានលក្ខណៈបែបណា? តើការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មដំណើរការយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរជាសារណានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវចំណេះដឹងផ្នែកច្បាប់ចំពោះ ការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មនៅកម្ពុជា ដោយហេតុ

ថា ទិដ្ឋភាពសង្គមនៅពេលមានវិវាទ បុគ្គលដែលមានវិវាទតែងជ្រើសរើសនូវការដោះស្រាយវិវាទតាមផ្លូវតុលាការជាជាងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ទោះបីជាបុគ្គលដែលមានវិវាទហើយជ្រើសរើសយក ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក៏ដោយតែមានលក្ខណៈមិនទាន់ទូលាយ និងមិនមានការពេញនិយម បើធៀបនឹងសំណុំដែលកំពុងកក់ស្ទះនៅតាមផ្លូវតុលាការ។ ប៉ុន្តែសម្រាប់ ការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្ម ជាផ្លូវសម្រាប់ការដោះស្រាយនូវវិវាទដែលមានលក្ខណៈរហ័ស និងមានការប្រើប្រាស់យន្តការនេះតាមរយៈប្រទេសដែលមានវិវាទពាណិជ្ជកម្ម។ សម្រាប់ប្រទេសកម្ពុជានីតិវិធីនេះទើបតែមានការបង្កើតឡើង ហើយសម្រាប់វិវាទពាណិជ្ជកម្មមានការកើនឡើងធ្វើឲ្យសំណុំដែលដាក់ទៅតុលាការមានការកកស្ទះ។ ហេតុនេះគួរតែមានការពង្រឹងនិងផ្សព្វផ្សាយទៅលើការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្ម។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា

គួរកត់សម្គាល់ ការបង្ហាញពីប្រធានបទដែលបានលើកឡើងខាងលើនេះ គឺធ្វើការស្រាវជ្រាវតែការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មនៅកម្ពុជា ដែលមានដែនកំណត់ស្ថិតក្រោមវិសាលភាពនៃបទដ្ឋានគតិយុត្តរបស់កម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

កន្លងមក យើងតែងតែឃើញ សៀវភៅសរសេរពីប្រធានបទជាច្រើនដែលស្រដៀងនិងប្រធានបទរបស់យើងខ្ញុំពោលប្រធានបទ **ការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្មនៅកម្ពុជា**។ ដោយមើលឃើញភាពកម្រនូវអត្ថបទខាងលើ យើងខ្ញុំក៏សម្រេចលើកប្រធានបទខាងលើយកមកសរសេរនិងតាក់តែងឡើង ក្នុងន័យឱ្យសិស្សានុសិស្ស និស្សិត ដើម្បីទុកជាឯកសារយោងឬអត្ថបទស្រាវជ្រាវ។ ជាពិសេសសិស្សនិស្សិតគួរតែបានដឹងពីសិទ្ធិសំខាន់ៗ ការដោះស្រាយវិវាទដោយមជ្ឈការផ្នែកពាណិជ្ជកម្ម។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវរបស់យើងខ្ញុំគឺបានប្រើវិធីសាស្ត្រមួយចំនួនរួមមាន ធ្វើសិក្សាពីសក្ខាសាលាការចែករំលែងរបស់មជ្ឈត្តករ ដែលជាសមាជិករបស់ម.ជ.ម.។ បន្ថែមពីនេះយើងបានសិក្សានិងចូលរួមសម្រាប់វគ្គខ្លីរបស់អ្នកវិជ្ជាជីវៈច្បាប់ និងបានធ្វើការស្រាវជ្រាវឯកសារ នៅតាមបណ្ណាល័យ គេហទំព័រ សៀវភៅ និងឯកសារនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបបញ្ហាទៅនឹងការបញ្ហាខាងលើ យើងខ្ញុំធ្វើការរៀបចំរចនាសម្ព័ន្ធនៃស្រាវជ្រាវនៃប្រធានបទនេះ ដែលផ្តោតទៅលើ ៣ជំពូកធំៗ ដូចជា

ជំពូកទី១ គោលការណ៍ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ជំពូកទី២ ការចាប់ផ្ដើមមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

ជំពូកទី៣ ការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មតាមមជ្ឈត្តការនៅប្រទេសកម្ពុជា។

# ជំពូកទី១

# គោលការណ៍ក្នុងការដោះស្រាយ
# វិវាទក្រៅប្រព័ន្ធតុលាការ

# ជំពូកទី១

# គោលការណ៍ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## ១.១. ការចរចា

ការចរចា ជាទម្រង់ទូទៅនៃដំណើរការដោះស្រាយវិវាទដែលគេឃើញមានក្នុងប្រទេសដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) និងប្រព័ន្ធច្បាប់អង់គ្លេស (Common Law)។[1] យើងក៏អាចប្រើប្រាស់ ការចរចាក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ ដូចជាការទិញលក់សម្ភារៈប្រើប្រាស់ការតថ្លៃទំនិញជាដើម។

ការចរចា អាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយវាជួយដល់ការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មជាច្រើន។ ការដោះស្រាយវិវាទតាមរយៈការចរចានេះ អាចជួយឲ្យភាគីវិវាទមិនចាំបាច់ធ្វើការចំណាយថវិកាច្រើន រក្សាបាននូវទំនាក់ទំនងរវាងភាគី រក្សាការសម្ងាត់ និងការជ្រើសរើសដំណោះស្រាយជាការព្រមព្រៀងគ្នារបស់ភាគីដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការអនុវត្ត។[2] ការចរចាកើតឡើងនៅពេលដែលគូភាគីនៃជម្លោះរបស់ពួកគេដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអ្នកតំណាងរបស់ពួកគេ។ ការចរចាគឺជាវិធីដោះស្រាយជម្លោះតាមផ្លូវច្បាប់តែមួយគត់ដែល មិនមានភាគីអព្យាក្រឹត្យចូលរួម។ ការចរចាគឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមវិធីនេះ ភាគីទាំងអស់ដាក់ជូនឬពិចារណាលើសំណើរផ្សេងៗ រហូតដល់សំណើរណាមួយត្រូវបានធ្វើឡើងហើយត្រូវបានគេទទួលយក។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬមានលក្ខណៈផ្លូវការ។ម្យ៉ាងវិញទៀត គេអាចធ្វើការចរចាតាមរយៈសំបុត្រ ឬអ៊ីមែលផងដែរ។

នៅក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងផ្ទាល់ ចំពោះមុខគ្នា ប៉ុន្តែគេក៏អាចចរចាតាមទូរស័ព្ទផងដែរ។ បុគ្គលគ្រប់រូបអាចធ្វើការចរចានៅគ្រប់ពេលទាំងអស់ ដែលជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងភាគីវិវាទ។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃគេធ្វើការចរចាទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ការទិញលក់របស់ប្រើប្រាស់ប្រចាំថ្ងៃ និងទំនិញផ្សេងៗ។

## ១.២. នីតិវិធីក្នុងការចរចា

ដំបូង យើងអាចជ្រើសរើសយកការចរចាមកធ្វើការដោះស្រាយជាបឋម មុនពេលដែលភាគីសម្រេចដោះស្រាយតាមប្រព័ន្ធតុលាការ។ ការចរចាប្រព្រឹត្តក្នុងរូបភាពជាច្រើនតាមការព្រមព្រៀងរបស់ភាគីតាមរយៈការ

[1] មេធាវីស៊ីវិន អ៊ែម អូស្ទើរមីឡើ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.២៥ បោះពុម្ពឆ្នាំ ២០០៩។

[2] មេធាវីស៊ីវិន អ៊ែម អូស្ទើរមីឡើ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១១ បោះពុម្ពឆ្នាំ ២០០៩។

ចរចាផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សររបស់ភាគី។ បន្ថែមពីនេះគូភាគីទាំងសងខាងអាចរកអ្នកដែលមានចំណេះដឹងមកជួយចរចាដើម្បីជាផលប្រយោជន៍ដល់គូភាគី។

ក្នុងការចរចា ភាគីទាំសងខាងត្រូវត្រៀមឲ្យរួចជាស្រេច នៅវត្ថុបំណងរៀងៗខ្លួនដើម្បីយកមកធ្វើការចរចា ឬពិភាក្សាជាមួយអ្នកតំណាងរបស់ខ្លួន នូវចំនួនទឹកប្រាក់ឬចំណែកដែលខ្លួនចង់បាន។[3] នៅក្នុងការចរចាបែបបែងចែក ភាគីវិវាទសន្មត់ថាមានធនធានដែលមានចំនួនជាក់លាក់មួយ ដែលពួកគេត្រូវ បែងចែករវាងគ្នា និងគ្នា។ នៅក្នុងកំឡុងពេលចរចា ភាគីវិវាទកំណត់ពីជំហរខ្លួនឯងរៀងៗខ្លួន។ ភាគីចុងចម្លើយដឹងអំពីចំនួនអតិបរមាដែលខ្លួនមានឆន្ទៈក្នុងការបង់ ហើយភាគីរងគ្រោះដឹងអំពីចំនួនអប្បបរមាដែលខ្លួនមានឆន្ទៈក្នុងការទទួលយក។ នៅក្នុងដំណើរការនៃការចរចា អាចកើតមានឡើងនូវភាពតានតឹងផ្លូវចិត្ត ឬអារម្មណ៍មិនល្អរវាងគូភាគីដែលអាចជាមូលហេតុដែលធ្វើអោយការចរចាមិនបានទទួលជោគជ័យ ភាគីចរចាអាចសំរេចមិនធ្វើការចរចាដោយផ្ទាល់ ប៉ុន្តែផ្ទុយទៅវិញពួកគេអាចចាត់តាំងជនណា ដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងជម្លោះអោយចរចាជំនួសពួកគេជាញឹកញាប់តំណាងបែបនេះអាចមានសមត្ថភាពយ៉ាងច្រើនផ្តោតលើបញ្ហាជា ខ្លឹមសារ មិនមែនទាក់ទាញទឹកចិត្តដោយសារមនោសញ្ចេតនានោះទេ។ បន្ថែមពីនេះភាគីជំលោះក៏ធ្វើការចរចា ដោយផ្ទាល់វាមានលក្ខណៈប្រសើរជាង ដោយសារតែពួកគេយល់អំពីប្រយោជន៍ផ្ទាល់ខ្លួន និងស្ថានភាពនៃជម្លោះរបស់ពួកគេជាងអ្នកដទៃ។

យើងក៏អាចចរចាផ្អែកលើផលប្រយោជន៍ផងដែរ ព្រោះមានលក្ខណៈសហការជាងការចរចាបែបបែងចែក។ គេត្រូវសន្មតថា មានផលប្រយោជន៍សំខាន់ៗដទៃទៀតដែលគេត្រូវរកឱ្យឃើញនិងតម្រូវតាម។ ភាគីវិវាទអាចមានផលប្រយោជន៍មួយចំនួនរួមគ្នា ឬយ៉ាងហោចណាស់ផលប្រយោជន៍មួយចំនួនដែលបំពេញបន្ថែមឱ្យគ្នា។ ការចរចាមិនមានប្រេីវិធានអ្វីឱ្យជាក់លាក់នោះទេ មិនមានច្បាប់ ឬលក្ខន្តិកៈណាមួយដែល ណែនាំអំពីដំណើរការនៃការចរចាឡើយ។ ជួនកាលការចរចាជា វិធីសាស្ត្របែបបែងចែកដែលត្រូវបានគេហៅថាជា ការតថ្លៃ។ ជាគោលការណ៍ ភាគីនីមួយៗនិយាយ តតាំងគ្នាចុះឡើងអំពីតម្លៃដែលខ្លួនស្នើ ជួនកាល ភាគីទាំងសងខាងអាចឈានដល់ការព្រមព្រៀងគ្នា ហើយជួនកាល ទៀត គឺមិនមានការព្រមព្រៀងគ្នាទេ។

**ឧទាហរណ៍** ធា ទៅផ្សារហើយចង់ទិញតុមួយពីវណ្ណា គាត់បញ្ជាក់ថា តុនោះត្រូវលក់ក្នុងតម្លៃ២៥ដុល្លាអាមេរិក។ ធា និយាយថា អូ! តុនេះស្អាតណាស់ ប៉ុន្តែអ្នកទារថ្លៃណាស់។ ខ្ញុំរីករាយនឹងឱ្យ ត្រឹម១០ដុល្លា ប៉ុន្តែលើសពីហ្នឹង គឺមិនបានទេ។ បន្ទាប់មកវណ្ណាក៏ឆ្លើយតបថា មែនហើយ តុនេះស្អាតណាស់ វាធ្វើពីឈើដែលល្អ។ យើងត្រូវចំណាយពេលអស់៥ថ្ងៃដើម្បីធ្វើវា ខ្ញុំមិនអាចលក់ខាតបានទេ។ ខ្ញុំអាចចុះថ្លៃជាពិសេសឱ្យអ្នកបានត្រឹម

[3] មេធាវីស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៤២ ដល់ ៤៣ បោះពុម្ពឆ្នាំ ២០០៩។

២០ដុល្លាប៉ុណ្ណោះ ប៉ុន្តែមិនអាចចុះក្រោមហ្នឹងទៀតទេ ខ្ញុំត្រូវចំណេញតិចតួចដែរ។ បន្ទាប់មក ធានិយាយថា ១២ ដុល្លា បានទេ? ហើយ ការតថ្លៃនោះក៏ចេះតែបន្តទៅទៀត។ អ្នកទាំងពីរអាចឈានទៅដល់ការព្រមព្រៀងគ្នា ប៉ុន្តែលុះត្រាតែតម្លៃទិញជាអតិបរមារបស់ ធា ស្មើឬធំជាងតម្លៃលក់អប្បរមារបស់វណ្ណាប៉ុណ្ណោះ។

## ១.២.១. ដំណើរការក្នុងការចរចា

នៅក្នុងដំណាក់កាលចរចា យើងអាចបែងចែកជាច្រើនដំណាក់ដូចជា ការចាប់ផ្តើមនិងការបញ្ចប់។ នៅក្នុងការចាប់ផ្តើមនៃកិច្ចចរចា យើងអាចនឹងមើលរំលង ដោយគិតថាមិនមែនជាចំណុចសំខាន់តែចំណុចនេះ អាចជួយយើងឱ្យដើរទៅដល់ដំណាក់កាលបន្ទាប់។ នៅក្នុងដំណាក់កាលនេះ ភាគី និងមេធាវីរបស់ខ្លួន ត្រូវពិនិត្យមើលរឿងក្តីយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាមូលដ្ឋានមួយចំនួន មុននឹងចាប់ផ្តើម ដំណើរការចរចា ជំហានទីមួយរបស់មេធាវី គឺធ្វើការស្រាវជ្រាវ និងស្វែងរកអង្គហេតុដែលពាក់ព័ន្ធនឹងរឿងក្តីទាំងអស់។ ក្នុងដំណាក់កាលនេះ ជាទូទៅមានន័យថាការសម្ភាសជាមួយមនុស្សម្នាក់ ឬច្រើននាក់ដោយផ្ទាល់។ វាក៏អាចពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវភស្តុតាងជាឯកសារដូចជា កិច្ចសន្យា ឬវិក័យប័ត្រផ្សេងៗ។ បន្ទាប់ពីមេធាវីយល់ច្បាស់អំពីអង្គហេតុមក ជំហានបន្ទាប់គឺធ្វើការវិភាគច្បាប់ ដោយផ្អែកលើអង្គហេតុទាំងនោះ ច្បាប់អាចមិនមានចម្លើយដែលច្បាស់លាស់។ ប្រសិនបើ បទដ្ឋានច្បាប់អាចមានភាពច្បាស់លាស់ ប៉ុន្តែអង្គហេតុអាចមានភាពចំរូងចំរាស់។ ត្រង់ចំណុចនេះ ប្រការដែលសំខាន់គឺ មេធាវីត្រូវព្យាយាមបង្កើតអំណះអំណាងផ្លូវច្បាប់ ឱ្យបានច្រើនតាមដែលអាចធ្វើបាន ព្រមទាំងវាយតម្លៃដោយមិនលម្អៀងអំពីចំណុចខ្លាំងនៃអំណះអំណាងទាំងនេះ។[4]

នៅក្នុងករណីខ្លះ ផលប្រយោជន៍និងគោលដៅទាំងនេះអាចមានសារៈសំខាន់ជាងប្រាក់កាក់សម្រាប់ភាគីម្ខាង។ **ឧទាហរណ៍** កូនក្តីអាចមានអំណះអំណាងរឹងមាំលើផ្នែកទស្សនៈផ្លូវច្បាប់ ប៉ុន្តែផលប្រយោជន៍របស់កូនក្តីនោះអាចជា ការជៀសវាងនូវការប្រឈមមុខជាសាធារណៈ ឬក៏ថាកូនក្តីអាចត្រូវការដំណោះស្រាយមួយដែលឆាប់រហ័ស ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ឬពេលកំណត់នៃអាជីវកម្ម ហេតុនេះធ្វើឱ្យដំណោះស្រាយដែលឆាប់រហ័ស កាន់តែមានសារៈសំខាន់ជាងការទទួលបានជាអតិបរមាពីការព្រមព្រៀងស្រុះស្រួល។

ការពិភាក្សា ក្រោយពេលដែលបានអង្កេតអង្គហេតុ ការវិភាគច្បាប់ និងផលប្រយោជន៍ ត្រូវបានស្វែងយល់រួច មេធាវីអាចគណនា និងជ្រើសរើសពោលគឺជម្រើសប្រសើរបំផុតរបស់កូនក្តីក្រៅពីការព្រមព្រៀង តាមរយៈការចរចា។ នៅក្នុងដំណាក់កាលនេះ មេធាវីអាចមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកដើម្បីពិភាក្សាអំពី

[4] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៦៦ បោះពុម្ពឆ្នាំ ២០០៩។

បែបបទនៃការចរចាដូចជាថា តើគួរមានការចរចាទេ តើការចរចាត្រូវធ្វើនៅពេលណា កន្លែងណា និងដោយរបៀបណា។[5]

ចំពោះសំនួរថាតើគួរមានការចរចាដែលឬទេគឺ ចម្លើយនោះគួរតែមាន ព្រោះវាមានសារៈសំខាន់ណាស់។ ករណីមួយចំនួន ភាគីទីមួយដែលស្នើសុំអោយមានការចរចាអាចបង្ហាញភាពទន់ខ្សោយរបស់ខ្លួន។ ប្រសិនបើមាន ករណីបែបនេះមែនមេធាវីត្រូវគិតដោយប្រុងប្រយ័ត្នអំពីរបៀបបង្ហាញសំណើរនោះ។ ប្រសិនបើភាគីមានប្រយោជន៍កាន់តែតិចនៅក្នុងការចរចាភាគីនោះ តែងតែមានជំហររឹងមាំស្តែងឡើង។ ហេតុនេះការព្យាយាមបង្ហាញការមិនចំណាប់អារម្មណ៍នៅក្នុងការចរចា ប៉ុន្តែនៅតែយល់ព្រមចូលរួមក្នុងការចរចា។

ពាក់ព័ន្ធនឹងសំនួរថាតើការចរចាត្រូវធ្វើឡើងនៅពេលណា ផលប្រយោជន៍ខ្ពស់របស់គូភាគីក្នុងការអោយមានការចរចាជាបន្ទាន់ អាចចង្អុលបង្ហាញពីកំរិតមួយនៃតំរូវការ ឬសេចក្តីអស់សង្ឃឹម។ ប្រសិនបើភាគីម្ខាងយល់ថា ការចរចាត្រូវតែធ្វើឡើងជាបន្ទាន់ ភាគីនោះអាចប្រឈមមុខនឹងតំរូវការប្រាក់ ឬភាគីនោះអាចប្រឈមមុខនឹងរយៈពេលកំណត់ផ្នែកអាជីវកម្មដ៏សំខាន់ណាមួយ ឬភាគីនោះអាចមានការភ័យខ្លាចថា វិវាទនោះនឹងត្រូវបើកចំហជាសាធារណៈដែលអាចបង្ករមហន្តរាយធ្ងន់ធ្ងរដល់ខ្លួនបាន។ ទោះបីជាមានមូលហេតុអ្វីក៏ដោយ វាមានសារៈសំខាន់ក្នុងការចងចាំចំនុចនេះ នឹងគួរធានាថាភាគីវិវាទមានបំណងចង់អោយមានការចរចាជាបន្ទាន់។[6]

ចំពោះសំណួរដែលបានចោទសួរថាតើការចរចាត្រូវធ្វើនៅកន្លែងណា និងដោយរបៀបណាមានលក្ខណៈកាន់ តែល្អិតល្អន់ចំពោះសារៈសំខាន់របស់វា។ ប្រសិនបើការចរចា ធ្វើឡើងនៅការិយាល័យមេធាវីនៃគូវិវាទភាគីនោះ នឹងមានប្រៀបខាងទីតាំង អ្នកអាចមានអារម្មណ៍ងាយស្រួលជាងភាគីម្ខាងទៀត ដែលមានអារម្មណ៍មិនសុខស្រួល នៅក្នុងបរិយាកាសដែលខ្លួនមិនធ្លាប់ស្គាល់ លើសពីនេះទៅទៀតនៅក្នុងវប្បធម៌មួយចំនួនគេអាចចាត់ថា ភាគីមានតំរូវការជាងក្នុងការព្រមព្រៀងដោះស្រាយពីព្រោះពួកគេសុខចិត្តធ្វើដំណើរមកជួប។ ដោយសារមូលហេតុនេះ ជួនកាលការចរចាត្រូវបានធ្វើឡើនៅកន្លែងអព្យាក្រិត្យដូចជា ការិយាល័យគណៈមេធាវី មជ្ឈមណ្ឌលតុលាការ ឬមជ្ឈមណ្ឌលសម្រុះសម្រួលឯកជន។[7]

ចំពោះសំណួរដែលបានចោទសួរថាតើការចរចាត្រូវធ្វើឡើងដោយរបៀបណា គឺវាពាក់ព័ន្ធនឹងដំណើរការនៃ ការចរចាផ្ទាល់ តើភាគីទាំងពីរត្រូវធ្វើអ៊ីមែលឱ្យគ្នាឬទេ? តើពួកគេគួរចរចាតាមទូរស័ព្ទដែរឬទេ? តើពួកគេត្រូវ

---

[5] មេធាវីស៊្វីន អ៊ែម អូស្ទើរមីឡឺរ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៦៨ បោះពុម្ពឆ្នាំ ២០០៩។

[6] មេធាវីស៊្វីន អ៊ែម អូស្ទើរមីឡឺរ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៦៩ បោះពុម្ពឆ្នាំ ២០០៩។

[7] មេធាវីស៊្វីន អ៊ែម អូស្ទើរមីឡឺរ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៦៩ បោះពុម្ពឆ្នាំ ២០០៩។

ចរចាដោយផ្ទាល់ដែរឬទេ? ប្រសិនបើជួបផ្ទាល់ តើភាគីវិវាទត្រូវមានវត្តមាននៅពេលចរចាដែរឬទេ? ប្រសិនបើកូនក្តីរបស់អ្នកជាអ្នកមានប្រាក់ច្រើនជាង ឬជាមនុស្សដែលពោរពេញទៅដោយភាពជឿជាក់ពីធម្មជាតិនោះ ការចរចាទល់មុខគ្នាជាមួយកូនក្តីអាចមានប្រយោជន៍ ឬកូនក្តីរបស់អ្នកអាចមានលទ្ធភាពផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធនឹងអង្គហេតុ ដែលមានសារៈសំខាន់នៅក្នុងអំឡុងពេលចរចា ឬអាចថាពីដំបូងមកកូនក្តីរបស់អ្នកអាចមានការរំពឹងទុកចំពោះដំណោះស្រាយដែលមិនប្រាកដនិយម ហើយការស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតអាចជួយ បន្ធូរបន្ថយការរំពឹងទុកទាំងនោះបាន។[8]

ប្រសិនបើមានការព្រមព្រៀងនៅក្នុងកំឡុងពេលចរចាហើយ ត្រូវធានាថាលក្ខខណ្ឌព្រមព្រៀងទាំងនោះត្រូវបានសរសេរចូលជាលាយលក្ខណ៍អក្សរភ្លាមៗ ព្រោះថាការចងចាំរបស់មនុស្សតែងតែរលត់ទៅវិញ ហើយប្រសិនបើភាគីចរចាពន្យាពេលដោយគ្រាន់តែចងចាំអំពីរលក្ខខណ្ឌនៃការព្រមព្រៀងនោះ ក្រោយមកទៀតអាចមិនឯកភាពទៅលើលក្ខខណ្ឌជាក់លាក់ ណាមួយនៅពេលដែលពួកគេព្យាយាមសរសេរវាចូល។

ម្យ៉ាងទៀត ប្រសិនបើគូភាគីមានពេលវេលាច្រើនពេកនោះ ពួកគេអាចពិចារណាឡើងវិញនូវសម្បទានរបស់ខ្លួនហើយនឹងព្យាយាម ចរចាឡើងវិញដើម្បីទទួលបានលក្ខខណ្ឌកាន់តែប្រសើរជាងមុន។ ដើម្បីជៀសវាងបញ្ហានេះ ភាគីចរចា ត្រូវត្រៀមខ្លួនជានិច្ចនូវលក្ខខណ្ឌជាមូលដ្ឋាននៃកិច្ចព្រមព្រៀង និងចុះហត្ថលេខា ហើយបន្ទាប់មកសរសេរលក្ខខណ្ឌស្តាពរអោយបានឆាប់។ បន្ទាប់ពីនោះ មេធាវីទាំងអស់មានលទ្ធភាពប្រើប្រាស់ទម្រង់ច្បាប់សមស្រប។

ចំណុចដែលសំខាន់នោះ គឺភាគីមិនត្រូវប្រើក្រសែភ្នែក កាយវិការ ឬប្រើប្រាស់ពាក្យពេចន៍ទាំងឡាយណាដែលធ្វើ អោយភាគីម្ខាងទៀតកើតមានអារម្មណ៍មិនល្អដែលជាហេតុបណ្តាលអោយមានការរំលាយកិច្ចព្រមព្រៀងនោះទៅវិញ។

## ១.២.៣. គុណសម្បត្តិនៃការចរចា

លទ្ធផលដែលទទួលបានមានទាំងគុណសម្បត្តិ រាល់ការចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត វាជាវិធីមួយដែលនាំ ឱ្យការចរចាមានប្រជាប្រិយភាព ជាងវិធីផ្សេងទៀត[9] ចំណែកភាពឯកជនភាពនៃគូភាគីដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ គ្មានការចូលរួមពី

[8] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៦៩ បោះពុម្ពឆ្នាំ ២០០៩។

[9] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១១ បោះពុម្ពឆ្នាំ ២០០៩។

តុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ ហើយភាពបត់បែន ការចរចាមានភាពបត់បែនក្នុងដំណើរការ និងលទ្ធផលដោយភាពបត់បែនក្នុងដំណើរការមានន័យថា ការចរចាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ លទ្ធផលភាគីវិវាទផ្ទាល់ជាអ្នកឈានដល់ការស្រុះស្រួលរវាងគ្នា ដែលភាគីមិនអាចធ្វើបាននៅក្នុងការដោះស្រាយនៅមជ្ឈត្តការ ឬតុលាការឡើយ ចំណោះល្បឿន ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ភាគីមិនចាំបាច់ត្រូវរង់ចាំចៅក្រមមជ្ឈត្តករ ឬសន្ធានការី ដើម្បីធ្វើសវនាការ និងសម្រេចលើរឿងក្តីនោះឡើយបញ្ហាអាចត្រូវបានដោះស្រាយភ្លាមៗឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា ក្រលេកមកមើលការគ្រប់គ្រងវិញ ការចរចាផ្តល់ឱ្យភាគីវិវាទនូវលទ្ធភាពគ្រប់គ្រងយ៉ាងពេញលេញទៅលើដំណើរការនិងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើត្រូវធ្វើការចរចាតាមរបៀបណា និងថាតើនឹងមានការស្រុះស្រួលដែរឬទេ។ ក្នុងការចរចា គេមិនបង្ខំភាគីណាមួយឱ្យចូលក្នុងដំណើរការចរចា ឬការស្រុះស្រួលណាមួយដោយគ្មានការព្រមព្រៀងពីភាគីវិវាទនោះទេ បើចំពោះការរក្សាទំនាក់ទំនងបន្តការចរចា ផ្តល់លទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលណាមួយ ដែលអាចរក្សាទំនាក់ទំនងនេះ បានដែលពួកគេធ្លាប់មានពីមុនមក។[10] ការអនុវត្តដំណោះស្រាយ ការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តីណាមួយ អាចត្រូវបានកត់បញ្ចូលក្នុងនីតិវិធីតុលាការ នៅចំពោះមុខចៅក្រម ហើយនិងអាចអនុវត្តដូចជាសាលក្រមដែរ។[11]

## ១.២.៤. គុណវិបត្តិនៃការចរចា

បើយើងសង្កេតមើលគុណវិបត្តិវិញ ការចរចាមានការពន្យាពេល ដោយភាគីម្ខាងអាចពន្យាពេលដំណើរការនៃការចរចា បើសិនជាខ្លួនចង់នៅក្នុងស្ថានភាពចរចាសុទ្ធសាធមួយ គ្មានវិធីអ្វីអាចបង្ខំភាគីណាមួយឱ្យពន្លឿនសកម្មភាពបានឡើយ។[12] ហើយភាគីប្រកាន់ជំហមិនសមហេតុផលនៅក្នុងការចរចា ប្រើប្រាស់មធ្យោបាយមិនប្រាកដប្រជាដើម្បីបង្ហិនពេលវេលា ឬគេចវេសពីបណ្តឹងតុលាការ បន្ទាប់ពីការចរចារួច ភាគីអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងសុខស្រួលមួយដែល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។ ប៉ុន្តែមួយរយៈក្រោយមកភាគីណាមួយអាច មិនគោរពតាមលក្ខខណ្ឌ ការស្រុះស្រួលដោយសារតែការស្រុះស្រួលនោះ គ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីម្ខាងទៀតគ្មានវិធីដោយផ្ទាល់ក្នុងការដាក់ឱ្យអនុវត្តតាមផ្លូវតុលាការឡើយ។

---

[10] មេធាវី កៅ សីហា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទំ. ១៣

[11] មេធាវី កៅ សីហា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទំ. ៣និង៤

[12] ដដែល

ជាលទ្ធផល ភាគីនោះអាចនៅតែត្រូវដាក់ពាក្យប្តឹងទៅតុលាការ ហើយត្រូវរង់ចាំក្នុងរយៈពេលយូរ ដើម្បីអនុវត្តកិច្ចព្រមព្រៀងស្រុះស្រួលខាងដើមនោះ ប៉ុន្តែបើភាគីម្ខាងមានអំណាចខ្លាំងពេក មានកាលៈទេសៈមួយចំនួនដែលភាគីមានវិសមភាពនឹងគ្នានៅក្នុងអំណាចចរចា ជាហេតុនាំឱ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសពេក។

ជារួមមកគុណវិបត្តិទាំងនេះ ទោះជាផលប៉ះពាល់ចាយពេលវេលាច្រើនយ៉ាងនេះក្តីគឺជាជម្រើស ដំបូងដ៏ល្អបំផុត។ មុននឹងដាក់ពាក្យបណ្តឹង ឬសំអាងលើមជ្ឈត្តករ មេធាវីជាច្រើន តែងសាកល្បងធ្វើការចរចាពីព្រោះវាមានភាពឆាប់រហ័ស និងមានតម្លៃថោកជាងវិធីដោះស្រាយវិវាទផ្សេងទៀត។[13]

## ១.៣. សន្ធានកម្ម

សន្ធានកម្ម គឺជានីតិវិធីទីពីរមួយ ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលមានលក្ខណៈងាយស្រួល បត់បែន ដោយមានភាគីទីបីជាសន្ធានការីដែលមានអព្យាក្រឹត្យភាព ក្នុងការជួយដល់គូភាគីវិវាទពីរឬច្រើន ដើម្បីចរចានិងឈានដល់ការសះជានូវវិវាទដោយស្ម័គ្រចិត្ត។ គូភាគីមានអំណាចពេញលេញក្នុងការសម្រេចអំពីការសះជានិងវិវាទរបស់ពួកគេនិងខ្លឹមសារនៃការសះជានោះ។ ដើម្បីសម្រេចបាននូវគោលបំណងនេះសន្ធានការីប្រើជំនាញ និងបច្ចេកទេសជាច្រើនផ្សេងៗគ្នា ដើម្បីជួយភាគីក្នុងការឈានដល់ការសះជា។ សន្ធានការី មិនមានសិទ្ធិអំណាចក្នុងការសម្រេចសេចក្តីឡើយ។ គូភាគីជាអ្នកសម្រេចនិងមានអំណាចពេញ លេញលើលទ្ធផលនៃការចរចាតាមរយៈនីតិវិធីនេះ។[14]

សន្ធានកម្មក៏មានការចូលរួមពីសំណាក់តតិយជនដែលមានអព្យាក្រឹត្យ ក្នុងការជួយសម្រុះសម្រួលវិវាទដោយរៀបចំកិច្ចការសម្រុះសម្រួលបានលឿន ចំណាយសោហ៊ុយតិច ហើយមិនធ្វើឱ្យប៉ះពាល់សិទ្ធិប្រយោជន៍ថែមទាំងរក្សាការសម្ងាត់។ យើងក៏ផ្តល់សិទ្ធិឱ្យទៅសិទ្ធិវន្តក្នុងការធ្វើការចរចា និងសម្រេចចិត្តជំនួសផងដែរ។ ក្នុងនេះផងដែរសន្ធានការី មានសិទ្ធិក្នុងការរៀបចំដំណើរការ ដោះស្រាយវិវាទ ប៉ុន្តែត្រូវឆ្លងកាត់ការពិគ្រោះពីភាគីទាំងសងខាងជាមុន។ សន្ធានកម្មបានផ្តល់សិទ្ធិដល់ភាគីវិវាទ ក្នុងការសម្រេចពីលទ្ធផល ខុសពីការដោះស្រាយវិវាទតាមតុលាការនិងមជ្ឈត្តការ។ ជាងនេះទៅទៀតអាចឱ្យគូភាគីបង្កើត និងទទួលយកដំណោះស្រាយដែលមានលក្ខណៈច្នៃប្រឌិត។

[13] មេធាវី កៅ សីហា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទំ.៤។

[14] មេធាវី ព្រុំ សាវតា អត្ថបទព្រឹត្តិបត្រមេធាវី ទំ.១១។

### ១.៣.១. នីតិវិធី និង ដំណើរការនៃសន្ធានកម្ម

ដំណើរការក្នុងការធ្វើសន្ធានកម្ម មានរបៀបទៅតាមដំណាក់កាល និងតាមការព្រមព្រៀងរវាងគូរភាគី ដែលកំណត់នៅកិច្ចសន្យា។ សន្ធានកម្មមានការបែងចែកទៅជា៣ (បី) ដំណាក់កាលរួមមាន ដំណាក់កាលរៀបចំ ដំណាក់សន្ធានកម្ម និងដំណើកាលចរចា។

ដំណាក់កាលរៀបចំ គូភាគីធ្វើសកម្មភាពជាអាទិ៍ ជូនដំណឹងទៅភាគី និងមជ្ឈមណ្ឌលស្ថាប័នដែលផ្តល់សេវាសន្ធានកម្ម ធ្វើការតែងតាំងសន្ធានការី កំណត់អំពីដំណើរការសន្ធានកម្ម (កាលបរិច្ឆេទ និងរយៈពេល ទីតាំង ថ្លៃសេវាសន្ធានការី ជាដើម) ចុះកិច្ចសន្យាសន្ធានកម្ម។ បន្ទាប់ពីនេះ សន្ធានការីដែលត្រូវបានតែងតាំង អាចទាក់ទងទៅភាគីដើម្បីផ្តល់ព័ត៌មាន ឯកសារ អំពីវិវាទ និងការទាមទាររបស់ពួកគេ។ ក្រោយការតែងតាំងសន្ធានការីអាចណែនាំខ្លួនធ្វើឱ្យភាគី ទុកចិត្តខ្លួនសួរព័ត៌មានបឋមនានាដែលខ្លួនគួរដឹងអំពីវិវាទ ដើម្បីធ្វើការត្រៀមសម្រាប់ដំណើរការ ប្រាប់គូភាគីអំពីតួនាទីរបស់ខ្លួន និងអ្វីដែលគូភាគីអាចរំពឹងទុកថានឹងកើតឡើងនៅថ្ងៃធ្វើនីតិវិធីសន្ធានកម្ម។ល។

ដំណាក់កាលដំណើរការសន្ធានកម្ម នេះអាចជាពេលដំបូង ដែលសន្ធានការីជួបផ្ទាល់ជាមួយគូភាគី ដែលសន្ធានការី គួរធ្វើការណែនាំខ្លួននិងតួនាទី អំពីដំណើរការនិងវិធានឬគោលការណ៍មួយចំនួន (គោលការណ៍រក្សាការសម្ងាត់ គោលការណ៍ស្ម័គ្រចិត្ត។ល។ សន្ធានការីត្រូវជូនភាគីនៅក្នុងបន្ទប់ឯកជនរបស់ពួក េគរៀងៗខ្លួន។ បន្ទាប់មក សន្ធានការីក៏គួរសួរបញ្ជាក់អំពីអត្តសញ្ញាណរបស់គូភាគី និងសិទ្ធិអំណាចសម្រេចរបស់បុគ្គលចូលរួមការទាមទាររបស់គេ និងការបារម្ភនានាប្រសិនបើមាន។បន្ទាប់ពីជួបភាគីនីមួយៗនៅបន្ទប់ឯកជនរៀងៗខ្លួនហើយ សន្ធានការីគួររៀបចំឱ្យភាគី ជួបរួមគ្នាម្តង (First Joint Meeting) ដើម្បីឱ្យភាគីធ្វើសេចក្តីថ្លែងសង្ខេបពីការទាមទារមូលហេតុ នៃការទាមទារនិងការបារម្ភនានា។ ក្នុងការជួបរួមគ្នាដំបូងនេះ សន្ធានការីគួរបញ្ជាក់ម្តងទៀត អំពីតួនាទីរបស់ខ្លួន គោលការណ៍សំខាន់ៗ និងរបៀបនៃដំណើរការសន្ធានកម្មក្នុងថ្ងៃនេះ។ បន្ទាប់ពីឱ្យសេចក្តី ភាគីធ្វើថ្លែងបើកសង្ខេបអំពីការទាមទារមូលដ្ឋាននៃការទាមទារ និងការបារម្ភនានារួចសន្ធានការីគួរបំបែកភាគីទៅបន្ទប់ឯកជនរបស់គេរៀងៗខ្លួនវិញ។

ដំណាក់កាលរកចំណុចវិវាទក្នុងដំណាក់កាលនេះ សន្ធានការីត្រូវជួបភាគីក្នុងបន្ទប់ឯកជនរបស់ពួកគេដើម្បីពិភាក្សា ជាមួយភាគីនោះ សួរនាំពីអង្គហេតុ ការព្រួយបារម្ភ អ្វីដែលភាគីចង់បានពីការដោះស្រាយវិវាទនាថ្ងៃនោះ និងបន្ទាប់មកជួបជាមួយភាគីម្ខាងទៀតដើម្បីសួរនាំដូចគ្នា។ គោលបំណងចម្បងនៃការជួបភាគីនីមួយៗបែបនេះគឺដើម្បីពិភាក្សា ដើម្បីប្រមូលព័ត៌មាន និងសួរនាំឱ្យភាគីបានដឹងអំពី វិវាទ ជំហ សិទ្ធិនិងប្រយោជន៍ និងដំណោះស្រាយដែលអាចទៅរួចសម្រាប់ភាគី។ សន្ធានការីដើរតួជាអ្នកនាំសារក្នុងដំណាក់កាលនេះ ហើយអាច

ចែករំលែកព័ត៌មានដែលខ្លួនទទួលបានពីភាគីម្ខាងជូនភាគីម្ខាងទៀត ប្រសិនទទួលបានការអនុញ្ញាតពីភាគីជាម្ចាស់នៃព័ត៌មាននោះ។

សន្ធានការីដែលពូកែ និងមានសមត្ថភាព ធ្វើឱ្យភាគីដឹងច្បាស់ជាងមុនអំពីចំណុចវិវាទរបស់ខ្លួន ដឹងពីភាពខុសគ្នានៃជំហ និងផលប្រយោជន៍ អ្វីដែលត្រូវការហានិភ័យ ឬភាពលំបាកនានារបស់ខ្លួន និងភាគីម្ខាងទៀត និងអាចនឹកឃើញពីដំណោះស្រាយ ដែលមានភាពច្នៃប្រឌិត។ល។

ប្រសិនបើយល់ថាសមរម្យមានប្រយោជន៍ និងទទួលបានការអនុញ្ញាតពីគូភាគីសន្ធានការី អាចឱ្យភាគីជួបគ្នាម្តងទៀត បន្ទាប់មកបំបែកទៅបន្ទប់ឯកជនរៀងៗខ្លួន រួចជួបគ្នាម្តងទៀតសារចុះសារឡើង។

ចំណែកឯដំណាក់កាលចរចា សន្ធានការីត្រូវជួយគូភាគីក្នុងការរៀបចំដាក់ សំណើចំពោះគ្នាទៅវិញទៅមក។ ភាគីណាមួយអាចចាប់ផ្តើមដាក់សំណើសម្រាប់ដោះស្រាយវិវាទដំបូង។ ជានិច្ចកាល សំណើដំបូងអាចនឹងមិនមែនជាសំណើដែលប្រសើរអាចទទួលយក ដោយភាគីម្ខាងទៀតបានទេ សន្ធានការីត្រូវបន្តធ្វើការជាមួយគូភាគីពាក់ព័ន្ធនឹងការបង្កើតឬរៀបចំដោះស្រាយទៅវិញទៅមក ហើយប្រសិនបើដល់ដំណាក់កាលណាមួយជាប់គាំងប្រព្រឹត្តទៅមិនបាន សន្ធានការីអាចនឹងត្រូវត្រលប់ទៅដំណាក់ទី ៣(បី) ដែលជាដំណាក់កាលស្វែងរកចំណុចវិវាទ សិទ្ធិនិងប្រយោជន៍ម្តងទៀតក៏បាន។

ដំណាក់កាលបិទបញ្ចប់សន្ធានកម្ម ដំណាក់កាលនេះ ជាដំណាក់កាលចុងក្រោយនៃការចរចាតាមរយៈសន្ធានកម្ម ដែលអាច មានលទ្ធផលពីរ គឺភាគីឈានដល់ការសះជាឬមិនឈានដល់ការសះជា។ ប្រសិនបើមិនមានការសះជាទេ សន្ធានការីគួរនៅបន្តលើកទឹកចិត្តឱ្យភាគីបន្តពិចារណា អំពីលទ្ធភាពសះ ទោះជានៅក្រៅដំណើរការសន្ធានកម្មក៏ដោយ ហើយអាចសុំអនុញ្ញាតគូភាគី ដើម្បីទាក់ទងទៅពួកគេដើម្បីសាកសួរបន្ថែមអំពីលទ្ធភាពសះជា នាថ្ងៃអនាគត។ ប្រសិនបើសះជា សន្ធានការីត្រូវឱ្យគូភាគី ឬមេធាវីរបស់ពួកគេ រៀបចំកិច្ចសន្យាសះជា ដោយសន្ធានការីជួយពិនិត្យមើលដើម្បីធានាថា រាល់ចំណុចដែលព្រមព្រៀងត្រូវបានដាក់ចូល ហើយការតាក់តែងកិច្ចសន្យានោះ អាចអនុវត្តបានក្នុងជីវភាពជាក់ស្តែង។

## ១.៣.២. គុណសម្បត្តិនៃសន្ធានកម្ម

ការធ្វើសន្ធានកម្មក៏មានការផ្តល់នូវគុណសម្បត្តិមួយចំនួនដូចជា ផ្តល់នូវការរក្សាទំនាក់ទំនងល្អ ការរក្សាការសម្ងាត់បានខ្ពស់ ទាក់ទងនិងព័តមានផ្ទាល់ខ្លួនរវាងគូភាគីដូចជាក្នុងអាជីវកម្ម ឬពាណិជ្ជកម្ម។ បន្ថែម

ពីនេះសន្ធានកម្មមានលក្ខណៈបត់បែន លទ្ធផលទទួលពីការស្ម័គ្រចិត្តទាំងសងខាងមានភាពឆាប់រហ័ស និងចំណាយសោហ៊ុយតិច និងគ្មានការទទួលសំណូក។[15]

### ១.៣.៣. គុណវិបត្តិនៃសន្ធានកម្ម

ក្រៅពីគុណសម្បត្តិសន្ធានកម្មក៏មានគុណវិបត្តិដូចជា ការព្រមព្រៀងកើតឡើងពីគូភាគី ហេតុនេះភាគីណាក៏អាចបញ្ឈប់សន្ធានកម្មបានដែលជាការប៉ះពាល់ដល់ភាគីម្ខាងទៀត ដែលជាការប៉ះពាល់ដល់ការសម្ងាត់ដែលភាគីម្ខាងមានគំនិតមិនល្អ ឬបំណងចង់ដោះស្រាយបញ្ហា។

## ១.៤. ការផ្សះផ្សា

ការផ្សះផ្សា គឺជាវិធីទី៣ ដែលអ្នកផ្សះផ្សាជួបជាមួយនឹងភាគីជម្លោះដាច់ដោយឡែកពីគ្នា ការជួបដាច់ដោយឡែកនេះគឺខុសគ្នាពីការធ្វើសន្ធានកម្ម ដើម្បីព្យាយាមករកនូវការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ។[16]

ការផ្សះផ្សា គឺមានលក្ខណៈស្រដៀងគ្នានឹងសន្ធានកម្ម ហើយត្រូវបានគេប្រើជាញឹកញាប់ដែលជាមូលដ្ឋានគឺមានន័យដូចគ្នា។ ការផ្សះផ្សា និងសន្ធានកម្មគឺសំដៅទៅដល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយមានជំនួយពីភាគីទីបីឬតតិយជន ដែលដាក់អោយ អនុវត្តវិធានជាមូលដ្ឋានមួយ ស្នើជូនមតិ និងស្នើឡើងនូវដំណោះស្រាយ ប៉ុន្តែវិធាននេះមិនធ្វើសេចក្តីសម្រេចពី ជម្លោះនោះទេ។ បន្ទាប់ពីការចរចា ដែលនៅក្នុងនោះភាគីទីបីនាំភាគីវិវាទអោយជួបគ្នាដើម្បីដោះស្រាយបញ្ហា។ តួនាទីសំខាន់របស់សន្ធានការីគឺ ខិតខំប្រឹងប្រែងឲ្យភាគីវិវាទឈានទៅដល់ចំនុចព្រមព្រៀងគ្នា មួយដោយការបន្ថយនូវការដែលខ្វែងគំនិតគ្នា និងភាពតឹងតែងហើយបើកចំហអោយមានការប្រាស្រ័យទាក់ទង និងសំរួលអោយមានការផ្សះផ្សាជាបន្តទៅទៀត។

ភាគីត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដោយភាគីព្រមព្រៀងថានឹងប្រើវេទិការមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីមជ្ឈត្តការដែលបានចែងក្នុងកិច្ចសន្យា ឬក្នុងកិច្ចព្រមព្រៀងដោយឡែក។ មានន័យថា ក្នុងករណីដែលមានខចែងស្តីពីមជ្ឈត្តការដែលត្រូវបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចសន្យារបស់គូភាគី ឬបើគូភាគីព្រមព្រៀងធ្វើមជ្ឈត្តការនក្នុងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ

[15] មេធាវី ព្រុំ សាវតា អត្ថបទព្រឹត្តិបត្រមេធាវី ទំ.១៣។

[16] ឯកសារស្រាវជ្រាវ គណៈកម្មការទី៦ ទទួលបន្ទុកនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់លោកស្រី ស៊ូ សោភា និងកញ្ញា ទិត្យ ស៊ីដែត។

ដាច់ដោយឡែកមួយពីកិច្ចសន្យា នោះវិវាទពាណិជ្ជកម្មត្រូវតែដោះស្រាយតាមមជ្ឈត្តការ។ កិច្ចព្រមព្រៀងចាំបាច់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែលក្ខខណ្ឌតម្រូវនេះអាចបំពេញបាន ដោយការសរសេរលិខិតឆ្លើយតបគ្នាទៅវិញទៅមកដែលបង្ហាញឱ្យឃើញពីឆន្ទៈទទួលយកការធ្វើមជ្ឈត្តការ។

## ១.៤.១. នីតិវិធីនៃការផ្សះផ្សា

នៅក្នុងនីតិវិធីនៃការផ្សះផ្សា ភាគីដែលចង់ចាប់ផ្តើមការផ្សះផ្សាដោយធ្វើលិខិតជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀត ដើម្បីបើកដំណើរការផ្សះផ្សា។ បើសិនជាភាគីម្ខាងទៀតមិនយល់ព្រមឬបដិសេធនូវការអញ្ជើញ ដែលភាគីម្ខាងបានលើកឡើង នោះការផ្សះផ្សាមិនប្រព្រឹត្តទៅទេប៉ុន្តែប្រសិនបើភាគីដែលផ្តួចផ្តើមការផ្សះផ្សាមិនបានទទួលយក ចម្លើយតបក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃផ្ញើលិខិតអញ្ជើញមក ឬក្នុងរយៈពេលផ្សេងទៀតដូចមានបញ្ជាក់នៅ ក្នុងលិខិតអញ្ជើញ ចាត់ទុកថា ភាគីនោះជាការបដិសេធការអញ្ជើញដើម្បីផ្សះផ្សា។ នៅក្នុងដំណើការផ្សះផ្សា អ្នកផ្សះផ្សាគឺជាអ្នកជួយភាគីវិវាទ ដើម្បីជ្រើសរើសដំណោះស្រាយវិវាទប្រកប ទៅដោយភាពល្អប្រសើរសម្រាប់ភាគីទាំងសងខាង។ អ្នកផ្សះផ្សាធ្វើយ៉ាងណា ឱ្យការដោះស្រាយវិវាទទន់ភ្លន់ ទៅតាមកាលៈទេសៈ ដែលអាចធ្វើឱ្យភាគីនៃវិវាទទទួលយកបាន។ ចំពោះរយៈពេលនៃការផ្សះផ្សា គឺចំណាយពេលខ្លី ប៉ុន្តែសោហ៊ុយចំណាយលើថ្លៃសេវាផ្សះផ្សាជាបន្ទុករបស់ភាគីទៅតាមការកំណត់របស់អ្នកផ្សះផ្សា។

## ១.៤.២. គុណសម្បត្តិនៃការផ្សះផ្សា

ការផ្សះផ្សាក៏មានគុណសម្បត្តិដូចក្នុងការផ្សះផ្សានៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានការរីកចម្រើនហើយកំពុងពេញនិយមដោយបានផ្តល់នូវគុណសម្បត្តិដូចជា ចំណាយថវិកាតិច ចំណេញពេលវេលា និងមានភាពទន់ភ្លន់ មានលក្ខណៈបត់បែន សំរាប់ការដោះស្រាយវិវាទផ្តល់សិទ្ធិដល់ភាគីក្នុងការសម្រេចចិត្តដោះស្រាយឬដកខ្លួនចេញ និងជួយរក្សាទំនាក់ទំនាក់ល្អរវាងភាគីវិវាទ។

## ១.៤.៣. គុណវិបត្តិនៃការផ្សះផ្សា

បន្ទាប់ពីគុណសម្បត្តិ យើងគួរស្វែងយល់ពីគុណវិបត្តិផងដែរ អ្នកផ្សះផ្សាអាចនិងយល់ខុស អំពីខ្លឹមសារដែលភាគីចង់បង្ហាញនៅពេលផ្សះផ្សានិងលាតត្រដាងព័ត៌មានផ្ទាល់របស់ភាគីហើយភាគីអាចមានការលាក់បាំង ព័ត៌មានផ្ទាល់ខ្លួនទៅភាគីម្ខាងទៀតបាន។

# ជំពូកទី២

# ការចាប់ផ្តើមនៃមជ្ឈត្ថការ

# ផ្នែកពាណិជ្ជកម្មនៅកម្ពុជា

# ជំពូកទី២

# ការចាប់ផ្តើមមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

## ២.១. សញ្ញាណទូទៅនៃមជ្ឈត្តការ

### ២.១.១. និយមន័យមជ្ឈត្តការ និងប្រវត្តិនៃមជ្ឈត្តការ

មជ្ឈត្តការ គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។[17] នេះមានន័យថាមជ្ឈត្តការ ជាមធ្យោបាយដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ដែលហៅថា ADR ចម្បងទីបីបន្ទាប់ពីនីតិវិធីចរចា (Negotiation) និងសន្ធានកម្ម (Mediation)។ គូភាគីអាចធ្វើការរំលងនីតិវិធីចរចា និងសន្ធានកម្ម បើគូភាគីបានព្រមព្រៀងធ្វើកិច្ចសន្យាដោយ ធ្វើការយកនីតិវិធីមជ្ឈត្តការមកដោះស្រាយ។ យន្តការនេះរក្សាការសម្ងាត់ ហើយអំណោយផលដល់ភាគីក្នុងការជ្រើសរើស ភាសា ទីកន្លែង មជ្ឈត្តករ វិធាន និងច្បាប់សម្រាប់ដោះស្រាយវិវាទរបស់ខ្លួនដោយផ្អែកលើឆន្ទៈសេរី។

នៅក្នុងមជ្ឈត្តការ គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយហៅថា"**មជ្ឈត្តករ**"។[18] "**វេទិកាមជ្ឈត្តកម្ម**" គឺជាមជ្ឈត្តករមួយរូបឬមួយក្រុម[19] ឬវេទិកាមជ្ឈត្តកម្មគឺជា វេទិកាដែលត្រូវបានបង្កើតឡើងដោយមជ្ឈត្តករមួយរូបឬមួយក្រុម[20] ហើយវេទិកាមជ្ឈត្តការធ្វើការពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយ ហៅថា "**មជ្ឈត្តវិនិច្ឆ័យ**"។

ប្រវត្តិនៃមជ្ឈត្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មទំនើបត្រូវបាន បង្កើតឡើងជាលើកដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគមជ្ឈិមសម័យ (the Dark Age) យោងតាមចំណាររបស់ក្រិចសម័យបុរាណ (Ancient Greece) និងនៅក្នុងព្រះគម្ពីរប៊ីប្លី (Bible) របស់សាសនាគ្រិស្ត។ នាសម័យនោះ ពាណិជ្ជករធ្វើដំណើរដ៏ឆ្ងាយដើម្បីទៅធ្វើជំនួញនៅកន្លែង។

វិវាទនៅពេលនោះ តុលាការអចិន្ត្រៃយ៍មិនអាចដោះស្រាយវិវាទទាំងនោះឱ្យបានឆាប់រហ័សឡើយ ព្រមទាំងគ្មានចំណេះដឹងនិងយុទ្ធសាស្ត្រអំពីបទដ្ឋានឧស្សាហកម្មរបស់អ្នកជំនួញឡើយ។

ដោយសារបទដ្ឋានឧស្សាហកម្មទាំងនេះគឺជាចំណុចស្នូល ទើបត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលទំនាក់ទំនងពាណិជ្ជកម្ម ក្នុងចំណោមគូភាគីដែលមកពីប្រទេស និងវប្បធម៌ផ្សេងៗគ្នា។ ដោយសមត្ថកិច្ចរបស់

[17] មាត្រា ២ ចំណុច (ក) ច្បាប់ស្តីពីមជ្ឈត្តការ ២០០៦។

[18] ប្រការ ២៥ វិធានស្តីពីមជ្ឈត្តការ ២០២១។

[19] មាត្រា ២ ចំណុច (ខ) ច្បាប់ស្តីពីមជ្ឈត្តការ ២០០៦។

[20] ប្រការ ១ វិធានស្តីពីមជ្ឈត្តការ ២០២១។

តុលាការនៅមានកម្រិត ពាណិជ្ជករបានបង្កើតវេទិកាធ្វើមជ្ឈត្តកការជាឯកជន ដែលអាចដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ហើយដែលជាញឹកញាប់តែងប្រើប្រាស់អ្នកជំនាញឧស្សាហកម្ម។[21]

នៅកំឡុងសតវត្សរ៍ទី១៧ និងទី១៨ និគមជនអង់គ្លេស ផ្លាស់ទីលំនៅទៅទ្វីបអាមេរិកពួកគេបាននាំមកជាមួយខ្លួននូវបែបផែនមជ្ឈត្តការទាំងនេះផង។ ជាលទ្ធផល មជ្ឈត្តការបានដើរតួនាទីសំខាន់នៅក្នុងដំណោះស្រាយ វិវាទផ្នែកពាណិជ្ជកម្មនៅក្នុងទឹកដីអាណានិគមអង់គ្លេសក្នុងទ្វីបអាមេរិក។[22] នៅក្នុងឆ្នាំ១៧៦៨ ស្ថាប័នមជ្ឈត្តការអចិន្ត្រៃយ៍ដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយសភាពាណិជ្ជកម្មក្រុងញូវយ៉ក (NYCC)។[23] បន្ថែមពីនេះ ប្រធានាធិបតីទីមួយរបស់អាមេរិក គឺលោក ចច វ៉ាស៊ីងតុន (George Washington) បានបញ្ចូលខចែងស្តីពីមជ្ឈត្តការ នៅក្នុងមរតកសាស្រ្តរបស់គាត់ទៀតផង ដើម្បីគ្រប់គ្រងវិវាទក្នុងចំណោមអត្តគាហកទាំងឡាយ។[24] ទោះជាយ៉ាងនោះក្តី នៅសម័យនោះ មជ្ឈត្តវិនិច្ឆ័យមិនអាចអនុវត្តដោយតុលាការបានឡើយ នៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាក្នុងបណ្តាប្រទេសមួយចំនួនទៀត ដែលជាហេតុតាំងពីពេលនោះមក ទើបគេរក្សាការធ្វើមជ្ឈត្តការនេះឱ្យស្ថិតនៅខាងក្រៅប្រព័ន្ធតុលាការជាផ្លូវការ។

ដោយហេតុថាសំណុំរឿងក្តីដែលត្រូវធ្វើការដោះស្រាយចាប់ផ្តើមកើនឡើង នៅសតវត្សរ៍ទី២០តុលាការនៅប្រទេសជាច្រើនបានចាប់ផ្តើមទទួលយកមជ្ឈត្តការ ជាវិធីសាស្ត្រស្របច្បាប់មួយក្នុងដំណោះស្រាយវិវាទ។ ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធ ឆ្នាំ១៩២៥ (FAA) ប្រទេសសហរដ្ឋអាមេរិកបានផ្តល់សុពលភាពដល់ខចែងស្តីពីមជ្ឈត្តការ នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មឱ្យធ្វើការអនុវត្តបាន។[25]

ការអនុវត្តតាមយ៉ាងឆាប់រហ័សនៃប្រទេសផ្សេងៗ នាំឱ្យវិធានក្នុងការធ្វើមជ្ឈត្តការមានការកើនឡើងយ៉ាងឆាប់រហ័សនៅពាសពេញពិភពលោកទាំងមូល។ សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស ICC បានបង្កើតតុលាការមជ្ឈត្តការអន្តរជាតិក្នុងឆ្នាំ១៩២៣ ដែលបានក្លាយជាវេទិកាធ្វើមជ្ឈត្តការដែលល្បីល្បាញបំផុតមួយនៅក្នុងពិភពលោក (TOOLS)។[26]

[21] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៨១ បោះពុម្ព ឆ្នាំ ២០០៩។

[22] Susan Patterson, Grant Seabolt, Essentials of Alternative Dispute Resolution (បោះពុម្ពលើកទី២ ឆ្នាំ ២០០១)។

[23] Steven C. Bennett, Arbitration: Essential Concepts (បោះពុម្ព ឆ្នាំ ២០០២)។

[24] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៨១ បោះពុម្ព ឆ្នាំ ២០០៩។

[25] គេហទំព័រ Cornell Law School https://www.law.cornell.edu/uscode/text/9/9 (ចូលទស្សនាចុងក្រោយ ១៦ សីហា ២០២៣)

[26] គេហទំព័រ សភាពាណិជ្ជកម្មអន្តរជាតិ មាននៅ http://www.iccwbo.org/policy/arbitration/id2882/index.html (ចូលទស្សនាចុងក្រោយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣)។

វេទិកាធ្វើមជ្ឈត្តកាសំខាន់ផ្សេងៗទៀតរួមមាន សមាគមន៍មជ្ឈត្តការអាមេរិកទីក្រុងញូវយ៉ក (NYIAC) និងតុលាការមជ្ឈត្តការអន្តរជាតិទីក្រុងឡុងដ៍ (LCIA)។[27] បច្ចុប្បន្ននេះ វេទិកានៅអាស៊ីដ៏ធំបំផុតចំនួនបី រួមមាន គណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន (CIETAC) មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិទីក្រុងហុងកុង (HKIAC) និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី (SIAC)។ ហើយក៏មានវេទិកាធ្វើមជ្ឈត្តការផ្សេងៗទៀតនៅក្នុងប្រទេសជប៉ុន ថៃ វៀតណាម ម៉ាឡេស៊ី តៃវ៉ាន់ ឥណ្ឌា និងឥណ្ឌូនេស៊ីផងដែរ។[28] ប្រទេសកម្ពុជា បានដាក់បញ្ចូលមជ្ឈមណ្ឌលមជ្ឈត្តការជាតិថ្មី របស់ខ្លួននៅក្នុងបញ្ជីនេះដែរ។

## ២.១.២. ការបង្កើតមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

កម្ពុជា មានប្រព័ន្ធដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មតាំងពីយូរលង់មកម្លឹង គិតចាប់តាំងពីសម័យសង្គមរាស្ត្រនិយម។ ការបង្កើត មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហៅកាត់ថា ម.ជ.ម.[29] គឺដើម្បីសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការស្ម័គ្រចិត្ត របស់ភាគីវិវាទដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច។[30] ម.ជ.ម. ត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។ អនុលោមទៅតាមច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១០ ស្ដីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៤ អនក្រ.បក។

នៅឆ្នាំ ២០២១ ដោយយោងតាមរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម **លោកជំទាវ ចម និមល** បានឱ្យដឹងថាវិនិយោគិនបានបញ្ជូនពាក្យបណ្ដឹងចំនួន ២៧ (ម្ភៃប្រាំពីរ) ករណីទាក់ទងនឹងវិវាទពាណិជ្ជកម្ម ទៅកាន់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[31]

---

[27] គេហទំព័រ តុលាការមជ្ឈត្តការអន្តរជាតិក្រុងឡុងដ៍ មាននៅ http://www.lcia-arbitration.com/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២៣)។

[28] មេធាវីស៊្រីន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA មជ្ឈមណ្ឌលជាតិផ្នែកពាណិជ្ជកម្មកម្ពុជា ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៨១ បោះពុម្ព ឆ្នាំ២០០៩។

[29] ប្រការ ១ វិធានស្ដីពីមជ្ឈត្តការ ២០២១។

[30] ច្បាប់ស្ដីពីមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម ២០០៦។

[31] គេហទំព័រ NCAC Trade Disputes Reach 27: Official https://opendevelopmentcambodia.net/km/news/ncac-trade-disputes-reach-27-official/#!/story=post-152764 (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣)។

## ២.១.៣. គុណសម្បត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម

ក្នុងប្រព័ន្ធមជ្ឈត្តការ មានការប្រើប្រាស់ចំណាយតិចជាងបើធៀបទៅនឹងការជ្រើសរើសបណ្ដឹងទៅតុលាការ ពីព្រោះតែមជ្ឈត្តការ មានលក្ខណៈរលូនជាងវិធានរបស់តុលាការ។

វេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ ត្រូវខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យដំណើរការមជ្ឈត្តការប្រព្រឹត្តទៅដោយយុត្តិធម៌ ឆាប់រហ័ស មានប្រសិទ្ធភាព ចំណាយអស់តិចនិងមិនត្រូវបង្កឱ្យមានការពន្យារពេលដែលមិនចាំបាច់ណាមួយឡើយ។[32]

ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការមានលក្ខណៈ ឆាប់រហ័ស ដោយពុំមានការពន្យាពេលដោយមានការកំណត់រយៈពេលច្បាស់លាស់ដោយមានការកំណត់ពីមជ្ឈត្តករ។ ផ្ទុយមកវិញ តាមរយៈដំណើរការបណ្ដឹងតុលាការ គូភាគីអាចប្ដឹងឧបាស្រ័យយ៉ាងហោចណាស់ម្ដង ហើយជួនកាលច្រើនដងទៀតផង។ លើសពីនេះទៀត ប្រព័ន្ធតុលាការមានរឿងក្ដីដែលរងចាំ ការដោះស្រាយយ៉ាងច្រើន ដែលបង្ខំឱ្យគូភាគីរង់ចាំការជំនុំជម្រះយ៉ាងយូរ។

នេះគឺជាគុណសម្បត្តិដ៏ធំសម្រាប់ដោះស្រាយវិវាទអន្តរជាតិ ដោយសារតែគ្មានប្រព័ន្ធដាក់ឱ្យអនុវត្តជាអន្តរជាតិស្រដៀងគ្នានេះ សម្រាប់សេចក្ដីសម្រេចរបស់តុលាការនៅឡើយ ការដាក់ឱ្យអនុវត្តថ្នាក់ជាតិ ដោយហេតុថា ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួន តុលាការកម្ពុជាអាចដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយផ្ទាល់ ដំណោះស្រាយតាមការចរចា ឬសន្ធានកម្ម មិនអាចដាក់ឱ្យអនុវត្តបានដោយងាយស្រួលបែបនេះឡើយ។ ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិ ដោយអនុលោមតាមអនុសញ្ញាក្រុងញូវយ៉កស្ដីពីការទទួលស្គាល់ និងការដាក់ ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស អនុសញ្ញាក្រុងញូវយ៉ក (NYC) ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាផងដែរនោះ មជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងនៅក្នុងប្រទេសហត្ថលេខី អាចដាក់ឱ្យអនុវត្តបានដោយស្វ័យប្រវត្តិនៅក្នុងបណ្ដាប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់។

ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានភាពបដិបក្ខតិចជាងដំណើរការបណ្ដឹងនៅតុលាការ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន។

ផ្ទុយពីដំណើរការបណ្ដឹងនៅតុលាការ ជាទូទៅមជ្ឈត្តការគឺជាដំណើរការជាឯកជន អាចជាគុណសម្បត្តិដ៏ធំ ប្រសិនបើគូភាគីមិនចង់ឱ្យសាធារណជនដឹងអំពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ។

[32] ប្រការ ៦ វិធានស្ដីពីមជ្ឈត្តការ ២០២១។

រាល់ការសម្ងាត់ឬឯកសារសម្ងាត់របស់គូភាគី មានធានាការសម្ងាត់។ ចំណែកការប្រជុំនុំក៏មានលក្ខណៈសម្ងាត់ផងដែរ។[33]

មជ្ឈត្តករ តែងអាចមានភាពបត់បែនក្នុងការដាក់ចេញនូវមធ្យោបាយ ដោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត ដែលតុលាការមិនអាចធ្វើបានឡើយ ដូចជាការសម្រេចឱ្យភាគីដែល ឈ្នះក្តីចេញថ្លៃមេធាវីជាដើម។

គូភាគីអាចជ្រើសរើសមជ្ឈត្តករដែលមានជំនាញនៅក្នុងវិស័យអាជីវកម្ម ដែលត្រូវនឹងវិស័យការងាររបស់គេ។

មជ្ឈត្តករដែលបំពេញតួនាទីក្រោមវិធាននេះ ត្រូវតែឯករាជ្យ និងអព្យាក្រឹត្យ និងមិនត្រូវបំពេញតួនាទីជាអ្នកគាំទ្រ ឬជាទីប្រឹក្សារបស់ភាគីវិវាទណាមួយឡើយ ចាប់ពីពេលដែលត្រូវបានតែងតាំងជាមជ្ឈត្តករ រហូតដល់បញ្ចប់ដំណើរការមជ្ឈត្តការ ទាំងមូលនៃសំណុំរឿង គឺនៅពេលដែលមជ្ឈត្តវិនិច្ឆ័យស្ថាពរត្រូវបានចេញ និងរួមបញ្ចូលទាំងអំឡុងពេលដែលត្រូវបានអនុញ្ញាត ឬកំណត់នៅក្នុងវិធាននេះ សម្រាប់ការស្នើសុំ ឬការចេញការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម[34]។

ជារឿយៗ គូភាគីអាចជ្រើសរើស នីតិវិធីស្មុគស្មាញ ដែលមើលទៅមានលក្ខណៈដូចជាដំណើរការបណ្តឹងនៅតុលាការ ឬនីតិវិធីដែលមានលក្ខណៈសាមញ្ញជាងនេះ។ គូវិវាទអាចមានសិទ្ធិជ្រើសរើសមជ្ឈត្តករថ្មីបានប្រសិនបើខ្លួនមិនពេញចិត្ត។[35]

## ២.១.៤. គុណវិបត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម

បើទោះបីជាមជ្ឈត្តការ មានការចំណាយទាបជាងដំណើរការកាត់ក្តីដោយតុលាការក៏ដោយ ក៏មជ្ឈត្តការនៅតែអាចមានតម្លៃថ្លៃដដែល។ គូភាគីត្រូវបង់ថ្លៃសម្រាប់ពេលវេលារបស់មជ្ឈត្តករ បន្ទប់សវនាការ ថ្លៃវេទិកាធ្វើមជ្ឈត្តការ ព្រមទាំងថ្លៃដំណើរការកាត់ក្តីធម្មតាផ្សេងៗទៀតដូចជា ថ្លៃជួលមេធាវី និងថ្លៃចំណាយ ដែលពាក់ព័ន្ធដទៃទៀត។ ដោយហេតុថាមជ្ឈត្តវិនិច្ឆ័យមិនមែនបានមកពីការការចរចា និងការស្រុះស្រួលគ្នា ហេតុនេះគឺអាចមានលទ្ធភាពច្រើននៃការមិនអនុលោមតាមមជ្ឈត្តវិនិច្ឆ័យ។ ហេតុដូច្នេះហើយ គូភាគីអាច ត្រូវចំណាយបន្ថែមកាន់តែច្រើនលើថ្លៃមេធាវី ដែលចាំបាច់ដើម្បីបន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។ ការរក្សាទំនាក់ទំនងមានភាពប្រសើរជាងបណ្តឹងតុលាការក៏ដោយ ក៏ទម្រង់នៃដំណោះស្រាយវិវាទផ្សេង គឺការចរចា និងសន្ធានកម្ម កាន់តែ

[33] ប្រការ ៦៦ វិធានស្តីពីមជ្ឈត្តការ ២០២១។

[34] ប្រការ ២៧ វិធានស្តីពីមជ្ឈត្តការ ២០២១។

[35] ប្រការ ២៩ វិធានស្តីពីមជ្ឈត្តការ ២០២១។

មាន ប្រសិទ្ធភាពនៅក្នុងការរក្សាទំនាក់ទំនងរបស់គូភាគី។ លទ្ធផលនឹងមិនមានភាពប្រាកដប្រជា ប្រសិនបើមជ្ឈត្តករបំពេញតួនាទីជាអ្នកជួយសម្រុះសម្រួលពួកគេនឹងវិនិច្ឆ័យរឿងក្តី ដោយផ្អែកលើគោលការណ៍សមភាព មិនចាំបាច់មានច្បាប់សំរាប់គ្រប់គ្រងឡើយ។ [36]

## ២.១.៥. លក្ខណៈទម្រង់នៃម.ជ.ម.

### ២.១.៥.១. ក្រុមប្រឹក្សាប្រតិបត្តិ

នាពេលបច្ចុប្បន្ននេះ **លោក សាន គីរី** គឺជាប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម.។[37] បន្ថែមពីនេះក្រុមប្រឹក្សាប្រតិបត្តិនៃ ម.ជ.ម. ត្រូវបានជ្រើសតាំងដោយមហាសន្និបាតនៅក្នុង ម.ជ.ម. ជារៀងរាល់៣ (បី) ឆ្នាំម្តង។[38]

### ២.១.៥.២. គណៈកម្មាធិការ

ប្រធានគណៈកម្មាធិការត្រូវតែជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ។ គណៈកម្មាធិការនីមួយៗ ត្រូវមានសមាជិក ៣ (បី) រូប និងសមាជិកបម្រុង ៣ (បី) រូប លើកលែងតែមានការសម្រេចផ្សេងដោយក្រុមប្រឹក្សាប្រតិបត្តិ។ អាណត្តិរបស់សមាជិកនីមួយៗមានរយៈពេល ៣ (បី) ឆ្នាំ ហើយមិនលើសពី ០២ (ពីរ) អាណត្តិជាប់គ្នានៅក្នុងគណៈកម្មាធិការនីមួយៗ។[39]

គណៈកម្មាធិការ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីអនុវត្តការងារ ឬគម្រោងជាក់លាក់ណាមួយ។ សមាជិក និងសមាជិកបម្រុងរបស់គណៈកម្មាធិការ អាចធ្វើជាសមាជិកក្នុងគណៈកម្មាធិការតែមួយប៉ុណ្ណោះ។ សមាជិកគណៈកម្មាធិការមានកាតព្វកិច្ចបង្ហាញទៅក្រុមប្រឹក្សាប្រតិបត្តិ អំពីទំនាស់ផលប្រយោជន៍នានា ដែលអាចមានពាក់ព័ន្ធនឹងការបំពេញតួនាទី និងមុខងាររបស់ខ្លួន ក្នុងគណៈកម្មាធិការ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងដោយសំឡេងភាគច្រើននៃសមាជិកទាំងអស់របស់ខ្លួន។[40]

---

[36] មេធាវីស្ទើរិន អ៊ែម អូស្ទើរមីឡឺរី សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA មជ្ឈមណ្ឌលជាតិផ្នែកពាណិជ្ជកម្មកម្ពុជា ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.៨០ បោះពុម្ព ឆ្នាំ ២០០៩។

[37] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "ក្រុមប្រឹក្សាប្រតិបត្តិ" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣)។

[38] ដដែល។

[39] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "គណៈកម្មាធិការ" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣)។

[40] ដដែល។

គណៈកម្មាធិការមានចំនួន ៤ (បួន) គឺគណៈកម្មាធិការតែងតាំង និងនីតិវិធី គណៈកម្មាធិការវិន័យ គណៈកម្មាធិការអប់រំនិងបណ្តុះបណ្តាល និងគណៈកម្មាធិការសមាជិកភាព។[41]

### ២.១.៥.៣. អគ្គលេខាធិការដ្ឋាន

ក្រុមការងារអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. ប្រមូលផ្តុំដោយបុគ្គលដែលសកម្ម មានឆន្ទៈខ្ពស់ក្នុងការបំពេញការងារ ប្រកបដោយចំណេះដឹង ជំនាញច្បាស់លាស់ ព្រមទាំងសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេសជាច្រើនផងដែរ។ តួនាទីអគ្គលេខាធិការដ្ឋាន រួមមានការគ្រប់គ្រងសំណុំរឿងមជ្ឈត្តកម្ម កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ទំនាក់ទំនងសាធារណៈ និងការផ្តល់ការបណ្តុះបណ្តាល។[42]

### ២.១.៥.៤. សមាជិកភាពរបស់ ម.ជ.ម.

ជារួមមកសមាជិកភាពរបស់ ម.ជ.ម. មានបួនប្រភេទគឺ សមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្ត សមាជិកគាំទ្រជានីតិបុគ្គល។

សមាជិកជាមជ្ឈត្តករសំដៅលើរូបវន្តបុគ្គលក្នុងស្រុក និងបរទេស ដែលបានបំពេញលក្ខណសម្បត្តិជាមជ្ឈត្តករ និងត្រូវបានចុះបញ្ជីសមាជិកជាមជ្ឈត្តកររបស់ ម.ជ.ម.។[43]

ចំណែកសមាជិកជានីតិបុគ្គលនីមួយៗ ត្រូវតែងតាំងរូបវន្តបុគ្គលមួយរូបឱ្យធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពនានាក្នុងនាមជាសមាជិកជានីតិបុគ្គលសម្រាប់គ្រប់កិច្ចការទាំងអស់ពាក់ព័ន្ធនឹង ម.ជ.ម. រួមបញ្ចូលទាំងការតំណាងសមាជិកជានីតិបុគ្គលនៅក្នុងក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងគណៈកម្មាធិការនានា ប្រសិនបើសមាជិកជានីតិបុគ្គលនោះត្រូវបានតែងតាំងតាមនីតិវិធីកំណត់។ ដើម្បីជៀសវាងការភ័ន្តច្រឡំ អ្នកតំណាងមិនត្រូវបានចាត់ទុកជាសមាជិករបស់ ម.ជ.ម. ឡើយ។[44]

លក្ខណសម្បត្តិសម្រាប់ការចុះបញ្ជីជាសមាជិករួមមាននីតិបុគ្គល ត្រូវតែស្ថិតក្នុងប្រភេទណាមួយនៃអង្គភាពដូចជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សភាពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឬរាល់សមាគមន៍ដែលប្រមូលផ្តុំសមាជិកជាពាណិជ្ជករ ឧស្សាហករ អាជីវករ ឬសេវាករ។

---

[41] ដដែល។

[42] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "អគ្គលេខាធិការដ្ឋាន" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣)។

[43] ប្រការ១១ បទបញ្ជាផ្ទៃក្នុង។

[44] ដដែល។

សមាជិកគាំទ្រជារូបវន្តបុគ្គល សំដៅទៅលើរូបវន្តបុគ្គលដែលមានចំណាប់អារម្មណ៍ទៅលើវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប៉ុន្តែមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាមជ្ឈត្តករ ឬអ្នកដែលមានបំណងចង់ស្វែងយល់បន្ថែមអំពី ម.ជ.ម.។ លក្ខណសម្បត្តិដើម្បីចុះបញ្ជីជាសមាជិករួមមានដូចជា មានអាយុយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ បានចុះឈ្មោះជានិស្សិតនៃមហាវិទ្យាល័យណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ឬមានបរិញ្ញាបត្រជំនាញណាមួយដែលចេញដោយមហាវិទ្យាល័យណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស។[45]

សមាជិកគាំទ្រជានីតិបុគ្គល សំដៅទៅលើនីតិបុគ្គលដែលមានចំណាប់អារម្មណ៍ទៅលើវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងត្រូវបានចុះឈ្មោះជាសមាជិកនីតិបុគ្គលនៅ ម.ជ.ម.។[46]

នីតិបុគ្គល ត្រូវមានឆន្ទៈក្នុងការចូលរួមចំណែកយ៉ាងសកម្មនៅក្នុងកម្មវត្ថុ និងសកម្មភាពរបស់ ម.ជ.ម. ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្ត ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬស្ថាប័នបានសមត្ថកិច្ច និងមានប្រព័ន្ធអភិបាលកិច្ចច្បាស់លាស់។

សមាជិកគាំទ្រជានីតិបុគ្គលនឹងទទួលបានព័ត៌មានដែលចែកចាយដោយ ម.ជ.ម. ចូលរួមកម្មវិធីនានាដែលរៀបចំដោយ ម.ជ.ម. ជាមួយតម្លៃចុះឈ្មោះចូលរួមពិសេស និងមានសិទ្ធិចូលរួមក្នុងការបណ្តុះបណ្តាលនានាដែលរៀបចំដោយ ម.ជ.ម. ក្រោមការចាត់ចែងជាក់លាក់ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ សមាជិកគាំទ្រជានីតិបុគ្គល និងសមាជិកគាំទ្រជារូបវន្តបុគ្គល ក៏នឹងមានឈ្មោះក្នុងបញ្ជី របស់ ម.ជ.ម.។[47]

## ២.២. មជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

### ២.២.១. គោលបំណងនៃការស្ថាបនាមជ្ឈត្តការនៅកម្ពុជា

ក្នុងរយៈពេលកន្លងមកនេះ កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងត្រូវបានធ្វើឡើង ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្ស កសាងសហគមន៍មជ្ឈត្តការមួយដែលរឹងមាំ ផ្សារភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍អន្តរជាតិ និងធានានូវការអភិវឌ្ឍន៍ និងប្រតិបត្តិការប្រកបដោយចីរភាពរបស់មជ្ឈមណ្ឌល។[48]

[45] ប្រការ ១១ បទបញ្ជាផ្ទៃក្នុង។

[46] ដដែល។

[47] ដដែល។

[48] ប្រការ ៣ បទបញ្ជាផ្ទៃក្នុង។

### ២.២.២. ចក្ខុវិស័យ និងបេសកកម្មរបស់ម.ជ.ម.

ចក្ខុវិស័យដែលក្នុងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានតួនាទីសម្របសម្រួលដល់ការដោះស្រាយវិវាទពាណិជ្ជកម្មភាពដោយមិនមានការលំអៀង និងចំណាយពេលឆាប់រហ័ស ស្របទៅតាមឆន្ទៈរបស់គូភាគីវិវាទ និងការការពារសិទ្ធិ ហើយនិងផលប្រយោជន៍ស្របទៅតាមច្បាប់របស់ពួកគេ ក្នុងគោលបំណងលើកកម្ពស់ក្នុងការអភិវឌ្ឍរបស់សេដ្ឋកិច្ចឱ្យបានរឹងមាំ។[49]

បេសកកម្មធ្វើឱ្យអ្នកប្រើប្រាស់ឬអ្នកទទួលនូវសេវាកម្មប្រកបដោយប្រសិទ្ធិភាពខ្ពស់ តាមរយៈការប្រើប្រាស់សេវាកម្មល្អ គ្រឿងបរិក្ខារ និងឧបករណ៍បច្ចេកវិទ្យាទំនើប ព្រមទាំងការអនុវត្តបទបញ្ជា និងវិធានប្រកបដោយប្រសិទ្ធភាពខ្ពស់។ បង្កើនការយល់ដឹងអំពីមជ្ឈត្តកម្មតាមរយៈការសហការជាមួយភាគីពាក់ព័ន្ធទាំងអស់។[50]

### ២.២.៣. មជ្ឈត្តករនៅម.ជ.ម.

គណៈកម្មការរៀបចំនិងជ្រើសរើសមជ្ឈត្តករដំបូង ត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ២២៣ MOC/SM ២០០៩ ចុះនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩។ ការជ្រើសរើសសមាជិកមជ្ឈត្តករជំនាន់ ដំបូងត្រូវបានជ្រើសរើសដោយគណៈកម្មាធិការជ្រើសរើសមជ្ឈត្តករ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១០។ ដើម្បីធានាបាននូវប្រសិទ្ធភាព និងការប្រាកដអំពីសមត្ថភាពវិជ្ជាជីវៈរបស់ មជ្ឈត្តករជំនាន់ដំបូងត្រូវបានឆ្លងកាត់នូវវគ្គបណ្ដុះបណ្ដាលជាច្រើនស្ដីពីជំនាញមជ្ឈត្តការ ព្រមទាំងច្បាប់ពាណិជ្ជកម្មដែលត្រូវបានរៀបចំឡើងដោយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលជាផ្នែកមួយនៃធនាគារពិភពលោក ដោយបានសហការជាមួយវិទ្យាស្ថានមជ្ឈត្តការសិង្ហបុរី។[51] បន្ទាប់ពីពេលដែលបានបញ្ចប់ការសិក្សាការបណ្ដុះបណ្ដាលអស់រយៈពេលពីរឆ្នាំរួច សិក្ខាកម្មដែលទទួលបានជោគជ័យចំនួន ៤៤ (សែសិបបួន) រូប ត្រូវបានចុះឈ្មោះជាមជ្ឈត្តករនៅក្នុងបញ្ជីរបស់ម.ជ.ម.។[52]

---

[49] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "ចក្ខុវិស័យ" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣)។

[50] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "បេសកកម្ម" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣)។

[51] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "មជ្ឈត្តករ" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០២៣)។

[52] ដដែល។

បច្ចុប្បន្ននេះមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម យើងមានមជ្ឈត្តករច្រើនជាង៦៨ (ហុកសិបប្រាំបី) រូប ដែលមានសញ្ជាតិផ្សេងៗគ្នានៅក្នុងបញ្ជីរបស់ ម.ជ.ម.។[53] ហើយនៅដើមឆ្នាំ២០២២ សន្ទានការីពាណិជ្ជកម្មថ្មីចំនួន ១៦ រូបត្រូវបានទទួលស្គាល់ដោយស្គាល់ដោយស្ថាប័នអន្តរជាតិផ្នែកសន្ទានកម្ម និងដោះស្រាយវិវាទពាណិជ្ជកម្មក្រៅតុលាការមជ្ឈមណ្ឌល។[54]

លក្ខណសម្បត្តិ ដើម្បីចុះបញ្ជីសមាជិកជាមជ្ឈត្តករួមមាន មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ដែលបញ្ចប់ពីមហាវិទ្យាល័យណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសបានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការ ដែលរៀបចំដោយ ម.ជ.ម. ឬវគ្គបណ្តុះបណ្តាលដែលរៀបចំដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម.បានប្រឡងជាប់ការប្រឡងដែលរៀបចំដោយ ម.ជ.ម. ឬដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម.។[55]

សមាជិកជាមជ្ឈត្តករមិនត្រូវជាមន្ត្រីរាជការ ឬស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ ឬតុលាការ។[56]

### ២.៣.២.១. ការដាក់បញ្ចូលមជ្ឈត្តករ

មជ្ឈត្តករដែលអាចត្រូវបានតែងតាំង ត្រូវបង្ហាញដោយមិនបង្អង់ដល់បុគ្គលទាំងឡាយ ដែលមកទាក់ទងអំពីលទ្ធភាពក្នុងការតែងតាំងខ្លួនជាមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម អំពីកាលៈទេសៈទាំងឡាយណាដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផលណាមួយពាក់ព័ន្ធនឹងឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់ខ្លួន។[57] នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវមានសមាសភាពមជ្ឈត្តករជាចំនួនសេស។ វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន ៣ (បី) រូប លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។[58]

---

[53] ប្រការ១១ បទបញ្ជាផ្ទៃក្នុង។

[54] គេហទំព័រ កម្ពុជាមានសន្ទានការីពាណិជ្ជកម្ម ១៦ រូបថ្មីត្រូវបានទទួលស្គាល់ ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម https://www.postkhmer.com/business/2022-03-10-1129-233105.html (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០២៣)។

[55] គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration/why-ncac/ "មជ្ឈត្តករ" (ចូលទស្សនាចុងក្រោយនៅ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣)។

[56] ដដែល។

[57] ប្រការ ២៧.២ វិធានស្តីពីមជ្ឈត្តការ ២០២១។

[58] ប្រការ២៤ វិធានស្តីពីមជ្ឈត្តការ ២០២១។

បន្ទាប់ពីត្រូវបានតែងតាំងហើយ មជ្ឈត្តករត្រូវប្រកាសបង្ហាញដោយ មិនបង្អង់អំពីកាលៈទេសៈទាំងឡាយណា ដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផល ណាមួយ ពាក់ព័ន្ធនឹងឯករាជ្យភាព ឬអព្យាក្រឹត្យភាពរបស់ខ្លួនដល់គូភាគីវិវាទ អគ្គលេខាធិការដ្ឋាន និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម។

ប្រសិនបើក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ កាលៈទេសៈថ្មីកើតមានឡើងបង្កឱ្យមានការសង្ស័យពាក់ព័ន្ធនឹងឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់មជ្ឈត្តករ មជ្ឈត្តកររូបនោះត្រូវប្រកាសបង្ហាញភ្លាមអំពីកាលៈទេសៈនោះ ដល់គូភាគីវិវាទ អគ្គលេខាធិការដ្ឋាន និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម។[59]

## ២.៣.២.២. លក្ខន្តិកៈរបស់មជ្ឈត្តករ

មជ្ឈត្តករដែលបំពេញតួនាទី ត្រូវតែឯករាជ្យ និងអព្យាក្រឹត្យ និងមិនត្រូវបំពេញតួនាទីជាអ្នកគាំទ្រ ឬជាទីប្រឹក្សារបស់ភាគីវិវាទណាមួយឡើយ ចាប់ពីពេលដែលត្រូវបានតែងតាំងជាមជ្ឈត្តករ រហូតដល់បញ្ចប់ដំណើរការមជ្ឈត្តការ ទាំងមូលនៃសំណុំរឿង គឺនៅពេលដែលមជ្ឈត្តវិនិច្ឆ័យស្ថាពរត្រូវបានចេញ និងរួមបញ្ចូលទាំងអំឡុងពេលដែលត្រូវបានអនុញ្ញាត ឬកំណត់នៅក្នុងវិធាននេះ សម្រាប់ការស្នើសុំ ឬការចេញការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម។ ប្រសិនបើមជ្ឈត្តករណាមួយពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុតាមផ្លូវច្បាប់ ឬមូលហេតុជាក់ស្តែងណាមួយ ឬដោយមូលហេតុណាមួយផ្សេងទៀត ខកខានក្នុងការបំពេញមុខងារដោយមិនមានការពន្យារពេលហួសហេតុ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ ប្រសិនបើមជ្ឈត្តករនោះដកខ្លួនពីមុខតំណែង ឬប្រសិនបើគូភាគីវិវាទព្រមព្រៀងបញ្ចប់អាណត្តិនោះ។ ការដកខ្លួន ឬការព្រមព្រៀងបញ្ចប់អាណត្តិនេះ មិនត្រូវបានចាត់ទុកជាការទទួលស្គាល់ចំពោះ សុពលភាពនៃមូលហេតុដែលនាំឱ្យមានការដកខ្លួននោះទេ។ ប្រសិនបើការមិនយល់ស្របគ្នានៅតែបន្តមានពាក់ព័ន្ធនឹងមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងនេះ ឬប្រសិនបើមជ្ឈត្តករណាម្នាក់ខកខានមិនបាន បំពេញអាណត្តិរបស់ខ្លួន ភាគីវិវាទណាមួយអាចដាក់សំណើទៅអគ្គលេខាធិការដ្ឋានសុំឱ្យគណៈកម្មាធិការតែងតាំង និងនីតិវិធីសម្រេចបញ្ចប់អាណត្តិរបស់មជ្ឈត្តកររូបនោះ។[60]

[59] ប្រការ ២៧.២ វិធានស្តីពីមជ្ឈត្តការ ២០២១។

[60] ប្រការ ២៩.១ វិធានស្តីពីមជ្ឈត្តការ ២០២១។

### ២.៣.២.៣. ការបញ្ចប់អាណត្តិរបស់មជ្ឈត្តករ

តាមសំណើរបស់ភាគីវិវាទណាមួយ ប្រសិនបើមជ្ឈត្តករណាមួយពុំអាចបំពេញមុខងាររបស់ខ្លួនបាន ដោយមូលហេតុ តាមផ្លូវច្បាប់ ឬមូលហេតុជាក់ស្តែងណាមួយ ឬដោយមូលហេតុណាមួយផ្សេងទៀត ខកខាន ក្នុងការបំពេញមុខងារដោយមិនមានការពន្យារពេលហួសហេតុ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ ប្រសិនបើមជ្ឈត្តករនោះដកខ្លួនពីមុខតំណែង ឬប្រសិនបើគូភាគីវិវាទព្រមព្រៀងបញ្ចប់អាណត្តិនោះ។[61] ការដកខ្លួន ឬការព្រមព្រៀងបញ្ចប់អាណត្តិនេះ មិនត្រូវបានចាត់ទុកជាការទទួលស្គាល់ចំពោះសុពលភាពនៃមូលហេតុដែល មានការដកខ្លួននោះទេ។[62] ប្រសិនបើការមិនយល់ស្របគ្នានៅតែបន្តមានពាក់ព័ន្ធនឹងមូលហេតុណាមួយ ក្នុង ចំណោមមូលហេតុទាំងនេះ ឬប្រសិនបើមជ្ឈត្តករណាម្នាក់យកមិនបាន បំពេញអាណត្តិរបស់ខ្លួន ភាគីណាមួយ អាចដាក់សុំទៅអគ្គលេខាធិការដ្ឋាន ឱ្យគណៈកម្មាធិការតែងតាំង និងនីតិវិធី សម្រេចបញ្ចប់អាណត្តិថ្មីមជ្ឈត្តករ រូបនោះ។[63]

មជ្ឈត្តករ ភាគីវិវាទម្ខាងទៀត និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្មអាច ផ្តល់យោបល់របស់ខ្លួន ឆ្លើយតបនឹងសំណើនោះទៅអគ្គលេខាធិការដ្ឋាន ក្នុងអំឡុង ពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួល សំណើនោះ។[64]

គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវសម្រេចលើសំណើសុំបញ្ចប់អាណត្តិ របស់មជ្ឈត្តករ ក្នុងអំឡុង ពេល១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលកំណត់សម្រាប់ផ្តល់យោបល់ឆ្លើយតបនឹងសំណើសុំ បញ្ចប់អាណត្តិរបស់មជ្ឈត្តករ។[65]

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី បដិសេធសំណើសុំនោះ មជ្ឈត្តកររូបនោះ ត្រូវបង្ហាញភារកិច្ចរបស់ខ្លួនជាបន្តទៅទៀត។ គណៈកម្មាធិការតែងតាំង និងនីតិវិធី យល់ស្របចំពោះសំណើនោះ អាណត្តិរបស់ មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃសេចក្តី ការដាក់មជ្ឈត្តករជំនួស ត្រូវ យកមកអនុវត្ត។[66] សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី មិនចាំបាច់បង្ហាញ ហេតុផល

61 ដដែល។

62 ដដែល។

63 ដដែល។

64 ប្រការ ២៩.២ វិធានស្តីពីមជ្ឈត្តការ ២០២១។

65 ប្រការ ២៩.៣ វិធានស្តីពីមជ្ឈត្តការ ២០២១។

66 ប្រការ ២៩.៣ វិធានស្តីពីមជ្ឈត្តការ ២០២១។

ឡើយ គឺជាសេចក្ដីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មអំពីសេចក្ដី សម្រេចរបស់គណៈកម្មាធិការតែងតាំងនិងជីតិវិធីនោះ។[67]

## ២.៣.២.៤. ការជំទាស់ដោយដាក់មជ្ឈត្តករជំនួស

មជ្ឈត្តករអាចត្រូវបានជំទាស់ ប្រសិនបើមានកាលៈទេសៈណាមួយបង្កឱ្យមាន ការសង្ស័យសមហេតុផលចំពោះឯករាជ្យភាព ឬអព្យាក្រឹត្យភាពរបស់មជ្ឈត្តករ។ មជ្ឈត្តករអាចត្រូវបានជំទាស់ផងដែរប្រសិនបើមជ្ឈត្តកររូបនោះ មិនមានលក្ខណសម្បត្តិដូចដែលបានព្រមព្រៀងដោយគូភាគីវិវាទ។[68] ភាគីវិវាទមួយអាចជំទាស់ទៅនឹងមជ្ឈត្តករ ដែលខ្លួនបានតែងតាំង ឬដែលខ្លួនបានចូលរួមក្នុងការតែងតាំង តែក្នុងករណីដែលភាគីវិវាទនោះបានដឹងអំពីមូលហេតុដើម្បីជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។[69]

គណៈកម្មាធិការតែងតាំងនិងនីតិវិធី ត្រូវសម្រេចលើការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានបានទទួលការតវ៉ាចំពោះការជំទាស់នឹងមជ្ឈត្តករ។[70] ប្រសិនបើគណៈកម្មាធិការតែងតាំងនិងនីតិវិធី បដិសេធការជំទាស់ មជ្ឈត្តករដែលត្រូវបានជំទាស់នោះត្រូវបន្តបំពេញតួនាទីរបស់ខ្លួនជាមជ្ឈត្តករតទៅទៀត។ តែប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធីយល់ស្រប ចំពោះការជំទាស់ អាណត្តិរបស់មជ្ឈត្តករដែលត្រូវបានជំទាស់នោះនឹងត្រូវបញ្ចប់ ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃសេចក្ដីសម្រេចនោះ។[71] អគ្គលេខាធិការដ្ឋាន ត្រូវជូនដំណឹងទៅគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មអំពីសេចក្ដីសម្រេចរបស់គណៈកម្មាធិការតែងតាំងនិងនីតិវិធីនោះ។[72]

ម្យ៉ាងវិញទៀត មជ្ឈត្តករអាចត្រូវបានដាក់ជំនួស នៅពេលមជ្ឈត្តករនោះទទួលមរណភាពដកខ្លួន ឬលាលែងពីតំណែង ឬនៅពេលបញ្ចប់អាណត្តិរបស់មជ្ឈត្តករណាម្នាក់ ដោយមូល ហេតុផ្សេងៗ។[73]

នៅក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ មានមជ្ឈត្តករណាម្នាក់ត្រូវដាក់ជំនួស ការតែងតាំងមជ្ឈត្តករជំនួសនោះត្រូវធ្វើឡើង ដោយត្រូវចាប់ផ្ដើមមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ក្រោយពីភាគីវិវាទដែលត្រូវតែងតាំងមជ្ឈត្តករជំនួស បានទទួលសេចក្ដីជូនដំណឹងអំពីការដាក់មជ្ឈត្តករជំនួស។ គ្មានភាគីវិវាទណាមួយ ត្រូវ

[67] ប្រការ ២៩.៤ វិធានស្ដីពីមជ្ឈត្តការ ២០២១។
[68] ប្រការ ២៨.១ វិធានស្ដីពីមជ្ឈត្តការ ២០២១។
[69] ដដែល។
[70] ប្រការ ២៨.៥ វិធានស្ដីពីមជ្ឈត្តការ ២០២១។
[71] ដដែល។
[72] ប្រការ ២៨.៦ វិធានស្ដីពីមជ្ឈត្តការ ២០២១។
[73] ប្រការ ៣០.១ វិធានស្ដីពីមជ្ឈត្តការ ២០២១។

បានរារាំងមិនឱ្យចូលរួមក្នុងការតែងតាំងមជ្ឈត្តករជំនួស ដោយមូលហេតុថាភាគីវិវាទនោះ ខកខានមិនបានចូលរួមពីដំបូងក្នុងការតែងតាំងមជ្ឈត្តករដែលនឹងត្រូវបានដាក់ជំនួសនោះទេ។[74]

តាមរយៈសំណើរបស់ភាគីវិវាទណាមួយទៅអគ្គលេខាធិការដ្ឋាន ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី កំណត់ថាដើម្បីធានាភាពឆាប់រហ័សដំណើរការមជ្ឈត្តការ គណៈកម្មាធិការតែងតាំងនិងនីតិវិធី អាចតែងតាំងមជ្ឈត្តករជំនួសណាម្នាក់ បន្ទាប់ពីបានទុកឱកាសឱ្យគូភាគីវិវាទ ព្រមទាំងមានការផ្តល់យោបល់ពីមជ្ឈត្តករផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្មរួចហើយ។[75]

[74] ប្រការ ៣០.២ វិធានស្តីពីមជ្ឈត្តការ ២០២១។

[75] ប្រការ ៣០.៣ វិធានស្តីពីមជ្ឈត្តការ ២០២១។

# ជំពូកទី៣

# ការដោះស្រាយវិវាទមជ្ឈត្តការ ផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជា

# ជំពូកទី៣

# ការដោះស្រាយវិវាទមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជា

## ៣.១. នីតិវិធីដោះស្រាយវិវាទដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

### ៣.១.១. ការប្រើប្រាស់ភាសា

នៅក្នុងនីតិវិធីមជ្ឈត្តការ ការការគិតគូរពីភាសាដែលនឹងត្រូវប្រើមានសារសំខាន់ណាស់ ចំពោះកិច្ចសន្យាដែលមានគូភាគីអន្តរជាតិ។ បើសិនជាគូភាគីមិនមែនជាគូភាគីអន្តរជាតិទេ ជាជាតិសាសន៍ខ្មែរដូចគ្នា ការប្រើប្រាស់អាចជាខ្មែរ ឬអង់គ្លេស។ គូភាគីនៃវិវាទមានសិទ្ធិពេញលេញក្នុងការព្រមព្រៀងជ្រើសរើសភាសាណាមួយដើម្បីធ្វើការដោះស្រាយ ប៉ុន្តែក្នុងករណីដែលមិនមានការព្រមព្រៀងគ្នានោះទេ វេទិកាមជ្ឈត្តកម្មជាអ្នកសម្រេចជំនួសស្របតាមកាលៈទេសៈដែលពាក់ព័ន្ធនានា ព្រមទាំងភាសានៃកិច្ចសន្យា។[76]

ការចំណាយការបកប្រែភាសា ឯកសារ និងសក្ខីកម្ម ដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ត្រូវបានបង្គាប់ដោយវេទិកាមជ្ឈត្តកម្មទៅលើភាគីណាមួយ ទៅជាទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាត្រឹមត្រូវនិងសមស្រប។[77] ជាទូទៅ គេប្រើភាសាអង់គ្លេស ឬបកពីភាសាណាមួយមកអង់គ្លេសជាដើម។[78]

ចំពោះភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់ចេញដោយវេទិការមជ្ឈត្តកម្មត្រូវតែជាភាសាខ្មែរ ឬភាសាអង់គ្លេស ទោះបីជាភាគីវិវាទបានជ្រើសរើសភាសាផ្សេងក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេសក៏ដោយ។[79]

### ៣.១.២. ទីកន្លែងធ្វើមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ការធ្វើសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មអំពីទីកន្លែងធ្វើទាំងអស់ គឺត្រូវធ្វើឡើងនៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា តាមខចែងសាមញ្ញស្តីពីទីកន្លែងមជ្ឈត្តការ លុះត្រាតែមានការព្រមព្រៀងខុសពីនេះ ឬដោយប្រការណាមួយនៃសំណុំអង្គហេតុដែលមានលក្ខណៈសមស្របជាងដោយវេទិកាមជ្ឈត្តកម្ម។[80]

ទីកន្លែងធ្វើមជ្ឈត្តការសម្រាប់ដំណើរការមជ្ឈត្តកម្មវិធានការបណ្តោះអាសន្ន ចេញដោយមជ្ឈត្តករបន្ទាន់ បើគូភាគីវិវាទបានព្រមព្រៀងយកទីកន្លែងណាមួយសម្រាប់ធ្វើមជ្ឈត្តការ គឺសម្រេចយកទីកន្លែងនោះសម្រាប់

---

[76] ប្រការ ៣៣.១ វិធានស្តីពីមជ្ឈការ ឆ្នាំ ២០២១។

[77] ប្រការ ៣៣.២ វិធានស្តីពីមជ្ឈការ ឆ្នាំ ២០២១។

[78] មេធាវីស្ទីវិន អ៊ែម អូស្ទើរមើឡឺរី សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៧២ បោះពុម្ពឆ្នាំ ២០០៩។

[79] ប្រការ ៣៣.៣ វិធានស្តីពីមជ្ឈការ ឆ្នាំ ២០២១។

[80] ប្រការ ៣១ វិធានស្តីពីមជ្ឈការ ឆ្នាំ ២០២១។

ដំណើរការមជ្ឈត្តការ។ ប្រសិនបើគ្មានការព្រមព្រៀងរវាងគូភាគីវិវាទ ទីកន្លែងគឺ រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា តែក៏អាចខុសពីនេះបានដែរ។[81]

គួរកត់សម្គាល់ថា ការកំណត់យកទីកន្លែងសម្រាប់ដំណើរការមជ្ឈត្តការមានអត្ថប្រយោជន៍សំខាន់ណាស់សម្រាប់ភាគីវិវាទ ដែលអាចធ្វើឡើងជាអន្តរជាតិ សម្រាប់ប្រទេសដែលជារដ្ឋហត្ថលេខីនៃអនុសញ្ញាញ៉ូយ៉ក (NYC) ដែលក្នុងនោះក៏មានកម្ពុជាដែរ[82] ពីព្រោះថាទីកន្លែងមានឥទ្ធិពលលើការចំណាយនៃដំណើរការនៃមជ្ឈត្តការ យុត្តាធិការតុលាការនៃប្រទេសណានោះថាតើមជ្ឈត្តករនៅទីនោះមានសមត្ថភាព និងតម្លាភាពនិងជាទីកន្លែងអាចកំណត់ពីមជ្ឈត្តវិនិច្ឆ័យ។

### ៣.១.៣. ការកំណត់យកច្បាប់មកប្រើប្រាស់

ការកំណត់យកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តណាមួយសម្រាប់អនុវត្តចំពោះខ្លឹមសារនៃវិវាទក្នុងវេទិកាមជ្ឈត្តកម្ម គូភាគីមានសេរីភាពក្នុងការព្រមព្រៀងជ្រើសរើស ដែលហៅថាប្បញ្ញតិស្តីពីជម្រើសនៃច្បាប់។[83] វាជាជាការសំខាន់ដែលគូភាគី សម្រាប់ដំណើរមជ្ឈត្តការគ្រប់ពេលចុះកិច្ចសន្យា ដើម្បីជៀសវាងវិវាទជម្រើសច្បាប់នៅពេលក្រោយ។ នៅពេលដែលគ្មានការជ្រើសរើសទេ ពេលមានវិវាទកើតឡើង វេទិកាមជ្ឈត្តកម្មជាអ្នកដែលជ្រើសរើសយកវិធានសមស្របណាមួយមកអនុវត្ត។[84] ជាធម្មតា ជម្រើសបទប្បញ្ញត្តិគតិយុត្តណាមួយ នឹងត្រូវដាក់បញ្ចូលទៅក្នុងកិច្ចសន្យាជានិច្ចជាកាល។[85]

ប្រសិនបើកិច្ចសន្យាមានចែងនូវបញ្ញត្តិផ្សេងៗដោយភាគីនៃវិវាទ ព្រមទាំងករណីដែលមានទម្លាប់ពាណិជ្ជកម្មពាក់ព័ន្ធនានា វេទិកាមជ្ឈត្តកម្មមានកិច្ចចាំបាច់ត្រូវតែធ្វើការពិនិត្យមើលគ្រប់ប្រការ និងស្ថានភាពទាំងអស់នៅក្នុងកិច្ចសន្យានោះ។[86]

---

[81] ប្រការ ១៣ វិធានស្តីពីមជ្ឈការ ឆ្នាំ ២០២១។

[82] គេហទំព័រ Overview of Cambodian Alternative Dispute Resolution System https://cacj-ajp.org/cambodia/legal-system/overview-of-cambodian-alternative-dispute-resolution-system/#:~:text=Cambodia%20ratified%20the%20New%20York,10%20dated%2023%20July%202001. (ចូលទស្សនាចុងក្រោយនៅ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២៣)។

[83] ប្រការ ៣២.១ វិធានស្តីពីមជ្ឈការ ២០២១។

[84] ប្រការ ៣២.១ វិធានស្តីពីមជ្ឈការ ២០២១។

[85] មេធាវីស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៦១ បោះពុម្ពឆ្នាំ ២០០៩។

[86] ប្រការ ៣២.៣ វិធានស្តីពីមជ្ឈការ ២០២១។

ចំណែកឯការសម្រុះសម្រួលនិងសមធម៌ពីវេទិកាមជ្ឈត្តកម្ម លុះត្រាតែមានការអនុញ្ញាតអំពីគូភាគីតែប៉ុណ្ណោះ បើពុំដូច្នោះទេ គឺវេទិកាមជ្ឈត្តកម្ម មិនចេះតែអាចសម្រុះសម្រួលទេ។[87] តាមការសម្រុះសម្រួលនេះ វេទិកាមជ្ឈត្តកម្មចាំបាច់ត្រូវធ្វើការសម្រេចសេចក្តីតាមគោលការណ៍សមធម៌ និងយុត្តិធម៌ជាជាង គោលការណ៍ច្បាប់ដែលបានចែងមក។[88]

ជាទូទៅវិវាទមជ្ឈត្តកម្មភាគច្រើនយកតាមច្បាប់សន្និសញ្ញាទីក្រុងញ៉ូយ៉ក ហើយច្បាប់មជ្ឈត្តការកម្ពុជាមានភាពស៊ីសង្វាក់គ្នាជាមួយប្រទេស៥០តាមការប៉ាន់ស្មាន ដែលជាដៃគូពាណិជកម្មសំខាន់ៗជាមួយកម្ពុជាដូចជា ប្រទេស កូរ៉េខាងត្បូង ជប៉ុន ថៃ អូស្ត្រាលី សិង្ហបុរីជាអាទិ៍ ដែលជាហេតុនាំអោយនៅក្នុងឆ្នាំ២០២០ មជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈមណ្ឌលមជ្ឈត្តកម្មកម្ពុជា[89] ដោយផ្អែកតាម UNCITRAL Model Law ត្រូវបានទទួលស្គាល់ដោយសាលាឧទ្ធរណ៍នៃប្រទេសសឹង្ហបុរី (The High Court) និងគ្មានការបដិសេធពីតុលាការណាមួយឡើយក្រោយពីការចេញមជ្ឈត្តវិនិច្ឆ័យ។[90]

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០០៦ លាតសន្ធឹងនិងគ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពនៃវិវាទមជ្ឈត្តការពាណិជ្ជកម្ម នឹងត្រូវបានយកមកប្រើប្រាស់ដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលច្បាប់នេះអាចយកមកអនុវត្តចំពោះតែផ្នែកពាណិជ្ជកម្មតែប៉ុណ្ណោះ[91] ដោយយកតាមលំនាំដើមតាមច្បាប់គំរូ UNCITRAL Model Law នៃអង្គការសហប្រជាជាតិ។[92]

---

[87] ប្រការ ៣២.២ វិធានស្តីពីមជ្ឈការ ២០២១។

[88] *The Halbout & Matenec HG v. Hanin*, Court de Cassation [France], សាលារដ្ឋប្បវេណីទី ២ (ថ្ងៃទី១៥ កុម្ភៈ ឆ្នាំ ២០០១)

[89] មេធាវីស្ទីវិន អ៊ែម អូស្ទើមីឡឺរី សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៧៧ បោះពុម្ពឆ្នាំ ២០០៩។

[90] គេហទំព័រ ច្បាប់គម្រូ UNCITRAL ស្តីមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិឆ្នាំ ២០០៦ វេបសាយត៍ UNCITRAL https://uncitral.un.org/sites/uncitral.un.org/files/media-documents/uncitral/en/06-54671_ebook.pdf (ចូលទស្សនាចុងក្រោយនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២៣)។

[91] មេធាវីស្ទីវិន អ៊ែម អូស្ទើមីឡឺរី សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៦៧ បោះពុម្ពឆ្នាំ ២០០៩។

[92] ដដែល។

### ៣.១.៤. ការកំណត់ពេលវេលាដំណើរការមជ្ឈត្តការ

ការកំណត់ពេលវេលា និងការប្រើប្រាស់ពេលវេលាសម្រាប់ដំណើរការដោះស្រាយវិវាទ គឺដើម្បីកំណត់យកពេលវេលាណាមួយសមស្របសម្រាប់ដំណើរប្រព្រឹត្តទៅយ៉ាងរលូននៃមជ្ឈត្តការ។ ការកំណត់ពេលវេលាគឺគេធ្វើការគណនាកំឡុងពេលក្នុងការប្រព្រឹត្តទៅនៃដំណើរការ និងបម្រែបម្រួលនៃពេលវេលាដោយប្រការណាមួយ។[93]

ការគណនានៃពេលវេលានេះ ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់ ឬជាថ្ងៃកន្លងផុតទៅមួយថ្ងៃដែលព្រឹត្តការណ៍នោះចាប់ផ្តើមក្នុងចន្លោះពេលនោះ ព្រមទាំងត្រូវគណនាបន្ថែមពេលវេលាពេញនៃថ្ងៃចុងក្រោយនៃចន្លោះពេលនោះ។[94]

ករណីនេះមិនអាចយកមកអនុវត្តបានក្នុងករណីដែលមានការកំណត់ផ្សេងដោយអគ្គលេខាធិការដ្ឋាន ឬវេទិកាមជ្ឈត្តកម្ម។ ការកំណត់យកគោលការណ៍ល្វែងម៉ោងប្រទេសកម្ពុជា (GMT+7) ចំពោះចន្លោះម៉ោងពី ០៨:០០ ព្រឹក ដល់ម៉ោង ០៥:០០ ល្ងាច សំដៅដល់ថេរវេលាក្នុងពាក្យថា ថ្ងៃ ឬកាលបរិច្ឆេទ។ ក្រោយពីពេលវេលាពីម៉ោង ០៥:០០ ល្ងាច ត្រូវចាត់ទុកជាពេលវេលានៃថ្ងៃថ្មី ឬកាលបរិច្ឆេទថ្មីបន្ទាប់។[95] ករណីដែលថ្ងៃចុងក្រោយនៃអំឡុងពេលនោះ មិនមែនជាថ្ងៃធ្វើការនៃទីកន្លែងដែលបានធ្វើការទាក់ទង អំឡុងពេលនេះនឹងត្រូវពន្យា រហូតដល់ថ្ងៃធ្វើការធម្មតាទីមួយ បន្ទាប់ពីថ្ងៃមិនធ្វើការនោះ។ ការកំណត់យកថ្ងៃឈប់សម្រាក តាមបានធ្វើការកំណត់តាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជៀសវាងការភ័ន្តច្រលំ។[96]

បើសិនជាភាគីចង់ធ្វើការកែប្រែពេលវេលាដែលបានកំណត់រួចរាល់ហើយ ភាគីត្រូវជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម ដើម្បីធ្វើការកែប្រែទៅលើពេលវេលានៃការចាប់ផ្តើមមជ្ឈត្តកម្ម ការបង្កើតវេទិកាមជ្ឈត្តកម្ម កម្រៃសេវា និងបទបញ្ញត្តិនានា ដែលមានការទាក់ទីននឹងអគ្គលេខាធិការដ្ឋាន[97] ព្រមទាំងធ្វើការកែប្រែទៅលើ ពេលវេលានៃដំណើរមជ្ឈត្តការ សេចក្តីសម្រេចលើការតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យបន្ថែម។[98] គូភាគី ក៏អាចធ្វើការព្រមព្រៀងគ្នាបន្ថយពេលវេលាកំណត់ណាមួយបានដែរ។ ការព្រមព្រៀងទាំងអស់នេះ មានអានុភាពដរាបណាមានការឯកភាពពីវេទិកាមជ្ឈត្តកម្មជាមុនសិន។[99]

---

93 ប្រការ ៥.១ វិធានស្តីពីមជ្ឈត្តការ ២០២១។

94 ដដែល។

95 ប្រការ ៥.១ វិធានស្តីពីមជ្ឈត្តការ ២០២១។

96 ដដែល។

97 ប្រការ ៥.២ ចំណុច (ក)(i) វិធានស្តីពីមជ្ឈត្តការ ២០២១។

98 ប្រការ ៥.២ ចំណុច (ខ)(i)(ii) វិធានស្តីពីមជ្ឈត្តការ ២០២១។

99 ប្រការ ៥.២ ចំណុច(គ)វិធានស្តីពីមជ្ឈត្តការ ២០២១។

### ៣.១.៥. អានុភាពនៃខចែងមជ្ឈត្តកម្ម

ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការ មិននាំឱ្យខចែងស្តីពីមជ្ឈត្តកម្មនោះបាត់សុពលភាពឡើយ។ ដើម្បីអោយ យុត្តាធិការនៃវេទិកាមជ្ឈត្តកម្មមិនរលត់ គោលបំណងនៃខចែងស្តីពីមជ្ឈត្តកម្មត្រូវផ្តាច់ចេញ ដែលត្រូវចាត់ទុកជាការព្រមព្រៀងដោយឡែកក្លាយជាផ្នែកមួយនៃកិច្ចសន្យា ដែលមិនទាក់ទងនឹងលក្ខខណ្ឌ និងខចែងផ្សេងទៀតនៃកិច្ចសន្យានោះឡើយ។[100]

ជាងនេះទៅទៀតខចែងពីមជ្ឈត្តការ គឺជាការបញ្ជាក់របស់គូភាគីក្នុងការព្រមព្រៀងទៅដោះស្រាយវិវាទតាមមធ្យោបាយមជ្ឈត្តការ។ ខចែងនេះអាចរារាំងដល់ភាគីណាមួយ ចង់កែប្រែនៅពេលក្រោយក្នុងការសំរេចដាក់ពាក្យបណ្តឹងទៅតុលាការបាន។ ហេតុនេះតើត្រូវចែងខសំរាប់មជ្ឈត្តការយ៉ាងដូចម្តេចទើបមានសុពលភាព?

ខចែងពីមជ្ឈត្តការ អាចត្រូវបានកំណត់ក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងដោយឡែកនៅពេល បង្កើតកិច្ចសន្យាអាជីវកម្មអ្វីមួយ។[101]

**ឧទាហរណ៍** កិច្ចសន្យាធ្វើអាជីវកម្មកម្មសិទ្ធិបញ្ញា កិច្ចសន្យាក្រុមហ៊ុន (លក្ខន្តិកៈក្រុមហ៊ុន) កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាជាដើម។ គូភាគីអាចចែងដោយសេរី តែត្រូវមាន យ៉ាងតិចនូវពាក្យ "**...មជ្ឈត្តការ...**" ពីព្រោះវាអាចបញ្ជាក់ច្បាស់លាស់ និងផ្តល់សមត្ថកិច្ចក្នុងការយកមធ្យោបាយមជ្ឈត្តការ សំរាប់ដោះស្រាយវិវាទរបស់ពួកគេ។[102]

ផ្ទុយទៅវិញ ក្នុងករណីដែលខចែងមានភាពស្រពិចស្រពិល ឬប្រហាក់ប្រហែល ឬស្រដៀង ដូចជាថាការផ្សះផ្សា ឬការសំរបសំរួល មិនមានន័យគ្រប់គ្រាន់ក្នុងការយល់ព្រមធ្វើមជ្ឈត្តការនោះទេ ហើយជាផលលំបាកខចែងនោះ នឹងមិនចងកាតព្វកិច្ចក្នុងការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទនេះឡើយ និងភាគីវិវាទណាមួយនៅតែអាចជ្រើសរើសប្រព័ន្ធតុលាការដដែល។[103] លើសពីនេះ ខចែងមជ្ឈត្តការ ក៏ត្រូវចែងផងដែរនូវ ឈ្មោះមជ្ឈត្តករ (មជ្ឈត្តការបែបអាដហុក) ឬស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ (មជ្ឈត្តការបែបស្ថាប័ន)។[104]

**ឧទាហរណ៍** មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីនៅពេលមានវិវាទកើតឡើងភាគីវិវាទមួយគ្រាន់តែដាក់សេចក្តីជូនដំណឹង អំពីមជ្ឈត្តកម្ម (ពាក្យសុំសេវាកម្មអំពីមជ្ឈត្តកម្ម) ដល់ពួកគេ បន្ទាប់មក

---

[100] ប្រការ ៣៤.៣ វិធានស្តីពីមជ្ឈត្តការ ២០២១។

[101] គេហទំព័រ London High Court, *Fiona Trust v. Privalov (2015)* http://www.nadr.co.uk/articles/published/ArbitLRe/Fiona%20v%20Privalov%202007.pdf (ចូលទស្សនានៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០២៣)។

[102] គេហទំព័រ About the Arbitration Clause https://ouchvutthy.files.wordpress.com/2012/07/arbitration-clause.pdf (ចូលទស្សនាថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០២៣)។

[103] ដដែល។

[104] ដដែល។

ដំណើរការមជ្ឈត្តការនឹងចាប់ផ្តើម។ ក្រៅពីចំនុចទាំងនេះ នៅមានទីកន្លែង ភាសា ច្បាប់ និងវិធានសំរាប់ដោះស្រាយ។ល។[105] សុទ្ធតែត្រូវចែងឬក៏កំណត់ជាមុន ដែលទាំងនេះគឺអាស្រ័យទៅលើសេវាកម្មរបស់មជ្ឈត្តករឬស្ថាប័នដែលបានជ្រើសរើស។ ហេតុនេះ គូភាគីត្រូវពិនិត្យមើលគំរូនៃខចែងរបស់ពួកគេជាមុន ឬធ្វើការពិភាក្សាជាមុន នៅពេលសំរេចជ្រើសរើសសេវាកម្មរបស់ពួកគេ។ ជារួមដើម្បីអាចដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការបាន ខចែងពីមជ្ឈត្តការ ដែលមាននៅក្នុងកិច្ចសន្យាឬកិច្ចព្រមព្រៀងដោយឡែករបស់គូភាគីត្រូវតែមានភាពច្បាស់លាស់នូវពាក្យ "**មជ្ឈត្តការ**"។ ការចែងដទៃទៀតសំរាប់លក្ខខណ្ឌនៃដំណើរការនីតិវិធីរបស់មជ្ឈត្តការ គឺអាស្រ័យទៅនឹងមជ្ឈត្តករ ឬស្ថាប័នដែលបានផ្តល់ជាគំរូ ឬកំណត់រួចហើយ។ ការបំពេញនៅលក្ខខណ្ឌទាំងនេះគ្រប់គ្រាន់ អាចធ្វើឲ្យខចែងពីមជ្ឈត្តការមានសុពលភាព និងធានាបាននូវដំណើរការមជ្ឈត្តការយ៉ាងប្រាកដ។[106]

## ៣.២. ដំណើរការមុនការចាប់ផ្តើមមជ្ឈត្តកម្ម

### ៣.២.១. ពាក្យបណ្តឹងរបស់ភាគី

សេចក្តីជូនដំណឹងត្រូវបានដាក់ជូនទៅអគ្គលេខាធិការដ្ឋានរាល់ព័ត៌មានទាំងអស់ ដោយអ្នកដែលមានបំណងដោះស្រាយតាមដំណើរការមជ្ឈត្តកម្ម ដែលហៅថាជា "**ភាគីប្តឹងទាមទារ**" ទាមទារទៅភាគីម្ខាងទៀតដែលហៅថាជា "**ភាគីប្តឹងឆ្លើយតប**"។ សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវធ្វើជាភាសាសម្រាប់មជ្ឈត្តកម្ម និងបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។[107] ព័ត៌មានដែលត្រូវមានក្នុងសេចក្តីជូនដំណឹងរួមមានដូចជា សេចក្តីថ្លែងដែលបញ្ជាក់ថាវិវាទត្រូវបានដាក់ឱ្យដោះស្រាយតាមមជ្ឈត្តកម្ម សេចក្តីថ្លែងឬសំណើបន្ថែមទាក់ទងនឹងដំណើរការមជ្ឈត្តការ សេចក្តីយោងនៃកិច្ចសន្យា ឬទំនាក់ទំនងផ្សេងៗ ដែលកើតចេញពីវិវាទ ឬដែលទាក់ទងនឹងវិវាទ និងភ្ជាប់សំណៅចម្លងនៃកិច្ចសន្យា សេចក្តីថ្លែងសង្ខេបដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃវិវាទ ការទាមទារ ឬការសង្គ្រោះដែលទាមទារ និងអត្តសញ្ញាណគូភាគី និងអត្តសញ្ញាណក្រុមហ៊ុន(ប្រសិនជាមាន) របស់គូភាគីវិវាទ អត្តសញ្ញាណ ចំនួនមជ្ឈត្តករ ភាសា និងច្បាប់សម្រាប់អនុវត្តក្នុងដំណើរការមជ្ឈត្តការ។[108]

ប្រសិនជា វិធានរបស់មជ្ឈមណ្ឌលជាតិមជ្ឈត្តកម្មមិនត្រូវយកមកប្រើដោយគូភាគីវិវាទក្នុងកិច្ចព្រមព្រៀងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានចែងអំពីបញ្ញត្តិទូទៅមួយចំនួន ដែលក្នុងនោះគូភាគីត្រូវបំពេញ

[105] គេហទំព័រ អំពីខចែងពីមជ្ឈត្តការ www.ouchvutthy.wordpress.com (ចូលទស្សនាថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០២៣)។

[106] ប្រការ ៧.១. វិធានស្តីពីមជ្ឈត្តការ ២០២១។

[107] ដដែល។

[108] ប្រការ ៧ វិធានស្តីពីមជ្ឈត្តកម្ម ២០២១។

លក្ខខណ្ឌដើម្បីដាក់លិខិតបញ្ជាក់អំពីការទាមទារ រួមមាន អង្គហេតុដែលនាំឱ្យមានការទាមទារ ចំណុចដែលមានបញ្ហា និងដំណោះស្រាយដែលខ្លួនចង់បាន។[109]

### ៣.២.២. ភាគីឆ្លើយតប

ក្នុងនីតិវិធីមជ្ឈត្តការ តួនាទីរបស់ភាគីឆ្លើយតបគឺ ត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតបក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង។ នៅក្នុងពាក្យបណ្តឹងរបស់ភាគីឆ្លើយតប ត្រូវមានព័ត៌មានដូចជា ការបញ្ជាក់សង្ខេបអំពីការទទួលយក ឬការបដិសេធចំពោះការទាមទារទាំងស្រុង ឬដោយផ្នែក សេចក្តីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃបណ្តឹងតប ឬការដោះសារតាមរយៈការកាត់កង ដែលភាគីឆ្លើយតបមានបំណងបញ្ជូន មានសេចក្តីថ្លែងការណ៍ ឬសំណើបន្ថែមផ្សេងៗ ដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការអត្តសញ្ញាណគូភាគី អត្តសញ្ញាណក្រុមហ៊ុន របស់គូភាគីវិវាទ ភាសា និងច្បាប់ដែលត្រូវអនុវត្ត។[110]

ភាគីឆ្លើយតប ក្នុងអំឡុងពេលដែលកំណត់ដោយវេទិកាមជ្ឈត្តកម្មត្រូវ ដាក់សេចក្តីថ្លែងដោះសារដែលមានបញ្ជាក់សេចក្តីលម្អិតដូចជាអង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគី ឆ្លើយតបទទួលស្គាល់ អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបដិសេធ និងមូលហេតុនៃការបដិសេធនោះ និងអង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ផ្សេងទៀត ដែលភាគីឆ្លើយតបផ្អែកជាមូលដ្ឋាន លើកលែងតែសេចក្តីថ្លែងដោះស្រាត្រូវបានប្រគល់រួចហើយ។[111]

បន្ទាប់ពីបានទទួលសេចក្តីថ្លែងដោះសារ ត្រូវបញ្ជូន សេចក្តីថ្លែងដោះសារចំពោះបណ្តឹងតបនោះ ដោយត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានានៃខ្លឹមសារសេចក្តីថ្លែងដោះសារនិងបណ្តឹងតប ក្នុងវិធានស្តីពីមជ្ឈត្តការរបស់ NCAC ប្រសិនបើបណ្តឹងតបត្រូវបានធ្វើឡើង ភាគីប្តឹងទាមទារ ក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន។[112]

[109]ជំពូកទី៦ ដំណើរការនៃនីតិវិធីមជ្ឈត្តការ ច្បាប់ស្តីពីមជ្ឈត្តកម្ម ២០០៦

[110] ប្រការ ៨ វិធានស្តីពីមជ្ឈត្តកម្ម ២០២១

[111]ប្រការ ៣៧.៣.វិធានស្តីពីមជ្ឈត្តកម្ម ២០២១

[112] ប្រការ ៣៧.៤. វិធានស្តីពីមជ្ឈត្តកម្ម ២០២១

### ៣.២.៣. ការកែប្រែពាក្យបណ្ដឹងតប

ការកែប្រែ ឬបន្ថែមការទាមទារ ការដោះសារបណ្ដឹងតប ឬការដោះសារតាមការកាត់កង ត្រូវតែមានការអនុញ្ញាតពីវេទិកាមជ្ឈត្តការជាមុនសិន ដោយមូលហេតុថាការធ្វើបែបនេះចំពោះបណ្ដឹងអាចបង្កអោយមានការពន្យាដល់ដំណើរការមជ្ឈត្តការ និងមានការប្រព្រឹត្តទៅដោយលំអៀងដល់ភាគីម្ខាងទៀត ឬអាចមានកាលៈទេសៈផ្សេងទៀតកើតឡើង។[113]

ចំពោះករណីដែលពាក្យបណ្ដឹងស្ថិតនៅក្រៅយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ការកែប្រែ ឬបន្ថែមការទាមទារ ការដោះសារបណ្ដឹងតប ឬការដោះសារតាមការកាត់កងក៏មិនអាចប្រព្រឹត្តទៅបានដែរ។ [114]

### ៣.២.៤. ការដកពាក្យបណ្ដឹង

ក្រោយពីភាគីប្ដឹងទាមទារដាក់សេចក្ដីជូនដំណឹងទៅវេទិកាមជ្ឈត្តកម្ម ភាគីប្ដឹងទាមទារមានសិទ្ធិ ក្នុងការដកពាក្យបណ្ដឹងរបស់ខ្លួន លើកលែងតែភាគីឆ្លើយតបជំទាស់ និងវេទិកាមជ្ឈត្តកម្មមានសេចក្ដីសម្រេចស្ដាពរលើវិវាទ។ វេទិកាមជ្ឈត្តកម្មចេញសេចក្ដីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ ក្នុងលក្ខខណ្ឌដែលមានការដកពាក្យបណ្ដឹង។[115]

## ៣.៣. ដំណើរការមជ្ឈត្តការ

### ៣.៣.១. ការដាក់ពាក្យស្នើសុំរបស់ភាគី

នៅពេលដំណើរការ គូភាគីមានការសំណូមពរចំពោះវេទិកាមជ្ឈត្តកម្ម ក្នុងការចេញវិធានបណ្ដោះអាសន្នជាមុនសិន ត្រូវផ្ដល់ចម្លើយតបតាមការស្នើសុំរបស់ភាគី ទើបកាត់សេចក្ដីទៅលើវិវាទទាំងមូលនៅពេលក្រោយ។ ប្រសិនបើគូភាគីត្រូវរង់ចាំរយៈពេលយូរ ក្នុងកាត់សេចក្ដីលើវិវាទទាំងស្រុងនឹងធ្វើអោយមានការយឺតយ៉ាវជ្រុល និងមានការខាតប្រយោជន៍ ដើម្បីការពារសិទ្ធិ ឬទ្រព្យសម្បត្តិដល់ភាគីម្ខាងទៀត។[116]

**ឧទាហរណ៍** ភាគីម្ខាងចង់ឱ្យភាគីម្ខាងទៀតឈប់បោះពុម្ពឯកសារមិនពិត ឬដែលនាំឱ្យមានការភ័ន្តច្រឡំ។ ហេតុនេះហើយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីនោះឈប់បោះពុម្ពឯកសារទាំងនោះភ្លាមៗ រហូតដល់

[113] ប្រការ ៣៨.២ វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

[114] ដដែល។

[115] ប្រការ ៣៨.១ វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

[116] ប្រការ ៣៥ ១ វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

ផែទិកាមជ្ឈត្តកម្មអាចធ្វើការសម្រេចលើអង្គហេតុទាំងស្រុង ឬការមិនចុះសម្រុងគ្នាត្រូវបានដោះស្រាយ ដែលពេលខ្លះគេហៅថា "**សេចក្ដីបង្គាប់**"។[117]

ដំណើរការមជ្ឈត្តការត្រូវធ្វើឡើងដោយផែទិកាមជ្ឈត្តកម្ម យល់ថាសមស្រប ដើម្បីធានាភាពយុត្តិធម៌ឆាប់រហ័ស ចំណាយអស់តិច និងផ្ដល់ដំណោះស្រាយចុងក្រោយនៃវិវាទ។ ផែទិកាមជ្ឈត្តកម្មត្រូវយកចិត្តទុកដាក់ស្មើគ្នាចំពោះគូភាគីវិវាទ និងត្រូវផ្ដល់ឱកាសសមរម្យដើម្បីបង្ហាញរឿងរ៉ាវរបស់ខ្លួន។[118]

សេចក្ដីបង្គាប់ ឬសេចក្ដីណែនាំ ដែលផែទិកាមជ្ឈត្តកម្មយល់ថាសមស្រប លុះត្រាតែសេចក្ដីបង្គាប់ និងសេចក្ដីណែនាំនោះ មិនត្រូវផ្ទុយនឹងវិធាននេះ ឬច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការឡើយ។ ក្នុងករណីដែលផែទិកាមជ្ឈត្តកម្មបានកំណត់ផ្សេងពីនេះ គូភាគីវិវាទយល់ព្រមក្នុងការគោរពដោយមិនបង្អង់តាមសេចក្ដីបង្គាប់ ឬសេចក្ដីណែនាំ។[119]

## ៣.៣.២. ដំណើរការត្រៀមមជ្ឈត្តការ

ផែទិកាមជ្ឈត្តកម្មត្រូវព្យាយាមស្វែករកដំណោះស្រាយនិងស្រុះស្រួលជូនគូភាគីវិវាទ ក្នុងលក្ខណៈណាមួយសមស្រប មុនពេលឬក្នុងអំឡុងពេលប្រជុំត្រៀម។[120] ការរៀបចំការប្រជុំត្រៀមជាមួយគូភាគីវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងពីនេះ គឺដើម្បីរៀបចំ និងកំណត់កាលវិភាគនៃដំណើរការមជ្ឈត្តការបន្ទាប់ ឬពិភាក្សាអំពីនីតិវិធីដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតសម្រាប់សំណុំរឿង។[121] ពីលើការប្រជុំត្រៀម ក៏មានការប្រជុំបន្ថែមក្នុងគោលបំណងពិនិត្យទីតាំង វត្ថុ ឯកសារផ្សេងៗ ឬពិនិត្យលើវិឌ្ឍនភាពនៃដំណើរការមជ្ឈត្តការ។

## ៣.៣.៣. ដំណើរការសវនាការ

នៅដំណាក់កាលមុនដំណើរសវនាការនេះមានរយៈយ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ផែទិកាមជ្ឈត្តកម្ម អាចផ្ដល់ដល់គូភាគីវិវាទនូវបញ្ជីនៃចំណុចវិវាទ ឬសំណួរដែលផែទិកាមជ្ឈត្តកម្ម មានបំណងឱ្យភាគីវិវាទទាំងអស់ពិចារណាជាពិសេស។ ផែទិកាមជ្ឈត្តកម្មគឺជាអ្នកដែលត្រូវកំណត់អំពី កាលបរិច្ឆេទ ពេលវេលា ទី

[117] ប្រការ ៣៥ ១ វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

[118] គេហទំព័រ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម https://www.theseedcambodia.com/article/6063/ (ចូលទស្សនានៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០២៣)។

[119] ដដែល។

[120] ប្រការ ៣៥.៣. វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

[121] ប្រការ ៣៥.២ វិធានស្ដីពីមជ្ឈត្តកម្ម ២០២១។

កន្លែង និងរបៀបការធ្វើសវនាការ និងត្រូវផ្តល់ដំណឹងជាមុនទៅគូភាគីវិវាទអំពីបញ្ហាទាំងនេះយ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទធ្វើសវនាការ។[122]

បន្ទាប់ពីរយៈពេល ១៥ (ដល់ប្រាំ) ថ្ងៃកន្លងផុតទៅ ដំណើរការសវនាការបានឈានមកដល់ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាតើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ ឬត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗតែប៉ុណ្ណោះ ប៉ុន្តែក្នុងករណីដែលគូភាគីវិវាទសុំដោយភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសវនាការ ដោយផ្ទាល់មាត់នៅដំណាក់កាលសមរម្យណាមួយនៃដំណើរការមជ្ឈត្តការ។

ក្នុងការធ្វើសវនាការដោយផ្ទាល់មាត់ក្រោយពីបានពិភាក្សាអង្គហេតុ និងកាលៈទេសៈរបស់សំណុំរឿងជាមួយគូភាគី វេទិកាមជ្ឈត្តការធ្វើឡើងដោយការចូលរួមផ្ទាល់ ឬពីចម្ងាយដោយ ទូរស័ព្ទ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិច សន្និសិទវីដេអូជាមួយអ្នកចូលរួមនៅទីតាំងរួម ឬដោយឡែកពីគ្នា។ នៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ឬនៅក្នុងដំណាក់កាលណាមួយនៃដំណើរមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចសម្រេចឱ្យមានសវនាការបន្ថែម ប្រសិនបើកាលៈទេសៈនៃមជ្ឈត្តការតម្រូវ។[123]

ក្នុងដំណើរមជ្ឈការ វេទិកាមជ្ឈត្តកម្មអាចធ្វើការបន្តធ្វើមជ្ឈត្តកម្ម និងអាចចេញមជ្ឈត្តវិនិច្ឆ័យ ដោយផ្អែកលើសេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម ដោយមិនមានការរាំងស្ទះពីសំណាក់ភាគីវិវាទណាមួយទេ បើករណីដែលមានការខកខានមិនចូលរួមក្នុងសវនាការដោយផ្ទាល់មាត់នោះមិនបានបញ្ជាក់ពីមូលហេតុគ្រប់គ្រាន់។[124]

## ៣.៤. ការបញ្ចប់មជ្ឈត្តវិនិច្ឆ័យ

ក្រោយបិទបញ្ចប់នីតិវិធីមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មធ្វើការផ្ទៀងផ្ទាត់លើសេចក្តីសម្រេចនៃទម្រង់មជ្ឈត្តវិនិច្ឆ័យហើយប្រកាសផ្សព្វផ្សាយមជ្ឈត្តត្តវិនិច្ឆ័យនោះ។ ប៉ុន្តែប្រសិនបើភាគីមិនយល់ស្របនឹងសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ភាគីអាចប្តឹងឧបាស្រ័យទៅនឹងការមជ្ឈត្តវិនិច្ឆ័យនោះបាន។[125]

[122] ប្រការ ៣៩ ៤ វិធានស្តីពីមជ្ឈត្តកម្ម ២០២១។

[123] ប្រការ៣៩ ១ វិធានស្តីពីមជ្ឈត្តកម្ម ២០២១។

[124] ប្រការ៣៩.២ វិធានស្តីពីមជ្ឈត្តការ ២០២១។

[125] គេហទំព័រ Overview of Cambodian Alternative Dispute Resolution System https://cacj-ajp.org/cambodia/legal-system/overview-of-cambodian-alternative-dispute-resolution-system/#:~:text=Cambodia%20ratified%20the%20New%20York,10%20dated%2023%20July%202001 (ចូលទស្សនាចុងក្រោយនៅ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២៣)។

### ៣.៤.១. សេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ

នៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្ម ត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីឱ្យធ្វើការពិនិត្យ។ បើវេទិកាមជ្ឈត្តកម្ម ឬគូភាគីវិវាទបានព្រមព្រៀងពន្យា វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានប្រកាសបិទដំណើរការមជ្ឈត្តកម្ម។[126]

អគ្គលេខាធិការ អាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យត្រួតពិនិត្យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យដោយយកចិត្តទុកដាក់លើចំណុចសារធាតុនានានៃមជ្ឈត្តវិនិច្ឆ័យ ដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ចាប់ពីបានទទួលសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ។[127] ការស្នើកែប្រែទៅលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ មិនត្រូវបានធ្វើឡើងចំពោះមជ្ឈត្តវិនិច្ឆ័យវិធានបណ្តោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យវិធានដោះស្រាយវិវាទដោយស្ម័គ្រចិត្តឡើយ។ [128]

ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬសេចក្តីព្រាង "**មជ្ឈត្តវិនិច្ឆ័យបន្ថែម**" ដោយធ្វើការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះទៅអគ្គលេខាធិការដ្ឋានសម្រាប់ការពិនិត្យពិច័យ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិននៃការទទួលបានសេចក្តីព្រាង។[129]

ការសម្រេចលើមជ្ឈត្តវិនិច្ឆ័យឬសេចក្តីសម្រេចផ្សេង គឺត្រូវយកតាមវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករដោយមានមតិភាគច្រើន យកទៅធៀបនឹងចំនួនមជ្ឈត្តករ ដែលជាសមាជិកវេទិកាមជ្ឈកម្មទាំងអស់។[130]

### ៣.៤.២. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

វេទិកាមជ្ឈត្តកម្មមិនអាចចេញមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ ប្រសិនបើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនោះមិនទាន់ត្រូវបានពិនិត្យ និងឯកភាពដោយអគ្គលេខាធិការដ្ឋាន។[131] មជ្ឈត្តវិនិច្ឆ័យត្រូវតែជាលាយលក្ខណ៍អក្សរ ឬជាមានសំអាងហេតុជាមូលដ្ឋានបើគូភាគីវិវាទបានព្រមព្រៀងខុសពីលក្ខខណ្ឌនេះ។[132] ទន្ទឹមនឹងនេះ មជ្ឈត្តវិនិច្ឆ័យត្រូវមានចុះកាលបរិច្ឆេទ ទីកន្លែងដែលមជ្ឈត្តវិនិច្ឆ័យ និងមានការចុះហត្ថលេខាពីគ្រប់មជ្ឈត្តករ ឬក្នុងករណីដែល

[126] ប្រការ ៥០.១ ចំណុច (ក) វិធានស្តីពីមជ្ឈត្តការ ២០២១។
[127] ប្រការ ៥០.១ ចំណុច (ខ) វិធានស្តីពីមជ្ឈត្តការ ២០២១។
[128] ប្រការ ៥០.១(ខ) វិធានស្តីពីមជ្ឈត្តការ ២០២១។
[129] ប្រការ ៥០.២ វិធានស្តីពីមជ្ឈត្តការ ២០២១។
[130] ប្រការ៤៧.១. វិធានស្តីពីមជ្ឈត្តការ ២០២១។
[131] ប្រការ៤៩.៥. វិធានស្តីពីមជ្ឈត្តការ ២០២១។
[132] ប្រការ៤៩.១. វិធានស្តីពីមជ្ឈត្តការ ២០២១។

មានមូលហេតុសមស្របណាមួយដែលមជ្ឈត្តករដទៃទៀតមិនចុះហត្ថលេខា ស្នាមហត្ថលេខារបស់មជ្ឈត្តករភាគច្រើនត្រូវចាត់ទុកថាគ្រប់គ្រាន់។[133] ម្យ៉ាងវិញទៀត អគ្គលេខាធិការដ្ឋានត្រូវតែមានការទទួលខុសត្រូវពេញលេញចំពោះឯកសារទាំងស្រុងនៃសំណុំរឿង។[134]

### ៣.៤.៣. ការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ

នៅពេលដែលមានការទូទាត់សាច់ប្រាក់រួចរាល់អស់ហើយ មជ្ឈត្តវិនិច្ឆ័យត្រូវបោះត្រា ម.ជ.ម. ពីអគ្គលេខាធិការដ្ឋាន ដែលត្រូវចុះហត្ថលេខាដោយមជ្ឈត្តករជាច្រើន និងជាលាយលក្ខណ៍អក្សរ ដោយមិនមានការខកខាននិងយឺតយ៉ាវឡើយ ដោយត្រូវស្របតាមទម្រង់មជ្ឈត្តវិនិច្ឆ័យ ហើយបន្ទាប់មកក៏ត្រូវបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់។ ជាងនេះទៀតសោត មជ្ឈត្តវិនិច្ឆ័យត្រូវរួមបញ្ចូលសេចក្តីសម្រេចលើអង្គហេតុ និងសេចក្តីសន្និដ្ឋានលើអង្គច្បាប់។[135]

ភាគច្រើននៅក្នុងមជ្ឈមណ្ឌលអន្តរជាតិ ការចេញមជ្ឈត្តវិនិច្ឆ័យដោយវេទិការមជ្ឈត្តកម្មគឺមានភ្ជាប់ជាការបញ្ជាក់ហេតុផលត្រឹមត្រូវ ដែលនេះជាគុណសម្បត្តិដល់គូភាគី ក្នុងការស្វែងយល់កាន់តែច្បាស់ស្តីពីសេចក្តីសម្រេច ហើយអាចនឹងមិនមានការតវ៉ាអំពីអព្យាក្រឹត្យភាព ឬភាពយុត្តិធម៌ ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានគុណវិបត្តិក្នុងនោះដែរ បើគូភាគីណាម្នាក់មានគំនិតចង់គេចវេសអំពីសេចក្តីសម្រេចមជ្ឈត្តវិច្ឆ័យ គឺវាអាចក្លាយជាមូលដ្ឋានសក្តានិភូតសម្រាប់អោយតុលាការពិនិត្យឡើងវិញ។[136]

ក្រោយការចេញមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ជាធម្មតាថ្លៃចំណាយផ្សេងៗ និងថ្លៃសាហ៊ុយ ភាគីនីមួយៗត្រូវតែជាអ្នករ៉ាប់រងរបស់ខ្លួន ព្រមទាំងធ្វើការចេញស្មើៗគ្នានូវកម្រៃមជ្ឈត្តករ និងកិច្ចការរដ្ឋបាលរបស់មជ្ឈត្តការ។ ប៉ុន្តែប្រសិនបើ គូភាគីចង់លើកទឹកទឹកចិត្តឲ្យមានដំណោះស្រាយមុនធ្វើមជ្ឈត្តការ ពួកគេអាចយល់ព្រមប្រគល់ថ្លៃមេធាវី ថ្លៃចំណាយ និងវិក្កយបត្រមជ្ឈត្តការប្រគល់អោយទៅភាគីដែលឈ្នះនៅក្នុងមជ្ឈត្តការ។[137]

---

[133] ប្រការ៤៩.៣. វិធានស្តីពីមជ្ឈត្តការ ២០២១។

[134] ប្រការ៥៣.៤. វិធានស្តីពីមជ្ឈត្តការ ២០២១។

[135] មេធាវីស៊ីវិន អ៊ែម អូស្ទើរមីឡើរ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៧៦ បោះពុម្ព ឆ្នាំ ២០០៩។

[136] គេហទំព័រ បណ្ណាល័យតម្រាច្បាប់ មជ្ឈត្តកម្ម https://www.insidercambodia.asia/file (ចូលទស្សនានៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣)។

[137] ប្រការ ៥១ វិធានស្តីពីមជ្ឈត្តការ ២០២១។

## ៣.៤.៤. អានុភាពមជ្ឈត្តវិនិច្ឆ័យ

ចាប់តាំងពីកាលបរិច្ឆេទនៃមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញនិងបោះត្រា មជ្ឈត្តវិនិច្ឆ័យនោះនឹងក្លាយជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ និងមានអានុភាពអនុវត្តចំពោះគូភាគីវិវាទដោយមិនមានការបង្អង់ឡើយ។[138]

ប៉ុន្តែបើសិនជា ភាគីណាបានដឹងថាមជ្ឈត្តវិនិច្ឆ័យមានពិរុទ្ធដែលបញ្ញត្តិគ្រប់គ្រងមជ្ឈត្តការមិនមានការចាប់បង្ខំតាមផ្លូវច្បាប់ ឬក៏ការព្រមព្រៀងក្នុងតម្រូវការណាមួយមិនត្រូវបានគោរព ឬវិធានស្តីពីមជ្ឈត្តការត្រូវបានប្រាសចាក តែភាគីវិវាទនៅតែបន្តមជ្ឈត្តការនោះក្នុងថេរវេលាដែលបានកំណត់ គឺត្រូវបានសន្មតថា ភាគីនោះធ្វើការបោះបង់សិទ្ធិក្នុងការប្តឹងជំទាស់ហើយ។[139] ម្យ៉ាងវិញទៀត ក្នុងលក្ខណៈដែលគូភាគីមានជម្រើសក្នុងការប្តឹងឧបាស្រ័យបាន ប៉ុន្តែបែរជាមិនទទួលជម្រើសនេះ ហើយគូភាគីបែបជាទៅយល់ព្រមអនុវត្តមជ្ឈត្តវិនិច្ឆ័យភ្លាមៗដោយមិនបង្អង់ គឺបង្ហាញថាភាគីធ្វើការបោះសិទ្ធិប្តឹងជំទាស់ផងដែរ។

ប្រសិនបើភាគីពិតជាចង់ធ្វើការប្តឹងឧបាស្រ័យទៅលើសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ឬការតែងតាំង ការជំទាស់ ការបញ្ចប់ ការខកខានក្នុងការបំពេញមុខងាររបស់មជ្ឈត្តករ យុត្តាធិការរបស់តុលាការ ត្រូវអនុវត្តដោយតុលាការដែលមានតុលាការកំពូល សាលាឧទ្ធរណ៍ តុលាការពាណិជ្ជកម្ម ឬមជ្ឈមណ្ឌលមជ្ឈត្តការជាតិ។[140] ប៉ុន្តែដោយសារខ្លឹមសារត្រង់មាត្រានេះមានភាពមិនច្បាស់លាស់ និងមិនស៊ីសង្វាក់គ្នា ការភ័ន្តច្រលំអាចកើតមានដូច្នេះជាជម្រើសល្អបំផុតនោះ បើភាគីចង់ស្វែងរកជំនួយត្រួតពិនិត្យពីអង្គតុលាការ គឺធ្វើការដាក់ញត្តិទៅសាលាឧទ្ធរណ៍។[141]

[138] ប្រការ ៥២ វិធានស្តីពីមជ្ឈត្តការ ២០២១។

[139] ប្រការ ៦៨ វិធានស្តីពីមជ្ឈត្តការ ២០២១។

[140] មាត្រា៦ ច្បាប់មជ្ឈត្តការ ២០០៦។

[141] មេធាវីស៊្រីវិន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ទំ.១៧៩ បោះពុម្ព ឆ្នាំ ២០០៩។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីការឆ្លងកាត់ការស្រាវជ្រាវ និងបកស្រាយពីប្រធានបទនេះរួចហើយ នាំឱ្យមានការយល់ដឹង និងអាចសន្និដ្ឋានបានថា ប្រទេសកម្ពុជាមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវមានឡើងតាមពីក្នុងអំឡុងទសវត្សរ៍ទី ១៩៧០។ នៅប្រទេសឯនាយសមុទ្រ ភាពល្បីល្បាញនៃការដោះស្រាយវិវាទនេះមាននៅដើមសតវត្សទី២០ ដោយរដ្ឋនានា ចាត់ទុកថាជាជម្រើសប្រព័ន្ធទីមួយនៃការដោះស្រាយវិវាទឱ្យកាន់តែឆាប់រហ័ស និងមានប្រសិទ្ធិភាពខ្ពស់។

សារៈសំខាន់នៃដំណោះស្រាយក្រៅប្រព័ន្ធតុលាការ មានអំណោយផលយ៉ាងគាប់ប្រសើរជុំវិញពិភពលោកដែលជាហេតុនាំអោយមានចាប់អារម្មណ៍ ពីរាជរដ្ឋាភិបាលកម្ពុជានូវនីតិវិធីនេះ ហើយបានពង្រឹងនូវភាពប្រសើរឡើងក្នុងវិស័យយុត្តិធម៌ និងលើកទឹកចិត្តអោយមានការបង្កើតឡើងនូវមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលហៅកាត់ថា ម.ជ.ម. នេះឡើង។ ផលប្រយោជន៍មានច្រើនហូរហែរមកជាបន្តបន្ទាប់អំពីការបង្កើតស្ថាប័ននេះ ហើយបច្ចុប្បន្ននេះ ស្ថាប័ននេះជាវិធីសាស្ត្រមួយដែលទទួលការស្ងើចសរសើរ និងមានពេញចិត្តពីសំណាក់អ្នកវិនិយោគ ពាណិជ្ជករ ជាជាងការប្រើប្រាស់ប្រព័ន្ធតុលាការ និងគ្មានការជំទាស់ឡើយពីសេចក្ដីសម្រេចដែលបានដាក់ចេញដោយម.ជ.ម.។ ដោយហេតុថា ការដោះស្រាយវិវាទនៅក្នុងប្រព័ន្ធតុលាការត្រូវចំណាយខ្ពស់ ផ្តល់នូវភាពបត់បែន និងរក្សាការសម្ងាត់នាំអោយមានការគាំទ្រភាគច្រើន។ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ក៏ជាមធ្យោបាយដ៏ល្អសម្រាប់ពាណិជ្ជករ រួមមាន ការចរចា ការផ្សះផ្សា សន្ទានកម្ម និងមជ្ឈត្តកម្ម។ មុននឹងឈានដល់ដំណាក់កាលមជ្ឈត្តការ ភាគីវិវាទ អាចព្យាយាមធ្វើការដោះស្រាយវិវាទរបស់ពួកគេតាមការចរចា ការផ្សះផ្សា ឬសន្ទានកម្ម ទៅតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីរក្សាទំនាក់ទំនងរវាងគូភាគី។

ដំណើរការមជ្ឈត្តកម្មចាប់ផ្តើម ពេលដែលភាគីឆ្លើយតប បានដាក់បញ្ហាវិវាទឱ្យធ្វើការដោះស្រាយតាមផ្លូវមជ្ឈត្តការដោយភាគីទទួលទាមទារ។ ជំហានបន្ទាប់ទៀត ភាគីវិវាទត្រូវធ្វើការតែងតាំងមជ្ឈត្តករ ជ្រើសរើសទីកន្លែង ភាសា និងច្បាប់កំណត់របស់ភាគី។ នៅក្រោយពេលដែលចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមានសិទ្ធិអំណាចលើកសេចក្តីសម្រេចនេះ ដោយអាចយកទៅអនុវត្តនៅបណ្តាប្រទេសជាង១៦០ដែលជាសមាជិកនៃអនុសញ្ញាទីក្រុងញូវយ៉ក (NYC)។

ជាងនេះទៅទៀត សេចក្តីសម្រេចរបស់មជ្ឈត្តករអាចធ្វើការប្តឹងឧបាស្រ័យ នៅពេលមានភាគីណាមិនពេញចិត្តចំពោះមជ្ឈត្តវិនិច្ឆ័យនោះបានពីម.ជ.ម.ទៅ។ សេចក្តីសម្រេចពីមជ្ឈមណ្ឌលមជ្ឈត្តការពីបរទេស ក៏អាចមានសិទ្ធិក្នុងការធ្វើការប្តឹងឧបាស្រ័យនៅសាលាឧទ្ធរណ៍នៃដែនដីព្រះរាជាណាចក្រកម្ពុជាដែរ ដោយតុលាការ

មើលតែនីតិវិធីនោះទេ មិនមែនសំណុំអង្គហេតុនោះឡើយ។ មិនតែប៉ុណ្ណោះ ច្បាប់កម្ពុជាការមានាការទទួលស្គាល់សេចក្តីសម្រេចពីបណ្តោរដ្ឋសមាជិកដែលស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

យើងខ្ញុំបានពិនិត្យពិចារណាឃើញចំណុចខ្លះគួរឱ្យចាប់អារម្មណ៍ ក្នុងកំឡុងពេលធ្វើកិច្ចការស្រាវជ្រាវសិក្សាពីប្រធានបទលើកឡើងនេះ។ ជាការពិតណាស់ ប្រទេសកម្ពុជា មានការអភិវឌ្ឍរហូតមកដល់សព្វថ្ងៃនេះទៅលើគ្រប់វិស័យទាំងអស់ ដូចជាវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលមានអាត្រាកំណើនគួរអោយកត់សម្គាល់នៃអ្នកវិនិយោគបរទេសនិងពាណិជ្ជករខ្មែរ ដែលអាចនាំអោយកម្ពុជាឈានទៅដល់ភាពរុងរឿងជាបន្តបន្ទាប់។ ជាពិសេសកម្ពុជាផ្តល់សច្ចា មានការអភិវឌ្ឍទៅលើច្បាប់ដើម្បីគ្រប់គ្រង និងដឹកនាំគ្រប់ផ្នែកទាំងអស់របស់រដ្ឋ ដែលក្នុងនោះមានច្បាប់មជ្ឈត្តការកម្ពុជា និងវិធានមជ្ឈត្តការជាអាទិ៍។ ក៏ប៉ុន្តែ ដោយសារតែកម្ពុជាទើបតែងើបពីផ្នួកភ្លើងសង្គ្រាម បាត់បង់អ្នកប្រាជ្ញបញ្ញាវន្តជាច្រើនរូប ការរៀបចំច្បាប់និងវិធានមានចន្លោះខ្វះខាត នៅមានកម្រិត និងនៅមានភាពមិនទាន់ជឿនលឿនដូចប្រទេសដទៃ។

ដើម្បីបង្កើន និងពង្រឹងនូវសេចក្តីទុកចិត្ត គុណភាព សមត្ថភាព តម្លាភាព មានការទទួលស្គាល់ពីអន្តរជាតិ យើងខ្ញុំសូមលើកមតិពិចារណានូវចំណុចមួយចំនួនជូនរាជរដ្ឋាភិបាល និងមជ្ឈមណ្ឌល ដូចខាងក្រោម

- ធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មជ្ឈត្តករទាំងអស់អោយមានជំនាញច្បាស់លាស់ និងមានក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ក្នុងការបំពេញភារកិច្ច។
- បញ្ចូលកម្មវិធីសិក្សា ទៅក្នុងបរិញ្ញាបត្រច្បាប់ខ្មែរ និងបង្កើតសក្ខាសាលានៅតាមសកលវិទ្យាល័យ
- បង្កើតនូវវគ្គបណ្តុះបណ្តាលបន្ថែមលើដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជារួមមាន ការចរចា ការផ្សះផ្សា សន្ធានកម្ម មជ្ឈត្តកម្ម ដល់សាធារណៈជនទូទៅ។
- មជ្ឈត្តករត្រូវរក្សានូវភាពស្មោះត្រង់ យុត្តិធម៌ ឯករាជ្យភាព របស់ខ្លួន ដើម្បីរក្សានូវគុណតម្លៃរបស់មជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន។
- ផ្សព្វផ្សាយវីដេអូអប់រំពីការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជាដើម្បីឱ្យប្រជាពលរដ្ឋមានចំណេះដឹងអំពីវិស័យមួយនេះ។
- មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវធ្វើការគ្រប់គ្រងតម្លៃនៅក្នុងដំណើរការមជ្ឈត្តកម្មឱ្យមានតម្លៃសមរម្យ ដែលអាចធានាថាពាណិជ្ជករទូទៅអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទរបស់ពួកគេបានតាមរយៈយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- រដ្ឋាភិបាលក៏ត្រូវធានាថាការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្មមានភាពឆាប់រហ័ស និងមានប្រសិទ្ធិភាពដល់ភាគីវិវាទទាំងពីរក្នុងការយកទៅអនុវត្តន៍ទាំងក្នុងប្រទេស និងទៅអន្តរជាតិ។

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គួរតែលើកទឹកចិត្ត និងដាក់ចេញនូវគោលនយោបាយ ដើម្បីជំរុញឱ្យសាធារណជនយល់ និងកាន់តែស្គាល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅ ប្រទេសកម្ពុជាឱ្យបានកាន់តែច្រើន តាមរយៈការផ្សព្វផ្សាយអំពីដំណើរការដោះស្រាយទាំងបួនដល់ ប្រជាពលរដ្ឋឱ្យមានការស្គាល់ និងយល់ដឹងកាន់តែច្បាស់ពីសារៈសំខាន់របស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាដើម្បីទទួលបានការគាំទ្រ និងជឿទុកចិត្តកាន់តែខ្លាំងពីសំណាក់សាធារណជនទាំងក្នុងស្រុក និងក្រៅស្រុក។

# ឯកសារយោង

# ឯកសារយោង

## ក. បទដ្ឋានគតិយុត្ត

- ច្បាប់ស្ដីពីមជ្ឈត្តកម្ម ២០០៦។
- ច្បាប់ស្ដីពីមជ្ឈត្តការរដ្ឋសហព័ន្ធ ១៩៧០។
- អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ២០០៩។
- វិធានផ្សះផ្សាUNCITRAL។
- វិធានស្ដីពីមជ្ឈត្តការ ២០២១។
- បទបញ្ជាផ្ទៃក្នុង ២០២១។

## ខ. សៀវភៅ និងគេហទំព័រ

- សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗរបស់ USAID/CAMBODIA ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា។
- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- Essentials of Alternative Dispute Resolution។
- Arbitration: Essential Concepts។
- គេហទំព័រ សភាពាណិជ្ជកម្មអន្តរជាតិhttp://www.iccwbo.org/policy/arbitration/id2882/index.html។
- គេហទំព័រ តុលាការមជ្ឈត្តការអន្តរជាតិក្រុងឡុងដ៍ មាននៅ http://www.lcia-arbitration.com/។
- គេហទំព័រ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មនៅកម្ពុជា https://ncac.org.kh/km/services/arbitration។
- គេហទំព័រ កម្ពុជាមានសន្ទានការីពាណិជ្ជកម្ម ១៦ រូបថ្មីត្រូវបានទទួលស្គាល់ ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម https://www.postkhmer.com/business/2022-03-10-1129-233105.html។
- គេហទំព័រ Overview of Cambodian Alternative Dispute Resolution System https://cacj-ajp.org/cambodia/legal-system/overview-of-cambodian-alternative-dispute-resolution-system/#:~:text=Cambodia%20ratified%20the%20New%20York,10%20dated%2023%20July%202001។
- គេហទំព័រ ច្បាប់គម្រូ UNCITRAL ស្ដីមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០០៦ UNCITRAL https://uncitral.un.org/sites/uncitral.un.org/files/media-documents/uncitral/en/06-54671_ebook.pdf ។

- គេហទំព័រ London High Court, *Fiona Trust v. Privalov (2015)n*

  http://www.nadr.co.uk/articles/published/ArbitLRe/Fiona%20v%20Privalov%202007.pdf។

- គេហទំព័រ About the Arbitration Clause

  https://ouchvutthy.files.wordpress.com/2012/07/arbitration-clause.pdf ។

- គេហទំព័រ អំពីខចែងពីមជ្ឈត្តការ www.ouchvutthy.wordpress.com។
- គេហទំព័រ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម https://www.theseedcambodia.com/article/6063/។
- គេហទំព័រ បណ្ណាល័យតម្រាច្បាប់ មជ្ឈត្តកម្ម

  https://www.insidercambodia.asia/files/%E1%9E%98%E1%9E%87%E1%9F%92%E1%9E%88%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98.pdf។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១**

# គំរូ ខចែងអំពីមជ្ឈត្តការរបស់ ម.ជ.ម.

វាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ ចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការ ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករ ចំនួន_________**រូប។

ភាសានៃមជ្ឈត្តការគឺ _______________ ។

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ_______________***។

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស ]")។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។



| លក្ខណៈ | ការចរចារ | សន្ទានកម្ម | មជ្ឈត្តកម្ម | តុលាការ |
|---|---|---|---|---|
| ស្ម័គ្រចិត្ត/ចាប់បង្ខំ | ស្ម័គ្រចិត្ត | ស្ម័គ្រចិត្ត តែក៏មានករណីដែលភាគីត្រូវចូលរួមដោយចាប់បង្ខំដែរ (mandatory mediation) | ស្ម័គ្រចិត្ត (នៅពេលធ្វើតាមប្រការនៃកិច្ចសន្យា គឺក្លាយជាចាប់បង្ខំ) | ចាប់បង្ខំ |
| ចងភ្ជាប់កាតព្វកិច្ច/មិនចងភ្ជាប់កាតព្វកិច្ច | ប្រសិនបើឈានដល់កិច្ចសន្យាសះជា អាចអនុវត្តបានដូចកិច្ចសន្យា | ប្រសិនបើឈានដល់កិច្ចសន្យាសះជា អាចអនុវត្តបានដូចកិច្ចសន្យា ហើយករណីខ្លះត្រូវបានទទួលស្គាល់អានុភាពអនុវត្តដូចសេចក្តីសម្រេចតុលាការដោយច្បាប់ | ចងភ្ជាប់កាតព្វកិច្ច ហើយអាចត្រូវបានពិនិត្យឡើងវិញ ក្នុងករណីតិចតួចបំផុត | ចងភ្ជាប់កាតព្វកិច្ច ហើយអាចប្តឹងឧទ្ធរណ៍បាន |
| តតិយជន | គ្មានការសម្របសម្រួលពីតតិយជន | គូភាគីជ្រើសរើសតតិយជនដើម្បីសម្របសម្រួល | គូភាគីជ្រើសរើសអ្នកមានសមត្ថកិច្ចសម្រេចសេចក្តីដែលមានជំនាញបច្ចេកទេស | គូភាគីគ្មានសិទ្ធិជ្រើសរើសអ្នកអព្យាក្រិតសម្រាប់សម្រេចសេចក្តី ហើយជានិច្ចកាល បុគ្គលនោះគ្មានជំនាញបច្ចេកទេសពាក់ព័ន្ធនឹងប្រភេទនៃវិវាទឡើយ |
| កម្រិតនៃបែបបទ | ជាទូទៅ មិនមានបែបបទផ្លូវការ មិនមានទម្រង់ច្បាស់លាស់ | ជាទូទៅមិនមានបែបបទផ្លូវការ តែផ្នែកខ្លះមានទម្រង់ច្បាស់លាស់ | នីតិវិធីមានបែបបទតិចជាងតុលាការ វិធានសម្រាប់នីតិវិធី និងច្បាប់សារធាតុអាចត្រូវបានកំណត់ដោយគូភាគី | មានបែបបទ និងមានទម្រង់ច្បាស់លាស់ ដែលកំណត់ដោយវិធានតឹងរឹងដែលមានស្រាប់ |
| លក្ខណៈនៃនីតិវិធី | មិនមានកាតព្វកិច្ចបង្ហាញកស្តុតាង អំណះអំណាង និងផលប្រយោជន៍ | មិនមានកាតព្វកិច្ចបង្ហាញកស្តុតាង អំណះអំណាង និងផលប្រយោជន៍ | ឱកាសសម្រាប់គូភាគីបង្ហាញកស្តុតាង អំណះអំណាង និងផលប្រយោជន៍ | ឱកាសសម្រាប់គូភាគីបង្ហាញកស្តុតាង អំណះអំណាង និងផលប្រយោជន៍ |
| លទ្ធផល | ការព្រមព្រៀងដែលគូភាគីស្វែងរកនិងទទួលយក។ | ការព្រមព្រៀងដែលគូភាគីស្វែងរកនិងទទួលយក។ | ជួនកាលការសម្រេចសេចក្តីដែលមានសំអាងហេតុ និងជួនកាលការសះជាដែលគ្មានសំអាងហេតុ | ការសម្រេចសេចក្តីដែលមានសំអាងហេតុ។ កម្រមានការសះជាដែលគ្មានសំអាងហេតុណាស់ |
| ទិសដៅដំណោះស្រាយ | គិតដល់អនាគត | គិតដល់អនាគត | គិតដល់អតីតកាល | គិតដល់អតីតកាល |
| ឯកជន/សាធារណៈ | ឯកជន | ឯកជន | ឯកជន លើកលែងមានការត្រួតពិនិត្យឡើងវិញដោយតុលាការ | សាធារណៈ |

# តារាងកម្រៃសេវារបស់ ម.ជ.ម.

## គណនាកម្រៃសេវា

| | |
|---|---|
| ទឹកប្រាក់វិវាទ: | 0 |
| ចំនួនមជ្ឈត្តករ: | 1 |
| កម្រៃសេវាវេទិកាមជ្ឈត្តកម្ម: | 0 |
| កម្រៃសេវារដ្ឋបាល: | 0 |
| កម្រៃសេវាសរុប: | 0 |

## កម្រៃសេវាចុះបញ្ជីសំណុំរឿង

1. នៅពេលដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬបណ្តឹងតប ភាគីប្តឹងទាមទារ ឬភាគីប្តឹងទាមទារនៃបណ្តឹងតបនោះត្រូវបង់រៀងៗខ្លួននូវកម្រៃសេវាចុះបញ្ជីសំណុំរឿងចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការចុះបញ្ជីការទាមទារ ឬបណ្តឹងតបនោះ។
2. ប្រសិនបើភាគីប្តឹងទាមទារ ឬភាគីប្តឹងទាមទារនៃបណ្តឹងតប ខកខានក្នុងការបង់កម្រៃសេវាចុះបញ្ជី ម.ជ.ម. នឹងមិនចាប់ដំណើរការមជ្ឈត្តកម្មដោះស្រាយការទាមទារ ឬបណ្តឹងតបនោះ នោះទេ។
3. កម្រៃសេវាចុះបញ្ជីសំណុំរឿងមិនអាចត្រូវបានបង់សងវិញទេ។

## កម្រៃសេវាតែងតាំងមជ្ឈត្តករ

1. ភាគីវិវាទត្រូវបង់កម្រៃសេវាចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការតែងតាំងមជ្ឈត្តករមួយរូបដែលធ្វើឡើងដោយ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង និងនិតិវិធី នៅពេលដែលភាគីវិវាទ ឬគូភាគីវិវាទ បានតែងតាំង ខកខានក្នុងការតែងតាំងមជ្ឈត្តករ ឬមជ្ឈត្តករដែលគូភាគីបានតែងតាំង ខកខានក្នុងការតែងតាំងប្រធានវេទិកាមជ្ឈត្តកម្ម ស្របតាមវិធានស្តីពីមជ្ឈត្តកម្ម របស់ ម.ជ.ម. ហើយ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង និងនិតិវិធី ត្រូវបានស្នើ ឬតម្រូវឱ្យធ្វើការតែងតាំងមជ្ឈត្តករ។
2. កម្រៃសេវាតែងតាំងមជ្ឈត្តករ ត្រូវអនុវត្តចំពោះសំណុំរឿងដែលចាត់ចែងដោយ ម.ជ.ម. ឬក្នុងសំណុំរឿងពិសេស ដែលទាមទារឱ្យគណៈកម្មាធិការតែងតាំង និងនិតិវិធីតែងតាំងមជ្ឈត្តករស្របតាមវិធានស្តីពីមជ្ឈត្តកម្ម របស់ ម.ជ.ម. ឬក្នុងករណីដែលសំណើសុំឱ្យមានការតែងតាំងមជ្ឈត្តករត្រូវបានបញ្ជូនទៅអគ្គលេខាធិការដ្ឋាន។
3. កម្រៃសេវាតែងតាំងមជ្ឈត្តករនេះមិនត្រូវបានអនុវត្តលើការតែងតាំងមជ្ឈត្តករជំនួសណាមួយឡើយ ក្នុងករណីដែលមជ្ឈត្តករត្រូវបានជំនួសដូចមានចែងក្នុងប្រការ ៣០ ((*ការដាក់មជ្ឈត្តករជំនួស*) ត្រូវបានតែងតាំងដោយគណៈកម្មាធិការតែងតាំង និងនិតិវិធី។
4. សម្រាប់សំណុំរឿងពិសេស កម្រៃសេវាតែងតាំងមជ្ឈត្តករត្រូវផ្ទេរចូលគណនីដែលកំណត់ដោយ ម.ជ.ម. មុនពេលចាប់ផ្តើមការតែងតាំង។
5. កម្រៃសេវាតែងតាំងមជ្ឈត្តករមិនអាចត្រូវបានបង់សងវិញឡើយ។

## កម្រៃសេវាវេទិកាមជ្ឈត្តកម្ម

1. កម្រៃសេវាវេទិកាមជ្ឈត្តកម្ម ត្រូវយោងតាមកម្រិតនៃកម្រៃសេវាដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។
2. តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃនៃរាល់ការទាមទារ និងបណ្ដឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវារដ្ឋបាល ប្រសិនការកាត់កងតាមការដោះសានោះ បណ្ដាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។
3. កម្រៃសេវាវេទិកាមជ្ឈត្តកម្មនៃសំណុំរឿងនីមួយៗ ត្រូវបានកែប្រែដោយអគ្គលេខាធិការដ្ឋាន ដោយពិចារណាទៅលើកាលៈទេសៈណាមួយដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផល ក្នុងការបន្ថយ ឬដំឡើងកម្រៃសេវារដ្ឋបាល ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែលម.ជ.ម. ត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬមានការងារបន្ថែម ដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញពាក់ព័ន្ធនឹងសំណើជាបន្តបន្ទាប់នានាសម្រាប់វិធានការបណ្ដោះអាសន្ន ការជំទាស់ទៅនឹងមជ្ឈត្តករ ឬទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។ ការដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម មិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវាវេទិកាមជ្ឈត្តកម្មដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ម.ជ.ម. ឡើយ។

## កម្រៃសេវារដ្ឋបាល

1. កម្រៃសេវារដ្ឋបាលត្រូវយោងតាមកម្រិតនៃកម្រៃសេវា ដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។
2. តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃកម្មវត្ថុនៃរាល់ការទាមទារ និងបណ្ដឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវារដ្ឋបាល ប្រសិនការដោះសាតាមការកាត់កងនោះ បណ្ដាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។
3. កម្រៃសេវារដ្ឋបាលនៃសំណុំរឿងនីមួយៗ អាចនឹងត្រូវបានកែប្រែដោយអគ្គលេខាធិការដ្ឋាន ដោយពិចារណាទៅលើកាលៈទេសៈណាមួយដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផល ក្នុងការបន្ថយ ឬដំឡើងកម្រៃសេវារដ្ឋបាល ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែលម.ជ.ម. ត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬសេវាកម្មផ្សេងៗ ដែលម.ជ.ម. ត្រូវផ្ដល់បន្ថែម។ ការដំឡើងកម្រៃសេវារដ្ឋបាល មិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ម.ជ.ម. នោះទេ។

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវារដ្ឋបាល | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | 50,000 | | | | 750 | | | | |
| ចាប់ពី | 50,001 | ដល់ | 100,000 | = | 1500 | + | 0.80% | នៃចំនួនដែលលើសពី | 50,000 |
| ចាប់ពី | 100,001 | ដល់ | 500,000 | = | 1,900 | + | 0.70% | នៃចំនួនដែលលើសពី | 100,000 |
| ចាប់ពី | 500,001 | ដល់ | 1,000,000 | = | 4,700 | + | 0.50% | នៃចំនួនដែលលើសពី | 500,000 |
| ចាប់ពី | 1,000,001 | ដល់ | 3,000,000 | = | 7,200 | + | 0.20% | នៃចំនួនដែលលើសពី | 1,000,000 |
| ចាប់ពី | 3,000,001 | ដល់ | 5,000.000 | = | 11,200 | + | 0.12% | នៃចំនួនដែលលើសពី | 3,000,000 |
| ចាប់ពី | 5,000,001 | ដល់ | 10,000,000 | = | 13,600 | + | 0.08% | នៃចំនួនដែលលើសពី | 5,000,000 |
| ចាប់ពី | 10,000,001 | ដល់ | 50,000,000 | = | 17,600 | + | 0.04% | នៃចំនួនដែលលើសពី | 10,000,000 |
| លើសពី | 50,000,000 | | | = | 33,600 | | | | |

| | តម្លៃកម្មវត្ថុនៃវិវាទ | | | | កម្រៃសេវាវេទិកាមជ្ឈត្តកម្ម (សម្រាប់មជ្ឈត្តករមួយរូប) | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | 50,000 | | | = | 1,000 | | | | |
| ចាប់ពី | 50,001 | ដល់ | 100,000 | = | 2,750 | + | 2% | នៃចំនួនដែលលើសពី | 50,000 |
| ចាប់ពី | 100,001 | ដល់ | 500,000 | = | 3,750 | + | 1.7% | នៃចំនួនដែលលើសពី | 100,000 |
| ចាប់ពី | 500,001 | ដល់ | 1,000,000 | = | 10,550 | + | 1.5% | នៃចំនួនដែលលើសពី | 500,000 |
| ចាប់ពី | 1,000,001 | ដល់ | 3,000,000 | = | 18,050 | + | 0.75% | នៃចំនួនដែលលើសពី | 1,000,000 |
| ចាប់ពី | 3,000,001 | ដល់ | 5,000,000 | = | 33,050 | + | 0.50% | នៃចំនួនដែលលើសពី | 3,000,000 |
| ចាប់ពី | 5,000,001 | ដល់ | 10,000,000 | = | 43,050 | + | 0.30% | នៃចំនួនដែលលើសពី | 5,000,000 |
| ចាប់ពី | 10,000,001 | ដល់ | 50,000,000 | = | 58,050 | + | 0.15% | នៃចំនួនដែលលើសពី | 10,000,000 |
| លើសពី | 50,000,000 | | | = | 118,050 | | 0.075% | នៃចំនួនដែលលើសពី | 50,000,000 |

## កាលបរិច្ឆេទសុពលភាព

1. តារាងកម្រៃសេវារបស់ម.ជ.ម. នេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ម.ជ.ម. នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។
2. តារាងកម្រៃសេវារបស់ម.ជ.ម. នេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅ។

**សម្គាល់៖** កម្រៃសេវាដូចមានកំណត់ខាងលើមិនរាប់បញ្ចូលការចំណាយផ្សេងៗ របស់ ម.ជ.ម. វេទិការមជ្ឈត្តកម្ម និងមជ្ឈត្តករបន្ទាន់ ក៏ដូចជាអាករលើតម្លៃបន្ថែម លើកម្រៃសេវារដ្ឋបាលរបស់ ម.ជ.ម. និងពន្ធកាត់ទុកលើសេវារបស់មជ្ឈត្តករឡើយ។ មុនពេលបង្កើតវេទិការមជ្ឈត្តកម្ម គូភាគីវិវាទអាចព្រមព្រៀងផ្សេងពីនេះលើកម្រៃសេវាវេទិការមជ្ឈត្តកម្ម ប្រសិនបើវេទិការមជ្ឈត្តកម្មឯកភាពចំពោះកម្រៃសេវាដែលព្រមព្រៀងនោះ។

**ឧបសម្ព័ន្ធ២.**

## ផ្នែកទី I : វិធានផ្តើម

ដែនកំណត់នៃការអនុវត្តន៍ (មាត្រា ១) និងខគម្រូស្តីពីមជ្ឈត្តការ

ការជូនដំណឹង ការគណនាពេលវេលា (មាត្រា ២)

ការជូនដំណឹងអំពីមជ្ឈត្តការ (មាត្រា ៣)

តំណាង និងជំនួយ (មាត្រា ៤)

## ផ្នែកទី II : សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

ចំនួនមជ្ឈត្តករ ( មាត្រា ៥)

ការតែងតាំងមជ្ឈត្តករ ( មាត្រា ៦ ដល់ ៨)

ការជំទាស់ទៅនឹងមជ្ឈត្តករ ( មាត្រា ៩ ដល់ ១២)

ការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៣ )

ការធ្វើសវនាការឡើងវិញក្នុងករណីមានការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៤ )

## ផ្នែកទីIII : និតិវិធីមជ្ឈត្តការ

បទប្បញ្ញត្តិទូទៅ ( មាត្រា ១៥)

ទីកន្លែងធ្វើមជ្ឈត្តការ ( មាត្រា ១៦ )

ភាសា ( មាត្រា ១៧ )

បណ្តឹងទាមទារ ( មាត្រា ១៨ )

បណ្តឹងដោះសា ( មាត្រា ១៩ )

ការកែប្រែលើបណ្តឹងទាមទារ ឬ ដោះសា ( មាត្រា ២០)

ការជំទាស់ចំពោះសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម ( មាត្រា ២១)

បណ្តឹងលាយលក្ខណ៍អក្សរបន្ថែមដទៃទៀត ( មាត្រា ២២ )

ថេរៈវេលាផ្សេងៗ ( មាត្រា ២៣ )

ភស្តុតាង និងសវនាការ ( មាត្រា ២៤ និង ២៥ )

វិធានការណ៏បណ្តោះអាសន្នដើម្បីការពារ ( មាត្រា ២៦ )

ជំនាញការ ( មាត្រា ២៧ )

ការខកខាន ( មាត្រា ២៨ )

ការបិទសវនាការ ( មាត្រា ២៩ )

ការលើកលែងចំពោះវិធានផ្សេងៗ ( មាត្រា ៣០ )

## **ផ្នែកទី** IV : **មជ្ឈត្តវិនិច្ឆ័យ**

ការសម្រេចផ្សេងៗ ( មាត្រា ៣១ )

ទម្រង់ និងអានុភាពនៃមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣២ )

ប្រព័ន្ធច្បាប់សម្រាប់អនុវត្ត ការស្រុះស្រួល (*umiable compositer)* ( មាត្រា ៣៣ )

ការស្រុះស្រួល ឬមូលដ្ឋានដទៃទៀតដើម្បីបញ្ចប់វិវាទ ( មាត្រា ៣៤ )

ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៥)

កំណែតម្រូវលើមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៦ )

មជ្ឈត្តវិនិច្ឆ័យបន្ថែម ( មាត្រា ៣៧)

ថ្លៃចំណាយផ្សេងៗ ( មាត្រា ៣៨ ទៅ ៤០)

ការតម្កល់ប្រាក់ចំណាយ ( មាត្រា៤១)

**ឧបសម្ព័ន្ធ៣**



មាត្រា ៥.–

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណាដែលច្បាប់នេះបានចែង ។

មាត្រា ៦.–

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២

## កិច្ចព្រមព្រៀងផ្សះផ្សា

មាត្រា ៧.–

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ញើរលិខិតឆ្លាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យានិង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបានល្លឹកណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

មាត្រា ២៥.–

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦

## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

មាត្រា ២៦.–

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

មាត្រា ២៧.–

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

14/2rk

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

**មាត្រា ២៨.-**

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ គឺវេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកាស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬឯកសារដទៃទៀត ។

**មាត្រា ២៩.-**

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

**មាត្រា ៣០.-**

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

17/28N

**មាត្រា ៣១.–**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬ បំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសាររបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.–**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែបើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវ-នាការ ។

ត្រូវជូនដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ ក៏ការប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈ-ត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

**មាត្រា ៣៣.-**

វៀរលែងតែភាគីវិវាទ បានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខ ។

**មាត្រា ៣៤.-**

វៀរលែងតែភាគីវិវាទ បានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទ បានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

**ឧបសម្ព័ន្ធ៤**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦៤ អនក្រ.បក

4334
14 08 9

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្លែកពាណិជ្ជកម្ម

ថតចម្លង
នាយកដ្ឋាន.រដ្ឋបាល.

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមជ្ឈត្តការផ្លែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

### ប្រការ ១. ឈ្មោះ និងទម្រង់គតិយុត្ត

មជ្ឈមណ្ឌលមជ្ឈត្តការមានឈ្មោះថា មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហៅកាត់ថា "ម.ជ.ម." ។ ម.ជ.ម. គឺជានីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ហៅកាត់ថា "ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម" អនុក្រឹត្យលេខ ១២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ហៅកាត់ថា "អនុក្រឹត្យលេខ ១២៤" និងអនុក្រឹត្យលេខ ១៨២ ស្តីពីវិសោធនកម្មមាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ហៅកាត់ថា "អនុក្រឹត្យលេខ ១៨២" ។

### ប្រការ ២. ទីស្នាក់ការរបស់ ម.ជ.ម.

ម.ជ.ម. មានទីស្នាក់ការនៅរាជធានីភ្នំពេញ តាមអាសយដ្ឋានដែលបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

### ប្រការ ៣. គោលបំណង

បទបញ្ជាផ្ទៃក្នុងនេះ បំពេញបន្ថែម និងអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អនុក្រឹត្យលេខ ១២៤ និងអនុក្រឹត្យលេខ ១៨២។ បទបញ្ជាផ្ទៃក្នុងនេះមានគោលបំណងកំណត់ឱ្យបានច្បាស់លាស់អំពីរចនាសម្ព័ន្ធ នីតិវិធីសម្រាប់ប្រតិបត្តិការ និងរដ្ឋបាល និងអភិបាលកិច្ចរបស់ ម.ជ.ម.។

ជំពូកទី ៣

# សមាជិកភាពរបស់ ម.ជ.ម.

**ប្រការ ១១.** **សមាជិករបស់ ម.ជ.ម.**

សមាជិក ម.ជ.ម. រួមមាន៖

(ក) សមាជិកជាមជ្ឈត្តករ ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១២ ខាងក្រោម

(ខ) សមាជិកជានីតិបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៣ ខាងក្រោម

(គ) សមាជិកគាំទ្រជារូបវន្តបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៤ ខាងក្រោម និង

(ឃ) សមាជិកគាំទ្រជានីតិបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៥ ខាងក្រោម។

**ប្រការ ១២.** **លក្ខណសម្បត្តិ និងការចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកមជ្ឈត្តករ**

១២.១.ដើម្បីចុះបញ្ជីជាសមាជិកជាមជ្ឈត្តករនៅ ម.ជ.ម. រូបវន្តបុគ្គលត្រូវមានលក្ខណសម្បត្តិទាំងអស់ដូចខាងក្រោម៖

(ក) មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ

(ខ) មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ដែលបញ្ចប់ពីមហាវិទ្យាល័យណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស

**ឧបសម្ព័ន្ធ៦**

# វិធានផ្សះផ្សា UNCITRAL

## ការអនុវត្តវិធាន

**មាត្រា ១**

(១) វិធានទាំងនេះអនុវត្តចំពោះការផ្សះផ្សាវិវាទកើតចេញពី ឬពាក់ព័ន្ធទៅនឹងទំនាក់ទំនងកិច្ចសន្យា ឬទំនាក់ទំនងផ្លូវច្បាប់ដទៃទៀត ដោយក្នុងនោះ ភាគីវិវាទដែលស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទរបស់ខ្លួន បានព្រមព្រៀងយកការប្រើប្រាស់វិធានផ្សះផ្សា UNCITRAL ។

(២) ភាគីវិវាទអាចព្រមព្រៀងគ្នាដោយមិនរាប់បញ្ចូល ឬផ្លាស់ប្តូរវិធានណាមួយបានគ្រប់ពេល ។

(៣) នៅពេលដែលមានវិធានណាមួយ មានទំនាស់នឹងបទប្បញ្ញត្តិនៃច្បាប់ ដែលភាគីវិវាទមិនអាចធ្វើបដិប្បញ្ញត្តិ បាននោះ បទប្បញ្ញត្តិនៃច្បាប់នោះនឹងត្រូវយកមកអនុវត្ត ។

## ការចាប់ផ្តើមដំណើរការផ្សះផ្សា

**មាត្រា ២**

(១) ភាគីដែលផ្តួចផ្តើមការផ្សះផ្សា ត្រូវផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀត ដើម្បីផ្សះផ្សាតាមវិធាននេះ ដោយធ្វើការបង្ហាញកម្មវត្ថុនៃវិវាទនោះដោយសង្ខេបផង ។

(២) ដំណើរការផ្សះផ្សា ចាប់ផ្តើមនៅពេលភាគីម្ខាងទៀតទទួលយកការអញ្ជើញដើម្បីផ្សះផ្សា ។ ក្នុងករណីដែលការទទួលយកនោះធ្វើឡើងដោយផ្ទាល់មាត់ ជាការល្អគួរតែធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរដែរ ។

(៣) ប្រសិនបើភាគីម្ខាងទៀតបដិសេធការអញ្ជើញនោះ ដំណើរការផ្សះផ្សានឹងមិនកើតឡើងឡើយ ។

(៤) ប្រសិនបើភាគីដែលផ្តួចផ្តើមការផ្សះផ្សា មិនបានទទួលចម្លើយតបក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃផ្ញើរលិខិតអញ្ជើញមក ឬក្នុងរយៈពេលផ្សេងទៀតដូចមានបញ្ជាក់នៅក្នុងលិខិតអញ្ជើញ ភាគីនោះអាចសម្រេចចិត្តដោយចាត់ទុកថានេះជាការរបដិសេធការអញ្ជើញដើម្បីផ្សះផ្សា ។ ប្រសិនបើមានការសម្រេចយ៉ាងដូច្នេះ ភាគីផ្តួចផ្តើមត្រូវជូនដំណឹងនេះទៅភាគីម្ខាងទៀត ។

## ចំនួនអ្នកផ្សះផ្សា

**មាត្រា ៣**

អ្នកផ្សះផ្សាមានតែមួយរូប លើកលែងតែភាគីវិវាទព្រមព្រៀងឱ្យមានអ្នកផ្សះផ្សាពីរ ឬបីរូប ។ ជាវិធានទូទៅនៅពេលដែលមានអ្នកផ្សះផ្សាលើសពីមួយរូប ពួកគេគួរតែធ្វើការរួមគ្នា ។

(២) អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យផ្ញើរសេចក្ដីថ្លែងជាលាយលក្ខណ៍អក្សរបន្ថែមទៀត ស្ដីពីគោលជំហររបស់ខ្លួន ព្រមទាំងអង្គហេតុនិងមូលដ្ឋានគាំទ្រផ្សេងៗភ្ជាប់ទៅដោយឯកសារ និងភស្ដុតាងទាំងឡាយណាដែលភាគីនោះយល់ថាសមស្រប ។ ភាគីត្រូវផ្ញើរឯកសារចំលងមួយច្បាប់ទៅភាគីម្ខាង ទៀតផងដែរ ។

(៣) នៅក្នុងដំណាក់កាលណាក៏ដោយនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើភាគីណាមួយឱ្យផ្ញើរព័ត៌មានបន្ថែមទាំងនោះ តាមការដែលខ្លួនយល់ឃើញថាសមស្រប ។

**តំណាង និងជំនួយ**

**មាត្រា ៦**

ភាគីវិវាទអាចមានអ្នកតំណាង ឬអ្នកផ្ដល់ជំនួយជាបុគ្គលដែលខ្លួនជ្រើសរើស។ ឈ្មោះ និង អាសយដ្ឋានរបស់បុគ្គលទាំងនោះ ត្រូវតែបានផ្ដល់ព័ត៌មានជាលាយលក្ខ័អក្សរទៅកាន់ភាគីម្ខាងទៀត និងអ្នកផ្សះផ្សាផងដែរ ដោយត្រូវបញ្ជាក់ថាការតែងតាំងនោះធ្វើឡើងក្នុងគោលបំណងសម្រាប់ធ្វើជាអ្នកតំណាង ឬធ្វើជាអ្នកផ្ដល់ជំនួយ។

**តួនាទីរបស់អ្នកផ្សះផ្សា**

**មាត្រា ៧**

(១) អ្នកផ្សះផ្សាជួយភាគីវិវាទក្នុងរបៀបមួយដែលឯករាជ្យ និងមិនលម្អៀង ក្នុងការដែលខ្លួនខិតខំខ្នែងដើម្បីបានឈានទៅដល់ដំណោះស្រាយមួយប្រកបដោយសន្ដិវិធីចំពោះវិវាទរបស់ពួកគេ ។

(២) អ្នកផ្សះផ្សាត្រូវប្រើប្រាស់គោលការណ៍អញ្ញាថាភាពត្រឹមត្រូវ និងយុត្តិធម៌ជាត្រីមុខ ដោយត្រូវពិចារណាលើកត្ដាផ្សេងៗដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ទម្លាប់ប្រើប្រាស់នៃជំនួញដែលពាក់ព័ន្ធ និងកាលៈ-ទេសៈនានានៅជុំវិញវិវាទ រួមទាំងបែបបទអាជីវកម្មដែលភាគីវិវាទបានអនុវត្តន៏ពីមុនមក។

(៣) អ្នកផ្សះផ្សាអាចដឹកនាំដំណើរការផ្សះផ្សា ក្នុងបែបបទមួយដែលខ្លួនយល់ថាសមស្រប ដោយលើកមកពិចារណានូវកាលៈទេសៈផ្សេងៗនៃរឿងក្ដី បំណងប្រាថ្នាដែលភាគីវិវាទអាចបង្ហាញ រួមទាំងសម្នើរបស់ភាគីម្ខាងឱ្យអ្នកផ្សះផ្សាស្ដាប់បំនកស្រាយផ្ទាល់មាត់ ព្រមទាំងតម្រូវការនូវដំណោះស្រាយដ៏ឆាប់រហ័សមួយនៃវិវាទជាដើម។

(៤) នៅគ្រប់ដំណាក់កាលនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចធ្វើសម្នើនានាក្នុងការបញ្ចប់វិវាទ។ សម្នើទាំងនោះមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរ និងមិនចាំបាច់អមដោយសេចក្ដីអធិប្បាយអំពីហេតុផល នៃសម្នើនោះឡើយ។

### ជំនួយផ្នែករដ្ឋបាល

**មាត្រា ៨**

(១) ដើម្បីជួលសម្រួលដល់ការដឹកនាំដំណើរការផ្សះផ្សា ភាគីវិវាទ ឬអ្នកផ្សះផ្សា ដោយមានការឯកភាពពីភាគីវិវាទ អាចចាត់ឱ្យមានជំនួយរដ្ឋបាលពីសំណាក់ស្ថាប័ន ឬដោយបុគ្គលណាមួយដែលសមស្រប ។

### ការឆ្លើយឆ្លងរវាងអ្នកផ្សះផ្សានិងភាគីវិវាទ

**មាត្រា ៩**

(១) អ្នកផ្សះផ្សាអាចអញ្ជើញភាគីវិវាទឱ្យមកជួបខ្លួន ឬអាចឆ្លើយឆ្លងជាមួយពួកគេដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ។ អ្នកផ្សះផ្សាអាចជួប ឬឆ្លើយឆ្លងជាមួយភាគីវិវាទរួមគ្នា ឬជាមួយភាគីនិមួយៗ ដោយឡែកពីគ្នា ។

(២) លើកលែងតែភាគីវិវាទបានព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើការប្រជុំជាមួយអ្នកផ្សះផ្សា ទីកន្លែងប្រជុំនឹងត្រូវសម្រេចដោយអ្នកផ្សះផ្សា បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយភាគីវិវាទ ដោយមើលតាមកាលៈទេសៈផ្សេងៗនៃដំណើរការផ្សះផ្សា ។

### ការបង្ហាញព័ត៌មាន

**មាត្រា ១០**

នៅពេលដែលអ្នកផ្សះផ្សាទទួលព័ត៌មានស្តីពីអង្គហេតុទាក់ទងនឹងវិវាទពីភាគីម្ខាង អ្នកផ្សះផ្សាបង្ហាញខ្លឹមសារនៃព័ត៌មាននោះដល់ភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតអាចមានឱកាសក្នុងការបង្ហាញបំនកស្រាយណាមួយដែលខ្លួនគិតថាសមស្រប ។ ក៏ប៉ុន្តែ នៅពេលដែលភាគីម្ខាងផ្តល់ព័ត៌មានទៅកាន់អ្នកផ្សះផ្សា ដោយភ្ជាប់នូវលក្ខខ័ណ្ឌជាក់លាក់ថាត្រូវរក្សាការសម្ងាត់ អ្នកផ្សះផ្សាមិនបង្ហាញព័ត៌មាន ទៅភាគីម្ខាងទៀតឡើយ ។

### ការសហការរបស់ភាគីវិវាទជាមួយអ្នកផ្សះផ្សា

**មាត្រា ១១**

ភាគីវិវាទត្រូវសហការដោយស្មោះត្រង់ជាមួយអ្នកផ្សះផ្សា ហើយជាពិសេសត្រូវខិតខំខ្នែងធ្វើតាមសម្នើ របស់អ្នកផ្សះផ្សា ក្នុងការផ្ញើឯកសារលាយលក្ខណ៍អក្សរនានា ការផ្តល់ភស្តុតាង និងការចូលរួមប្រជុំ ។

### សំណូមពររបស់ភាគីដើម្បីបញ្ចប់វិវាទ

**មាត្រា ១២**

ភាគីនិមួយៗ អាចផ្ញើរទៅកាន់អ្នកផ្សះផ្សានូវសំណូមពររបស់ខ្លួនដើម្បីបញ្ចប់វិវាទ តាមការផ្តួចផ្តើមផ្ទាល់ ខ្លួន ឬតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។

**ប្រាក់តម្កល់**

**មាត្រា ១៨**

(១) នៅពេលត្រូវបានតែងតាំង អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យតម្កល់ប្រាក់ចំណាយស្មើៗគ្នាដែលជាប្រាក់កក់សម្រាប់ថ្លៃចំណាយផ្សេងៗដូចមានរៀបរាប់នៅក្នុងមាត្រា១៧ កថាខ័ណ្ឌ(១) តាមការដែលខ្លួនរំពឹងថានឹងត្រូវការដើម្បីទូទាត់។

(២) នៅក្នុងពេលដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើសុំប្រាក់តម្កល់បន្ថែមនៅក្នុងចំនួនស្មើគ្នាពីភាគីនិមួយៗ។

(៣) ប្រសិនបើភាគីវិវាទទាំងសង្ខាងមិនបានបង់ប្រាក់តម្កល់ដែលបានតម្រូវក្នុងកថាខ័ណ្ឌ(១) និង(២) នៃមាត្រានេះ ឱ្យបានគ្រប់ក្នុងរយៈពេលសាមសិបថ្ងៃនោះទេ អ្នកផ្សះផ្សាអាចពន្យាដំណើរការ ឬអាចធ្វើសេចក្តីប្រកាសជាលាយលក្ខណ៏អក្សរអំពីការបញ្ឈប់ដំណើរការនោះ ជូនទៅភាគីវិវាទ ដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃប្រកាសនោះតទៅ។

(៤) នៅពេលបញ្ឈប់ដំណើរការផ្សះផ្សា អ្នកផ្សះផ្សាត្រូវប្រគល់ជូនរបាយការណ៏គណនេយ្យដល់ភាគីវិវាទដែលបានបង់ប្រាក់តម្កល់ និងត្រូវប្រគល់សមតុល្យដែលមិនបានចំណាយជូនភាគីទាំងនោះវិញ ។

**តួនាទីអ្នកផ្សះផ្សានៅក្នុងនីតិវិធីផ្សេងទៀត**

**មាត្រា ១៩**

ភាគីវិវាទ និងអ្នកផ្សះផ្សាត្រូវទទួលយល់ព្រមថា អ្នកផ្សះផ្សានឹងមិនដើរតួជាមជ្ឈត្តករ ឬជាតំណាង ឬជាអ្នកពិគ្រោះយោបល់របស់ភាគីម្ខាងនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានោះឡើយ។ ភាគីវិវាទក៏ត្រូវទទួលយល់ព្រមផងដែរថា ខ្លួននឹងមិនយកអ្នកផ្សះផ្សាធ្វើជាសាក្សីនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការនោះឡើយ។

**ការប្រើប្រាស់ភស្តុតាងនៅក្នុងដំណើរការផ្សេងទៀត**

**មាត្រា ២០**

នៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ទោះជានីតិវិធីទាំងនោះពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានេះក៏ដោយ ភាគីវិវាទត្រូវទទួលយល់ព្រមថាមិននឹងពឹងផ្អែក ឬប្រើប្រាស់ជាភស្តុតាងនូវៈ

(ក) ទស្សនៈដែលបានសំដែងចេញ ឬសំណើមពររបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងលទ្ធភាពនៃការបញ្ចប់វិវាទ

# ជំពូកទី២: ការចរចា




ចេះឯងអោយក្រែងចេះគេ។

## ក. សេចក្តីផ្តើម

ជំពូកនេះផ្តោតទៅលើការចរចា។ វាមានគោលបំណងជួយដល់អ្នកទាំងឡាយ ដែលមានជាប់ពាក់ព័ន្ធក្នុងការចរចា ទោះជាការចរចាដើម្បីខ្លួនឯង ឬក្នុងនាមអ្នកដទៃក៏ដោយ។ ការចរចាគឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះ ភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសម្នើផ្សេងៗ រហូតដល់សម្នើណាមួយត្រូវបានធ្វើឡើង ហើយត្រូវបានគេទទួលយក។[៦] ការចរចាគឺជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទនៅទូទាំងពិភពលោក ដែលគេឃើញមានទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) និងច្បាប់អង់គ្លេស (Common Law)។ ការចរចា អាចដោះស្រាយវិវាទធំ និងតូច ហើយអាចជាដំណើរការដ៏ស្មុគស្មាញបំផុត ឬសាមញ្ញធម្មតាមួយ។

មនុស្សធ្វើការចរចានៅគ្រប់ពេលទាំងអស់។ វាគឺជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្ស។ មនុស្សធ្វើការចរចាទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ ជាក់ស្តែង មនុស្សអាចចរចាគ្នាអំពីតម្លៃផ្លែស្វាយ ឬតម្លៃលក់ម៉ូតូជាដើម។ ពេលខ្លះ ពួកគេមិនទាំងដឹងផង ថាខ្លួនកំពុងតែចរចា។ ឧទាហរណ៍ នៅពេលបុគ្គលណាម្នាក់ព្យាយាមបញ្ចុះបញ្ចូលឱ្យក្រុមគ្រួសាររបស់ខ្លួនទៅធ្វើដំណើរកំសាន្ត ការចរចាអំពីកន្លែងដែលត្រូវទៅ ឬពេលវេលាចេញដំណើរ អាចនឹងកើតមាន។

ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនយ៉ាងដូចជា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីពីរ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬមានលក្ខណៈផ្លូវការ។ គេអាចធ្វើការចរចាតាមរយៈសំបុត្រ ឬអ៊ីមែលផងដែរ។ នៅក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមទូរស័ព្ទផងដែរ។ នៅពេលមានការចរចាពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ ការចរចាអាចនឹងរួមផ្សំទៅដោយមធ្យោបាយទំនាក់ទំនងទាំងអស់នេះ។

---

[៦] *Gainey v. Brotherhood of Railway and S.S. Clerks, Freight Handlers, Exp. & Station Employees,* 275 F. Supp. 292, 300 (E.D. Pa. 1967)

### ៣. *កលយុទ្ធនៅក្នុងការចរចាបែបបែងចែក*

គេអាចសម្រេចបានលទ្ធផលកាន់តែប្រសើរពីការចរចាបែបបែងចែក ដោយប្រើប្រាស់កលយុទ្ធមួយចំនួនដែលត្រូវបានគេស្គាល់ជាទូទៅរួចមកហើយ។ ខាងក្រោមនេះគឺជាកលយុទ្ធមួយចំនួនដែលអ្នកចរចាបានប្រើប្រាស់។ កលយុទ្ធទាំងនេះត្រូវបានផ្តល់ជូនជាឧបករណ៍សម្រាប់ប្រើនៅក្នុងការចរចាបែបបែងចែក ប៉ុន្តែមិនមានភាពចាំបាច់នៅក្នុងការចរចាផ្អែកលើផលប្រយោជន៍ឡើយ។

- **តម្លៃបម្រុងរបស់អ្នក:** កលយុទ្ធទីមួយគឺគណនាដោយប្រុងប្រយ័ត្ន និងប្រាកដប្រជានូវ EMV និង BATNA ក៏ដូចជាតម្លៃបម្រុងដែលជាលទ្ធផលចុងក្រោយ។ ដូចបានរៀបរាប់ពីខាងលើរួចមកហើយថា នេះជាការចាំបាច់ក្នុងការកំណត់ថាត្រូវមានវិធានការយ៉ាងដូចម្តេចនៅពេលមានវិវាទ។
- **តម្លៃបម្រុងរបស់ភាគីម្ខាងទៀត:** កលយុទ្ធទីពីរគឺព្យាយាមកំណត់ឱ្យបានត្រឹមត្រូវនូវតម្លៃបម្រុងរបស់ភាគីម្ខាងទៀត។ ចំណុចនេះអាចជាការលំបាក។ វិធីមួយក្នុងការកំណត់នេះគឺត្រូវព្យាយាមប្រមូលព័ត៌មានឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបានអំពីភាគីម្ខាងទៀត និងកម្មវត្ថុនៃវិវាទ។ ជាងនេះទៅទៀត វាជាប្រការសំខាន់ដែលគេត្រូវស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីៗទាំងអស់ដែលភាគីម្ខាងទៀតនិយាយ ឬសរសេរ នៅក្នុងកំឡុងពេលចរចា។ ត្រូវពិចារណាលើតួលេខដែលភាគីនោះស្នើ និងថាភាគីនោះតើមានភាពបត់បែនប៉ុណ្ណា នៅក្នុងកំឡុងពេលចរចា។ ចំណុចនេះអាចផ្តល់នូវគំនិតស៊ីជម្រៅមួយចំនួន ពាក់ព័ន្ធនឹងតម្លៃបម្រុងរបស់ភាគីនោះ។ ផ្ទុយទៅវិញ ប្រការដែលសំខាន់ គឺអ្នកមិនត្រូវលះបង់តម្លៃបម្រុងរបស់ខ្លួនឯងឡើយ។
- **"ការកម្លា":** ការកម្លា គឺជាការបង្ហាញនូវចេតនាធ្វើអ្វីមួយ ដែលមិនមែនជាចេតនាពិតប្រាកដ ដូចជា ចំណាយប្រាក់តែក្នុងចំនួនណាមួយ ឬឈប់សហការជាមួយភាគីម្ខាងទៀត ឬដើរចេញពីការចរចាជាដើម។ ដោយប្រើការកម្លា អ្នកអាចមានលទ្ធភាពបង្កើតអំណាចតថ្លៃបន្ថែមទៀត។ វាអាចបណ្តាលឱ្យភាគីម្ខាងទៀតកែប្រែតម្លៃបម្រុងរបស់ខ្លួន ឬកែប្រែការប៉ាន់ស្មានតម្លៃបម្រុងរបស់អ្នក។ ទោះក្នុងផ្លូវណាក៏ដោយ វាអាចហុចលទ្ធផលកាន់តែប្រសើរសម្រាប់បុគ្គលដែលធ្វើការកម្លានោះ។

ប៉ុន្តែ វាជាការប្រថុយប្រថាន ដោយសារមានពេលខ្លះ ការកម្លានោះត្រូវបានគេ "ជំរុញ"។ នេះមានន័យថាភាគីម្ខាងទៀតអាចបង្ខំអ្នកឱ្យធ្វើនូវអ្វីដែលអ្នកបានគំរាមថានឹងធ្វើ។ ប្រសិនបើលោកអ្នកមិនធ្វើតាមនោះទេ អ្នកនឹងបាត់បង់ភាពដែលអាចជឿជាក់បានពីក្រសែភ្នែករបស់ភាគីម្ខាងទៀត។ ហើយនាពេលអនាគតភាគីម្ខាងទៀត អាចនឹងមិនជឿនូវអ្វីដែលអ្នកនិយាយ។ ប្រសិនបើការកម្លាត្រូវបានគេជំរុញ លទ្ធផលចុង-ក្រោយទំនងជាកាន់តែអាក្រក់ជាងមុនទៅទៀត។

ជាងនេះទៅទៀត ការកម្លាជួនកាលអាចបំផ្លាញដល់ទំនាក់ទំនងយូរអង្វែងរវាងភាគីទាំងពីរ ដោយ-សារកង្វះទំនុកចិត្ត។ កាកម្លាត្រូវបានប្រើប្រាស់បានល្អបំផុត នៅក្នុងការចរចារវាងគូភាគី ដែលមិនមានចេតនាបន្តទំនាក់ទំនងទៅពេលអនាគត ដូចជាករណីទិញទំនិញនៅផ្សារ នៅថ្ងៃឈប់សម្រាកជាដើម។

- **ការកាត់ថ្លៃ :** ការកាត់ថ្លៃគឺជាការប្រើប្រាស់តួលេខ ទោះតិចក្តីច្រើនក្តី ដើម្បីជះឥទ្ធិពលទៅលើការយល់ឃើញរបស់ភាគីម្ខាងទៀតចំពោះតម្លៃ។ ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មនុស្សនឹងផ្លាស់ប្តូរការវាយតម្លៃ

និងសេចក្តីស្នើតបរបស់ខ្លួន ដោយផ្អែកលើសម្នើដំបូង។[២៣] ឧទាហរណ៍ ការសិក្សាមួយរបស់ប្រទេសស៊ុយអែតបានបង្ហាញឱ្យឃើញថា អ្នកទិញផ្ទះល្វែងបានផ្តល់តម្លៃដំបូងខ្ពស់ ប្រសិនបើតម្លៃនៅក្នុងបញ្ជីដំបូងខ្ពស់។ អ្នកទិញផ្ទះល្វែងបានផ្តល់តម្លៃដំបូងទាប ប្រសិនបើតម្លៃនៅក្នុងបញ្ជីដំបូងទាប សម្រាប់អចលនទ្រព្យដដែលនោះ។ គេអាចនិយាយបានថា ការយល់ឃើញរបស់អ្នកទិញអំពីតម្លៃទីផ្សាររបស់អចលនទ្រព្យ ទទួលឥទ្ធិពលពីតម្លៃដំបូងដែលអ្នកលក់កំណត់។[២៤] ការកាត់ថ្លៃមានឥទ្ធិពលចំពោះ សូម្បីតែ អ្នកជំនាញ។ ក្នុងការសិក្សាមួយរបស់ប្រទេសអាល្លឺម៉ង់ អ្នកស្រាវជ្រាវបានរកឃើញថា ការប៉ាន់ស្មានតម្លៃរថយន្ត ដោយយន្តការីអាជីព ទទួលឥទ្ធិពលយ៉ាងខ្លាំងពីសំណូរកាត់ថ្លៃដំបូងដែលអតិថិជនសួរ។[២៥]

ការកាត់ថ្លៃមានប្រសិទ្ធភាព ពីព្រោះវាហាក់ដូចជាធ្វើឱ្យមនុស្សផ្តោតអារម្មណ៍ទៅលើទិដ្ឋភាពមួយចំនួននៃកម្មវត្ថុមួយ។ ការកាត់ថ្លៃខ្ពស់ពាក់ព័ន្ធនឹងផលិតផលមួយនឹងហាក់បណ្តាលឱ្យមនុស្សផ្តោតទៅលើទិដ្ឋភាពវិជ្ជមាននៃផលិតផលនោះ ចំណែកឯការកាត់ថ្លៃទាបនឹងបណ្តាលឱ្យមានឥទ្ធិពលផ្ទុយពីនោះ។ អ្នកចរចាអាចទាញយកអត្ថប្រយោជន៍ពីចំណុចនេះ ដោយបង្ហាញនូវការទាមទារដំបូងដ៏ខ្ពស់ពីភាគីម្ខាងទៀត (ដូចគ្នានឹងអ្នកលក់អចលនទ្រព្យស៊ុយអែតដែរ) ឬសម្នើដំបូងដ៏ទាប ប្រសិនបើខ្លួនជាអ្នកបង់ប្រាក់។ គួរកត់សម្គាល់ថា ការកាត់ថ្លៃដំបូងខ្ពស់ ឬទាបហួសហេតុពេក មានប្រសិទ្ធភាពកាន់តែតិច ហើយមានភាពប្រថុយប្រថានក្នុងការធ្វើឱ្យភាគីម្ខាង ទៀតដើរចេញ។[២៦]

- **"តម្លៃចុងក្រោយ" ដែលមិនអាចកែប្រែបាន:** ជួនកាលភាគីម្ខាងអាចទាមទារថាខ្លួនកំពុងផ្តល់នូវជំហរដែលដាច់ខាត និងជាចុងក្រោយ។ នេះគឺជាសម្នើដ៏ល្អបំផុតរបស់ខ្លួន ហើយខ្លួនមិនអាចព្រមឱ្យហួសពីនោះទៀតបានទេ។ ជួនកាល ការបង្ហាញតម្លៃចុងក្រោយដែលមិនអាចកែប្រែបាន គឺស្រដៀងទៅនឹងការកម្លាដែរ ប៉ុន្តែតម្លៃចុងក្រោយ គឺជាជំហរដ៏ពិតប្រាកដរបស់ភាគី ហើយមិនមែនគ្រាន់តែជាការកម្លានោះទេ។ ជាទូទៅ តម្លៃចុងក្រោយគឺជាតម្លៃបម្រុងនោះឯង។ ឧទាហរណ៍ ប្រសិនបើបន្ទាប់ពីព្យាយាមចរចារកដំណោះស្រាយរួចមក ភាគីម្ខាងមានឆន្ទៈចំណាយតែ ១,000ដុល្លានោះ ភាគីនោះអាចប្រាប់ដល់ភាគីម្ខាងទៀតថានេះគឺជាតម្លៃចុងក្រោយ។ នៅ

---

[២៣] Henrik Kristensen និង Tommy Gärling *ចំណុចគោល ចំណុចយោង និងសម្នើតបនៅក្នុងការចរចា*។ របាយការណ៍ចិត្តវិទ្យានៃសាកលវិទ្យាល័យ Goteborge លេខ៧ ទំព័រ២៧ (ឆ្នាំ១៩៩៧)។

[២៤] *ដូចមុន*

[២៥] Adam D. Galinsky, *តើអ្នកគួរផ្តល់សម្នើដំបូងដែរឬទេ?*, **ការចរចា** (មហាវិ.ពាណិជ្ជ. នៃសាកលវិ.ហាវើដ, ឆ្នាំ២00៤)។ "នៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវតម្រូវឱ្យអតិថិជនមួយចំនួន យករថយន្តជាច្រើន ដែលប្រើរួច ហើយត្រូវការការជួសជុល ទៅរកយន្តការីអាល្លឺម៉ង់ ដែលជាអ្នកដែលគេរំពឹងថានឹងដឹងអំពីតម្លៃពិតប្រាកដនៃរថយន្ត។ បន្ទាប់ពីបានផ្តល់យោបល់ផ្ទាល់ខ្លួនអំពីតម្លៃរថយន្តនោះរួច អតិថិជនសួរយន្តការីអំពីតម្លៃដែលគាត់ប៉ាន់ស្មាន។ យន្តការីចំនួនពាក់កណ្តាលត្រូវបានផ្តល់ការកាត់ថ្លៃទាប។ អតិថិជននិយាយថា "ខ្ញុំគិតថារថយន្តនោះត្រូវលក់ក្នុងតម្លៃ២,៨00ម៉ាក"។ យន្តការីចំនួនពាក់កណ្តាលទៀតត្រូវបានផ្តល់ការកាត់ថ្លៃខ្ពស់: "ខ្ញុំគិតថារថយន្ត នោះត្រូវលក់ក្នុងតម្លៃ៥,000ម៉ាក"។ យន្តការីទាំងនោះប៉ាន់ស្មានតម្លៃរថយន្តក្នុងតម្លៃ ១,000ម៉ាក បន្ថែមទៀតនៅពេលដែលពួកគេត្រូវបានផ្តល់ការកាត់ថ្លៃខ្ពស់!" *ដូចមុន*។

[២៦] *ដូចមុន*

## ៥. ដំណាក់កាលនៃដំណើរការចរចា

ក្រៅពីការហាមឃាត់ចំពោះការបំភ័ន្ត ឬបង្ខិតបង្ខំ ដំណើរការចរចាមិនមានប្រើវិធានអ្វីឱ្យជាក់លាក់នោះទេ។ មិនមានច្បាប់ ឬលក្ខន្តិកៈណាមួយដែលណែនាំអំពីដំណើរការកាចរចាឡើយ។ ប៉ុន្តែគេអាចស្វែងយល់អំពីដំណើរការរបស់វាបានកាន់តែប្រសើរ តាមរយៈដំណាក់កាលចំនួនប្រាំដូចខាងក្រោមៈ

- ដំណាក់កាលត្រៀម
- ដំណាក់កាលផ្តើម
- ដំណាក់កាលព័ត៌មាន
- ដំណាក់កាលបែងចែក/ផ្អែកលើផលប្រយោជន៍
- ដំណាក់កាលបញ្ចប់

ការចរចានីមួយៗមានភាពខុសគ្នា។ ចំពោះការទិញទំនិញនៅផ្សារ ភាគច្រើននៃដំណាក់កាលទាំងនេះនឹងកន្លងទៅតែក្នុងរយៈពេលប៉ុន្មាននាទីតែប៉ុណ្ណោះ។ នៅក្នុងការចរចាផ្លូវច្បាប់ស្មុគស្មាញ ដំណាក់កាលទាំងនោះអាចត្រូវការរយៈពេលជាច្រើនថ្ងៃ ឬជាច្រើនសប្តាហ៍ដើម្បីបំពេញ។

### ១. *ដំណាក់កាលត្រៀម*

- ស្វែងរកអង្គហេតុ
- វិភាគច្បាប់
- ស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់អតិថិជន
- កំណត់ BATNA
- ពិចារណាលើការទាមទាររបស់ភាគីដទៃទៀត
- បង្កើតយុទ្ធសាស្ត្រ

ដំណាក់កាលទីមួយនៃការចរចា គឺជាដំណាក់កាលត្រៀម។ នៅក្នុងដំណាក់កាលនេះ ភាគី និងមេធាវីរបស់ខ្លួនត្រូវពិនិត្យមើលរឿងក្តីយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាមូលដ្ឋានមួយចំនួន មុននឹងចាប់ផ្តើមដំណើរការចរចា។ ជំហាន ទីមួយរបស់មេធាវី គឺធ្វើការស្រាវជ្រាវ និងស្វែងរកអង្គហេតុដែលពាក់ព័ន្ធនឹងរឿងក្តីទាំងអស់។ ការនេះជាទូទៅមានន័យថា ជាការសម្ភាសជាមួយមនុស្សម្នាក់ ឬច្រើននាក់ដោយផ្ទាល់។ វាក៏អាចពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវភ័ស្តុតាងជាឯកសារ ដូចជា កិច្ចសន្យា ឬវិក័យប័ត្រផ្សេងៗ។

បន្ទាប់ពីមេធាវីយល់ច្បាស់អំពីអង្គហេតុមក ជំហានបន្ទាប់គឺធ្វើការវិភាគច្បាប់ ដោយផ្អែកលើអង្គហេតុទាំងនោះ។ ច្បាប់អាចមិនមានចម្លើយដែលច្បាប់លាស់។ បើមិនដូច្នោះទេ បទដ្ឋានច្បាប់អាចមានភាពច្បាស់លាស់ ប៉ុន្តែអង្គហេតុអាចមានភាពចំរូងចំរាស់។ ត្រង់ចំណុចនេះ ប្រការដែលសំខាន់គឺ មេធាវីត្រូវព្យាយាមបង្កើតអំណះអំណាងផ្លូវច្បាប់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ព្រមទាំងវាយតម្លៃដោយមិនលម្អៀងអំពីចំណុចខ្លាំងនៃអំណះអំណាងទាំងនេះ។

ជំរុញទឹកចិត្តភាគីម្ខាងទៀតបាន។ វាក៏មានសារៈសំខាន់យ៉ាងខ្លាំងផងដែរដែល មេធាវីត្រូវធ្វើការវិនិច្ឆ័យដោយឯករាជ្យអំពីចំនុចខ្លាំងនៃអំណះអំណាងរបស់ភាគីទាំងពីរ។ ការគណនា BATNA របស់មេធាវី ត្រូវមានឯករាជ្យភាពពីបុរេ-វិនិច្ឆ័យ របស់កូនក្តីពាក់ព័ន្ធទៅនឹងភាពរឹងមាំនៃអំណះអំណាងផ្ទាល់របស់ខ្លួន និង "ភាពត្រឹមត្រូវ" នៃជំហររបស់ខ្លួន។

> ***ម្ចាស់ផ្ទះ និងក្រុមអ្នកច្បាប់ផ្ទាល់ខ្លួនរបស់គាត់គួរធ្វើការពិភាក្សាអំពីកិច្ចការខាងលើ ក្នុងជំពូកនេះ។***

ក្រោយពេលជំហានខាងលើត្រូវបានបំពេញរួច មេធាវីត្រូវបង្កើតយុទ្ធសាស្រ្តសម្រាប់ការចរចា។ យុទ្ធសាស្រ្តនេះត្រូវផ្តោតលើរបៀបបង្ហាញការទាមទារទៅភាគីម្ខាងទៀត តើសម្បទានអ្វីខ្លះដែលកូនក្តីរបស់អ្នកអាចធ្វើជាយថាហេតុ តើផលប្រយោជន៍ដែលសំខាន់មានអ្វីខ្លះ ដំណោះស្រាយដែលអាចមាន ព្រមទាំង BATNA ឬតម្លៃបម្រុង។ យុទ្ធសាស្រ្តនេះអាចកំណត់ឡើងដោយការឆ្លើយសំណួរនៅក្នុងទំព័រទិនានុប្បវត្តិនៃការចរចា ដែលមានចំណងជើងថា *ការរៀបចំផែនការសម្រាប់ការចរចា* ដែលស្ថិតនៅចុងបញ្ចប់នៃជំពូកនេះ។ ត្រូវពិនិត្យមើលយុទ្ធសាស្រ្តនេះឡើងវិញជាមួយកូនក្តីដើម្បីធានាថាកូនក្តីពេញចិត្តចំពោះយុទ្ធសាស្រ្តទាំងនេះ រីឯកូនក្តីវិញក៏ត្រូវផ្តល់សិទ្ធិអំណាចពេញលេញដល់មេធាវីក្នុងការចរចាដោយអនុលោមតាមយុទ្ធសាស្រ្តនេះផងដែរ។

## 2. *ដំណាក់កាលផ្តើម*

ជាញឹកញាប់ ដំណាក់កាលផ្តើមនៃការចរចាត្រូវបានបំភ្លេចចោល ដោយចាត់ទុកថាវាមិនសំខាន់។ ផ្ទុយទៅវិញ ដំណាក់កាលនេះមានភាពចាំបាច់ចំពោះភាពជោគជ័យនាពេលក្រោយមកទៀត។ នៅក្នុងដំណាក់កាលនេះ មេធាវីធ្វើទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដើម្បីពិភាក្សាអំពីបែបបទនៃការចរចា ដូចជា តើគួរតែមានការចរចា **ដែរឬទេ** និងតើការចរចាទាំងនេះត្រូវធ្វើ ឡើងនៅ **ពេលណា** **នៅកន្លែងណា** និង**ដោយរបៀបណា**។

- តើគួរតែមានការចរចាដែរ **ឬទេ**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **នៅពេលណា**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **នៅកន្លែងណា**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **ដោយរបៀបណា**

### គួរឬទេ

សំណួរថា "គួរឬទេ" (តើគួរមានការចរចាដែរឬទេ?) មានសារៈសំខាន់ណាស់។ នៅក្នុងករណីមួយចំនួន ភាគីទីមួយដែលស្នើឱ្យមានការចរចា អាចត្រូវបានគេមើលឃើញថាជាការបង្ហាញភាពទន់ខ្សោយរបស់ខ្លួន។ ប្រសិនបើមានករណីបែបនេះមែន មេធាវីត្រូវគិតដោយប្រុងប្រយ័ត្នអំពីរបៀបបង្ហាញសម្មើនោះ។ ជាគោលការណ៍ទូទៅ ប្រសិនបើភាគីមានផលប្រយោជន៍កាន់តែតិចនៅក្នុងការចរចា ភាគីនោះកាន់តែមានជំហររឹងមាំស្តែងឡើង។ អាស្រ័យហេតុនេះ

ការព្យាយាមបង្ហាញការមិនមានចំណាប់អារម្មណ៍នៅក្នុងការចរចា ប៉ុន្តែនៅតែយល់ព្រមចូលរួមក្នុងការចរចា ជូនកាលក៏ជាប្រការដែលមានសារៈប្រយោជន៍ដែរ ។

### នៅពេលណា

ជូនកាល សំណួរផ្សេងទៀតត្រូវបានចាត់ទុកថាជាបែបបទផ្លូវការការសុទ្ធសាធ ។ ប៉ុន្តែ សំណួរទាំងនេះអាចមានសារៈសំខាន់ផងដែរ ។ ពាក់ព័ន្ធនឹងសំណួរថា "នៅពេលណា" ផលប្រយោជន៍ខ្ពស់របស់ភាគីក្នុងការឱ្យមានការចរចាជាបន្ទាន់ អាចចង្អុលបង្ហាញកម្រិតមួយនៃតម្រូវការ ឬសេចក្តីអស់សង្ឃឹម ។ ប្រសិនបើភាគីម្ខាងយល់ថាការចរចាត្រូវតែធ្វើឡើងជាបន្ទាន់ ភាគីនោះអាចប្រឈមមុខនឹងតម្រូវការប្រាក់ ។ ឬអាចថា ភាគីនោះអាចប្រឈមមុខនឹងរយៈពេលកំណត់ផ្នែកអាជីវកម្មដ៏សំខាន់ណាមួយ ។ ឬភាគីនោះអាចមានការភ័យខ្លាចថា វិវាទនោះនឹងត្រូវបើកចំហរជាសាធារណៈដែលអាចបង្កមហន្តរាយធ្ងន់ធ្ងរដល់ខ្លួនបាន ។ ទោះបីជាមានមូលហេតុអ្វីក៏ដោយ វាមានសារៈប្រយោជន៍ក្នុងការចងចាំ ចំណុចនេះ និងត្រូវធានាថាកូនក្តីរបស់អ្នកមិនហាក់ដូចជាមានចំណង់ជ្រុលពេក ក្នុងការឱ្យមានការចរចាជាបន្ទាន់ ។

### នៅកន្លែងណា

សំណួរថា "នៅកន្លែងណា" និង "ដោយរបៀបណា" មានលក្ខណៈកាន់តែល្អិតល្អន់នៅក្នុងសារៈសំខាន់របស់វា ។ ប្រសិនបើការចរចាត្រូវបានធ្វើឡើងនៅឯការិយាល័យមេធាវីរបស់អ្នក នោះអ្នកនឹងមានប្រៀបខាង "ទីតាំង" ។ អ្នកអាចមានអារម្មណ៍ងាយស្រួលជាងភាគីម្ខាងទៀត ដែលអាចមានអារម្មណ៍មិនសុខស្រួល នៅក្នុងបរិយាកាសដែលខ្លួនមិនធ្លាប់ស្គាល់ ។ លើសពីនេះទៅទៀត នៅក្នុងវប្បធម៌មួយចំនួន គេអាចចាត់ថាភាគីជាភ្ញៀវមានតម្រូវការជាងក្នុងការព្រមព្រៀងដោះស្រាយ ពីព្រោះពួកគេសុខចិត្តធ្វើដំណើរមកជួប ។ ដោយសារមូលហេតុនេះ ជូនកាលការចរចាត្រូវបានធ្វើឡើងនៅកន្លែងអព្យាក្រឹត ដូចជាការិយាល័យគណៈមេធាវី មជ្ឈមណ្ឌលតុលាការ ឬមជ្ឈមណ្ឌលសម្រុះសម្រួលឯកជន ។

### ដោយរបៀបណា

សំណួរ "របៀបណា" ពាក់ព័ន្ធទៅនឹងដំណើរការចរចាផ្ទាល់ ។ តើភាគីទាំងពីរគួរផ្ញើអ៊ីមែលឱ្យគ្នាឬទេ? តើពួកគេគួរចរចាតាមទូរស័ព្ទដែរឬទេ? តើពួកគេត្រូវចរចាទល់មុខគ្នាដោយផ្ទាល់ដែរឬទេ? ប្រសិនបើជួបផ្ទាល់ តើកូនក្តីត្រូវមានវត្តមាននៅពេលចរចាដែរឬទេ? ប្រសិនបើកូនក្តីរបស់អ្នកជាអ្នកមានប្រាក់ច្រើនជាង ឬជាមនុស្សដែលពោរពេញទៅដោយភាពជឿជាក់ពីធម្មជាតិនោះ ការចរចាទល់មុខគ្នាជាមួយកូនក្តីទាំងពីរអាចមានប្រយោជន៍ ។ ឬកូនក្តីរបស់អ្នកអាចមានលទ្ធភាពផ្តល់ព័ត៌មានដល់អ្នក ពាក់ព័ន្ធនឹងអង្គហេតុដែលមានសារៈសំខាន់ នៅក្នុងកំឡុងពេលចរចា ។ ឬអាចថាពីដំបូងមកកូនក្តីរបស់អ្នកអាចមានការរំពឹងទុកចំពោះដំណោះស្រាយដែលមិនប្រាកដនិយម ហើយការស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតអាចជួយបន្ធូរបន្ថយការរំពឹងទុកទាំងនោះបាន ។

ផ្ទុយទៅវិញ ប្រសិនបើកូនក្តីរបស់អ្នកត្រូវបានគំរាមកំហែងដោយភាគីម្ខាងទៀត ឬឆាប់រំជួលអារម្មណ៍នោះគួរតែជៀសវាងកុំឱ្យមានការចូលរួមរបស់កូនក្តីទៅក្នុងការជួបចរចាផ្ទាល់ ។ ប្រសិនបើកូនក្តីរបស់អ្នក អាចនឹងផ្តល់ព័ត៌មានសំខាន់ ឬផ្តល់សញ្ញាជាកាយវិការ(ដូចជា ការបង្ហាញការភ័យខ្លាច)នោះ អ្នកអាច ពិចារណាបញ្ជៀសការចូលរួមដោយផ្ទាល់របស់កូនក្តីទៅក្នុងការចរចា ។

# ជំពូកទី៤: មជ្ឈត្តការ




**ចេះច្បាប់មិនខ្លាចក្ដី ចេះវិន័យមិនខ្លាចសង្ឃ។**

## ក. តើមជ្ឈត្តការគឺជាអ្វី?

មជ្ឈត្តការគឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ចម្បងទីបី។ នៅក្នុងមជ្ឈត្តការ គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយ (ដែលជាទូទៅហៅថា "មជ្ឈត្តករ" ឬ ប្រសិនបើច្រើនជាងម្នាក់ហៅថា "ក្រុមមជ្ឈត្តករ" ឬ "វេទិកាមជ្ឈត្តកម្ម")។ ភាគីទីបីនេះពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្ដីសម្រេចមួយ ហៅថា "មជ្ឈត្តវិនិច្ឆ័យ"។ ដូចដែលនឹងលើកយកមកពិភាក្សានៅក្នុងអត្ថបទខាងក្រោមនេះ មជ្ឈត្តវិនិច្ឆ័យ ជាទូទៅ គឺមានភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ យ៉ាងណាមិញក្នុងករណីខ្លះ មជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។

### ១. *ប្រវត្តិនៃមជ្ឈត្តការ*

មជ្ឈត្តការមានប្រវត្តិដ៏យូរលង់ណាស់មកហើយ។ មជ្ឈត្តការ ត្រូវបានលើកឡើងមកនិយាយនៅក្នុងអក្សរចំណាររបស់ក្រិចសម័យបុរាណ និងនៅក្នុងព្រះគម្ពីរប៊ីប្លរបស់សាសនាគ្រិស្ត។[១៥៧] មជ្ឈត្តការផ្នែកពាណិជ្ជកម្មទំនើបត្រូវបានបង្កើតឡើងជាលើកដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគមជ្ឈិមសម័យ។[១៥៨] ជាញឹកញាប់ ពាណិជ្ជករធ្វើដំណើរក្នុងចម្ងាយដ៏ឆ្ងាយដើម្បីទៅធ្វើជំនួញនៅកន្លែងដែលពួកគេទិញ និងលក់ទំនិញ ព្រមទាំងសេវាកម្មផ្សេងៗ។ ដោយហេតុថាការធ្វើដំណើរមាន

---

[១៥៧] STEVEN C. BENNETT, **មជ្ឈត្តការឧស្សាហានសំខាន់ៗ** ទំព័រ៩ (ALM ed., ឆ្នាំ២០០២)។

[១៥៨] Sarah Rudolph Cole and Kristen M. Blankley *មជ្ឈត្តការ,* **សៀវភៅណែនាំអំពីការដោះស្រាយវិវាទ** ទំព័រទី ៣១៨, ៣២០ (Moffitt and Bordone, ed., ឆ្នាំ២០០៥)។

គ្រោះថ្នាក់ច្រើន និងមានតម្លៃថ្លៃ វិវាទនានាត្រូវដោះស្រាយឱ្យបានឆាប់រហ័ស និងនៅជិតទីកន្លែងធ្វើជំនួញនោះ ។ យ៉ាងណាមិញ នៅពេលនោះតុលាការអចិន្ត្រៃយ៍មិនអាចដោះស្រាយវិវាទទាំងនោះឱ្យបានឆាប់រហ័សឡើយ និងគ្មានចំណេះដឹងអំពីបទដ្ឋានឧស្សាហកម្មរបស់អ្នកជំនួញឡើយ ។ នេះគឺជាចំណុចសំខាន់ ដោយសារបទដ្ឋានឧស្សាហកម្មទាំងនេះត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលទំនាក់ទំនងពាណិជ្ជកម្ម ក្នុងចំណោមគូភាគីដែលមកពីប្រទេស និងវប្បធម៌ផ្សេងៗគ្នា។ ដោយសមត្ថកិច្ចរបស់តុលាការនៅមានកម្រិត ពាណិជ្ជករបានបង្កើតវេទិកាធ្វើមជ្ឈត្តការជាឯកជន ដែលអាចដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ហើយដែលជាញឹកញាប់តែងប្រើប្រាស់អ្នកជំនាញឧស្សាហកម្ម និងបទដ្ឋានឧស្សាហកម្មផងដែរ ។[១៥៩]

នៅពេលដែលនិគមជនអង់គ្លេសផ្លាស់ទីលំនៅទៅទ្វីបអាមេរិកនៅកំឡុងសតវត្សរ៍ទី១៧ និងទី១៨ ពួកគេបាននាំមកជាមួយខ្លួននូវបែបផែនមជ្ឈត្តការទាំងនេះផង។ ជាលទ្ធផល មជ្ឈត្តការបានដើរតួនាទីសំខាន់នៅក្នុងដំណោះស្រាយវិវាទផ្នែកពាណិជ្ជកម្មនៅក្នុងទឹកដីអាណានិគមអង់គ្លេសក្នុងទ្វីបអាមេរិក។[១៦០] ក្នុងឆ្នាំ១៧៦៨ ស្ថាប័នមជ្ឈត្តការអចិន្ត្រៃយ៍ដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយសភាពាណិជ្ជកម្មក្រុងញូវយ៉ក។[១៦១] គេថែមទាំងបានរាយការណ៍ថា ប្រធានាធិបតីទីមួយរបស់អាមេរិក គឺលោក ចច វ៉ាស៊ីងតុន (George Washington) បានបញ្ចូលខចែងស្តីពីមជ្ឈត្តការនៅក្នុងមរតកសាស្ត្ររបស់គាត់ទៀតផង ដើម្បីគ្រប់គ្រងវិវាទក្នុងចំណោមអត្ថគាហកទាំងឡាយ ។[១៦២] ទោះជាយ៉ាងនោះក្តី នៅសម័យនោះ តុលាការនៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាក្នុងបណ្តាប្រទេសមួយចំនួនទៀត មិនអាចអនុវត្តមជ្ឈត្តវិនិច្ឆ័យបានឡើយ ដោយចាប់ពីពេល នោះមក ទើបគេរក្សាការធ្វើមជ្ឈត្តការនេះឱ្យស្ថិតនៅខាងក្រៅប្រព័ន្ធតុលាការជាផ្លូវការ ។

នៅសតវត្សរ៍ទី២០ ដោយហេតុថាសំណុំរឿងក្តីដែលត្រូវធ្វើការដោះស្រាយចាប់ផ្តើមកើនឡើង តុលាការនៃប្រទេសជាច្រើនបានចាប់ផ្តើមទទួលយកមជ្ឈត្តការ ថាជាវិធីសាស្ត្រស្របច្បាប់មួយក្នុងដំណោះស្រាយវិវាទ។ នៅក្នុងសហរដ្ឋអាមេរិក ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធឆ្នាំ១៩២៥ (FAA) បានផ្តល់សុពលភាពដល់ខចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មឱ្យធ្វើការអនុវត្តបាន។[១៦៣] ប្រទេសផ្សេងៗបានអនុវត្តតាមយ៉ាងឆាប់រហ័ស ដែលនាំឱ្យវេទិកាធ្វើមជ្ឈត្តការមានការកើនឡើងយ៉ាងឆាប់រហ័សនៅពាសពេញពិភពលោកទាំងមូល។[១៦៤] ក្នុងឆ្នាំ១៩២៣ សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស (ICC) បានបង្កើតតុលាការមជ្ឈត្តការអន្តរជាតិ ដែលបានក្លាយជាវេទិកាធ្វើមជ្ឈត្តការដែល

---

[១៥៩] *ដូចមុន ។*

[១៦០] ក្រុងបូស្តុនក៏ដូចជាសហគមន៍អាណានិគមអាមេរិកជាច្រើនដែរ បានអនុម័តច្បាប់ដែលលើកទឹកចិត្តឱ្យមានមជ្ឈត្តការ ។ Patterson et al., កំណត់សម្គាល់ *ខាងលើ* លេខ៩, ទំព័រ១១៨។

[១៦១] Bennett, កំណត់សម្គាល់ *ខាងលើ* លេខ១៥៧, ទំព័រទី ៩។

[១៦២] Patterson et al., កំណត់សម្គាល់ *ខាងលើ* លេខ៩, ទំព័រ១១៨។

[១៦៣] ***សូមមើលច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធ*** 9 U.S.C. § 1 – 307 (1970)។

[១៦៤] បច្ចុប្បន្ននេះ សាជីវកម្មអន្តរជាតិជាច្រើននិយមធ្វើមជ្ឈត្តការអន្តរជាតិជាងទម្រង់ទាំងអស់ផ្សេងទៀតនៃការដោះស្រាយវិវាទ ។ *សូមមើល ឧទាហរណ៍* Dr. Loukas Mistelis *មជ្ឈត្តការអន្តរជាតិ-តរិយាបថ និងទម្លាប់អនុវត្តន៍សាជីវកម្ម-ការធ្វើតេស្តលើការដឹងដោយវិញ្ញាណទាំង ១២: របាយការណ៍ស្រាវជ្រាវរឿងព្រេងកថា ទិន្នន័យ និងការវិភាគ,* **ព្រឹត្តបត្រអាមេរិកស្តីពីមជ្ឈត្តការអន្តរជាតិ** ទំព័រទី ៥២៥, ៥៣៨ (ឆ្នាំ២០០៤) ។

ល្បីល្បាញបំផុតមួយនៅក្នុងពិភពលោក។[១៦៥] វេទិកាធ្វើមជ្ឈត្តការសំខាន់ផ្សេងៗទៀត រួមមាន សមាគមមជ្ឈត្តការអាមេរិកទីក្រុងញូវយ៉ក[១៦៦] និងតុលាការមជ្ឈត្តការអន្តរជាតិទីក្រុងឡុងដ៍។[១៦៧] នៅទសវត្សរ៍កន្លងទៅនេះ កំណើនសេដ្ឋកិច្ចនៅអាស៊ី បាននាំឱ្យមានការកើនឡើងដ៏គួរឱ្យកត់សម្គាល់នៃវេទិកាធ្វើមជ្ឈត្តការនៅអាស៊ី។ បច្ចុប្បន្ននេះ វេទិកានៅអាស៊ីដ៏ធំបំផុត ចំនួនបីរួមមាន គណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន (CIETAC)[១៦៨] មជ្ឈមណ្ឌល មជ្ឈត្តការអន្តរជាតិទីក្រុងហុងកុង (HKIAC)[១៦៩] និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី (SIAC)[១៧០]។ ហើយក៏មានវេទិកាធ្វើមជ្ឈត្តការផ្សេងៗទៀតនៅក្នុងប្រទេសជប៉ុន ថៃ វៀតណាម ម៉ាឡេស៊ី តៃវ៉ាន់ ឥណ្ឌា និង ឥណ្ឌូនេស៊ីផងដែរ។ ដូចដែលនឹងពិភាក្សាខាងក្រោមនៅក្នុងជំពូកនេះ ប្រទេសកម្ពុជាបានដាក់បញ្ចូលមជ្ឈមណ្ឌលមជ្ឈត្តការជាតិថ្មី របស់ខ្លួននៅក្នុងបញ្ជីនេះដែរ។[១៧១]

### ២. *មជ្ឈត្តការសម្រាប់ប្រភេទវិវាទជាច្រើន*

ក្នុងខណៈដែលវេទិកាភាគច្រើនខាងលើផ្តោតលើដំណោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ជាសំខាន់ គេត្រូវយល់ថាមជ្ឈត្តការក៏អាចអនុវត្តចំពោះវិស័យផ្សេងទៀតនៃច្បាប់ផងដែរ។ នៅក្នុងប្រទេសជាច្រើន វិវាទការងារក៏ត្រូវបានដោះស្រាយមជ្ឈត្តការដែរ ក្នុងពេលបច្ចុប្បន្ន។ កិច្ចព្រមព្រៀងអនុសញ្ញារួមតែងតែមានខចែងស្តីពីមជ្ឈត្តការដែលទាមទារឱ្យគូភាគីបញ្ជូនវិវាទទៅធ្វើមជ្ឈត្តការ។ កីឡាអាជីពជាច្រើន ប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍។ សូម្បីតែកីឡាអូឡាំពិកក៏បានប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយវិវាទដែរ។[១៧២] កិច្ចសន្យាសាងសង់រវាងអ្នកសាងសង់

---

[១៦៥] *សូមមើល* វែបសាយត៍របស់សភាពាណិជ្ជកម្មអន្តរជាតិ *មាននៅ* http://www.iccwbo.org/policy/arbitration/id2882/index.html (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៦] *សូមមើល* វែបសាយត៍របស់សមាគមមជ្ឈត្តការអាមេរិក *មាននៅ* http://www.adr.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៧] *សូមមើល*វែបសាយត៍របស់តុលាការមជ្ឈត្តការអន្តរជាតិក្រុងឡុងដ៍ *មាននៅ* http://www.lcia-arbitration.com/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៨] *សូមមើល* វែបសាយត៍របស់គណៈកម្មាធិការសេដ្ឋកិច្ចអន្តរជាតិ និងមជ្ឈត្តការផ្នែកពាណិជ្ជកម្មចិន *មាននៅ* http://www.cietac.org.cn/index_english.asp (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៩] *សូមមើល* វែបសាយត៍របស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិក្រុងហុងកុង *មាននៅ* http://www.hkiac.org/HKIAC/HKIAC_English/main.html (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៧០] *សូមមើល*វែបសាយត៍របស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិក្រុងសិង្ហបុរី *មាននៅ* http://www.siac.org.sg/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៧១] *សូមមើល* ជំពូកទី ៤ (ង) ក្នុងផ្នែកនេះ *ខាងក្រោម*។

[១៧២] *សូមមើល* វែបសាយត៍របស់ Tribunal Arbitral du Sport (តុលាការមជ្ឈត្តការសម្រាប់វិស័យកីឡា) *មាននៅ* http://www.tas-cas.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

**៣) តើវិធានអ្វីនឹងគ្រប់គ្រងដំណើរការនេះ?**

វិធាននីតិវិធីគឺស្ថិតនៅលើគូភាគីជាអ្នកជ្រើសរើសទាំងស្រុង។ គូភាគីអាចតាក់តែងវិធានផ្ទាល់របស់ខ្លួន ប៉ុន្តែករណីបែបនេះមិនសូវមានឡើយ ដោយសារតែកម្រិតនៃការខិតខំប្រឹងប្រែងដែលកិច្ចការនេះតម្រូវ និងដោយសារតែមជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើន បានបង្កើតនីតិវិធីជាច្រើនសម្រាប់ឱ្យជ្រើសរើស។ មជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើនក៏នឹងអនុញ្ញាតឱ្យគូភាគីប្រើប្រាស់វិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការផ្សេងដែរ។ ឧទាហរណ៍ សមាគមមជ្ឈត្តការអាមេរិកនឹងអនុញ្ញាតឱ្យគូភាគីជ្រើសរើសយកសមាគមមជ្ឈត្តការអាមេរិកធ្វើជាអ្នកគ្រប់គ្រងប៉ុន្តែប្រើវិធានមជ្ឈត្តការតម្រូវរបស់ UNCITRAL បាន។ គូភាគីក៏អាចកែប្រែនីតិវិធីទាំងនេះខ្លះដើម្បីឱ្យត្រូវគ្នានឹងតម្រូវការពិសេសរបស់ខ្លួន : ឧទាហរណ៍ តម្រូវការនៃល្បឿនដំណើរជាដើម។

**វិធាននីតិវិធីដែលគ្រប់គ្រង**

*រាល់ការមិនចុះសម្រុងគ្នា ឬការទាមទារដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬរាល់ការរំលោភលើកិច្ចសន្យានេះ នឹងត្រូវដោះស្រាយដោយមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិកស្របតាមវិធានមជ្ឈត្តការឧស្សាហកម្មសំណង់របស់សមាគម ហើយសាលក្រមអំពីមជ្ឈត្តវិនិច្ឆ័យដែល ចេញដោយមជ្ឈត្តករអាចធ្វើបាននៅក្នុងតុលាការដែលមានយុត្តាធិការក្នុងការងារនេះ។*

**ង) តើភាសាអ្វីនឹងត្រូវប្រើនៅក្នុងដំណើរការមជ្ឈត្តការនេះ?**

នៅក្នុងកិច្ចសន្យាដែលមានការចូលរួមពីគូភាគីអន្តរជាតិ ការបញ្ចូលបញ្ញត្តិដែលចែងអំពីភាសាដែលនឹងត្រូវប្រើនៅក្នុងដំណើរការមជ្ឈត្តការ ពិតជាមានសារប្រយោជន៍ណាស់។

**ការជ្រើសរើសភាសា**

*មជ្ឈត្តការត្រូវធ្វើឡើងជាភាសាខ្មែរ។ ដោយមានសម្ពៃ និងចំណាយថវិការបស់ភាគីម្ខាង ឯកសារនិងសក្ខីកម្មនានាអាចបកប្រែទៅភាសាអង់គ្លេស ឬពីភាសាអង់គ្លេសមកវិញ។*

**ឋ) តើច្បាប់ណាដែលនឹងគ្រប់គ្រងដំណើរការនេះ?**

គូភាគីត្រូវកំណត់អំពីច្បាប់ចម្បងដែលនឹងគ្រប់គ្រងដំណើរការនេះ។ គេហៅការកំណត់នេះថា "បញ្ញត្តិស្តីពីជម្រើសនៃច្បាប់"។ វាជាការសំខាន់ដែលគូភាគីត្រូវដឹងអំពីប្រការនេះនៅគ្រប់ពេលដែលចុះកិច្ចសន្យា។ បើមិនដូច្នោះទេ ប្រសិនបើមានវិវាទកើតឡើង បទបញ្ញត្តិរបស់តុលាការ ឬស្ថាប័នមជ្ឈត្តការ ដែលស្តីពីទំនាស់នៃបញ្ញត្តិនឹងត្រូវប្រើដើម្បីកំណត់ថាតើច្បាប់ណាមួយដែលនឹងយកមកអនុវត្ត។ ការធ្វើដូច្នេះបង្កើតនូវភាពមិនច្បាស់លាស់សម្រាប់គូភាគី។ ជាលទ្ធផល បញ្ញត្តិស្តីពីជម្រើសនៃច្បាប់ តែងតែត្រូវបានបញ្ចូលនៅក្នុងកិច្ចសន្យាអន្តរជាតិស្ទើរតែទាំងអស់។

បន្តិចបន្តួច ។ ជាលទ្ធផល បច្ចុប្បន្ននេះ វិធានមជ្ឈត្តការរបស់ប្រទេសកម្ពុជា មានភាពស៊ីសង្វាក់គ្នាជាមួយប្រទេសប្រហែល ៥០ប្រទេស រួមមាន ដៃគូពាណិជ្ជកម្ម សំខាន់ៗដូចជា ប្រទេសជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ថៃ និងអូស្ត្រាលីជាដើម ។[១៨៦]

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃបញ្ហាមជ្ឈត្តការ រួមមានៈ កិច្ចព្រមព្រៀង ផ្សះផ្សា សមាសភាព និងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ការដឹកនាំដំណើរការ ការទទួលស្គាល់ និងការអនុវត្ត មជ្ឈត្តវិនិច្ឆ័យ និងផ្នែកមួយដែលមានចំណងជើងថា "មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម"។ ច្បាប់នេះគ្រប់-គ្រងតែលើវិវាទពាណិជ្ជកម្មប៉ុណ្ណោះ ប៉ុន្តែនិយមន័យរបស់វាត្រូវបានអនុញ្ញាតឱ្យធ្វើបកស្រាយយ៉ាងទូលំទូលាយដូចគ្នា នឹងនិយមន័យដែលមានចែងនៅក្នុងច្បាប់គម្រូ UNCITRAL ដែរ ។[១៨៧]

| |
|---|
| ***ដោយសារតែនិយមន័យដ៏ទូលំទូលាយនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងទំនងជាគ្របដណ្តប់លើសវនាការមជ្ឈត្តការនាពេលអនាគត ភាគច្រើននៅក្នុងប្រទេសកម្ពុជា ។[១៨៨]*** |

---

វែបសាយត៍របស់ UNCITRAL *មាននៅ*
http://www.uncitral.org/uncitral/en/uncitral_texts/arbitration/1985Model_arbitration.html
(ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[១៨៦] រដ្ឋដែលបានអនុម័តច្បាប់គម្រូនេះ រួមមាន : អូស្ត្រាលី អូទ្រីស (ឆ្នាំ២០០៥) អាហ្សែបៃហ្សង់ បារ៉ែន បង់ក្លាដែស បេឡារូស ប៊ុលហ្គារី កម្ពុជា (ឆ្នាំ២០០៦) កាណាដា ឈីលី ក្នុងប្រទេសចិនមានៈ តំបន់រដ្ឋបាលពិសេសហុងកុង តំបន់រដ្ឋបាលពិសេសម៉ាកាវ ក្រូអាត ហ្ស៊ីព្រ ដាណឺម៉ាក (ឆ្នាំ២០០៥) អេហ្ស៊ីព អាល្លឺម៉ង់ ក្រិច ហ្គោតាម៉ាឡា ហុងគ្រី ឥណ្ឌា (សាធារណរដ្ឋអ៊ីស្លាម) អ៊ីរ៉ង់ អៀរឡង់ ជប៉ុន ហ្សកដានី កែនយ៉ា លីទុយអានី ម៉ាដាហ្គាស្កា ម៉ាល់តា ម៉ិចស៊ិក ញូវហ្សេឡែន នីការ៉ាហ្គ័រ (ឆ្នាំ២០០៥) នីហ្សេរីយ៉ា ន័រវេស (ឆ្នាំ២០០៤) អូម៉ែន ប៉ារ៉ាហ្គាយ ប៉េរូ ហ្វីលីពីន ប៉ូឡូញ (ឆ្នាំ២០០៥) សាធារណរដ្ឋកូរ៉េ សហព័ន្ធរុស្ស៊ី សិង្ហបុរី អេស្ប៉ាញ ស្រីលង្ការ ថៃ ទុយនេស៊ី ទួរគី (ឆ្នាំ២០០១) អ៊ុយក្រែន នៅក្នុងចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង : ស្កត់ឡែន នៅក្នុង បែរមុយដា ដែនដីនាយសមុទ្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង នៅក្នុងសហរដ្ឋអាមេរិក : កាលីហ្វរនីញ៉ា ខនិកធីខាត់ អ៊ីលីន័រ លូស៊ីយ៉ាណា អូរីហ្គុង និងតិចសាស់ ប្រទេសហ្សំប៊ី និងហ្ស៊ីមបាវេ ។ វែបសាយត៍ UNCITRAL *មាននៅ*
http://www.uncitral.org/uncitral/en/uncitral_texts/arbitration/1985Model_arbitration_status.html
(ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[១៨៧] មាត្រា ២(ឈ) នៃច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចែងថា "ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចនានាដែលកើតចេញ ពីទំនាក់ទំនងទាំងអស់ដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមាន ឬគ្មាន កិច្ចសន្យាក៏ដោយ ហើយទំនាក់ទំនងដែលមានប្រភេទជាពាណិជ្ជកម្មរួមមាន តែមិនកម្រិតត្រឹម ជំនួញដូចខាងក្រោម : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬផ្លាស់ប្តូរទំនិញ [sic] ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការផលិត ការជួលទីតាំង ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចម្រុះ និងប្រភេទផ្សេងៗទៀត នៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូន ទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស សមុទ្រ ផ្លូវដែក ឬផ្លូវគោក" ។ ច.ម.ព កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ២(ឈ)

[១៨៨] ប្រហែលជាមានករណីលើកលែងចំពោះក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា ។

ដូចនេះ ផ្នែកនេះនឹងផ្តោតលើដំណើរការមជ្ឈត្តការដែលចែងនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ជាការសំខាន់គួរកត់សម្គាល់ថា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មគឺជាច្បាប់មជ្ឈត្តការ ដែលចែងអំពីបទដ្ឋានមជ្ឈត្តការ។ ភាគីវិវាទអាចធ្វើបង្វែរចេញពីបទដ្ឋាននេះបាន ជាពិសេសទាក់ទងនឹងវិធានមជ្ឈត្តការនានា។ ឧទាហរណ៍ ប្រសិនបើគូភាគីជ្រើសរើសយកស្ថាប័ន AAA ឬ ICC ធ្វើជាអ្នកគ្រប់គ្រងមជ្ឈត្តការរបស់ខ្លួន ពួកគេមុខជានឹងជ្រើសរើសយកវិធានមជ្ឈត្តការរបស់ AAA ឬ ICC ដែរ។ វិធានទាំងនេះមានភាពខុសគ្នាបន្តិចបន្តួចពីវិធាននៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប៉ុន្តែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអនុញ្ញាតឱ្យគូភាគីធ្វើដូច្នោះបាន។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មយកលំនាំតាមច្បាប់គម្រូ UNCITRAL ក្នុងការដាក់កំហិតអន្តរាគមន៍របស់តុលាការនៅក្នុងដំណើរការនានានៃមជ្ឈត្តការ។[១៨៩] ប៉ុន្តែមានការភ័ន្តច្រឡំគ្នាមួយចំនួនទាក់ទងនឹងតួនាទីគ្រប់គ្រងរបស់តុលាការ។ មាត្រា៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបញ្ជាក់ថាមុខងារត្រួតពិនិត្យជាច្រើន (ដូចជាការតែងតាំង ការជំទាស់ ការបញ្ចប់ ការខកខានក្នុងការបំពេញមុងារ របស់មជ្ឈត្តករ ក៏ដូចជាយុត្តាធិការរបស់តុលាការ) ត្រូវ "អនុវត្តដោយតុលាការ (តុលាការពាណិជ្ជកម្ម សាលាឧទ្ធរណ៍ ឬតុលាការកំពូល) ឬមជ្ឈមណ្ឌលមជ្ឈត្តការជាតិ។"[១៩០] ខ្លឹមសារត្រង់ចំណុចនេះគេអាចបកស្រាយថាមានការចង្អុរបង្ហាញដល់ភាគីថា ខ្លួនអាចប្តឹងឧបាស្រ័យដោយផ្ទាល់ទៅស្ថាប័ន*ណាមួយ*ក្នុងចំណោមស្ថាប័នទាំងបួននេះ ដើម្បីស្នើសុំជំនួយផ្នែកគ្រប់គ្រងនានា។[១៩១] ខ្លឹមសារត្រង់ចំណុចនេះក៏បានចង្អុលបង្ហាញផងដែរថា មានតែជម្រើសពីរយ៉ាងតែប៉ុណ្ណោះក្នុងការប្តឹងឧបាស្រ័យៈ ទី១គឺ"តុលាការ" ដែលសំដៅទៅលើប្រព័ន្ធតុលាការជាទូទៅ ឬ ទី២គឺមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ។ ដោយសារខ្លឹមសារ ត្រង់ចំណុចនេះនៅមានភាពស្រពិចស្រពិល ការភ័ន្តច្រឡំអាចកើតមាន ហើយការអនុវត្តអាចមានភាពមិនស៊ីសង្វាក់គ្នាខ្លះៗ។ ផ្អែកលើស្ថានភាពបច្ចុប្បន្ននេះ ប្រការដែលល្អបំផុត ក្នុងការស្វែងរកជំនួយត្រួតពិនិត្យពីតុលាការ គឺដាក់ញត្តិទៅសាលាឧទ្ធរណ៍[១៩២]។ ចំណុចនេះគួរត្រូវបានលើកមកពិនិត្យ នៅពេលកែតម្រូវឡើងវិញនាពេលអនាគតចំពោះច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ។

### ១. *ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ*

មជ្ឈត្តការអាចផ្តួចផ្តើមឡើងតាមវិធីបីយ៉ាងគឺៈ ១) ការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដែលមានស្រាប់ ២) ការព្រមព្រៀងឱ្យធ្វើមជ្ឈត្តការនៅពេលវិវាទកើតឡើង និង៣) មជ្ឈត្តការ ដែលត្រូវអនុវត្តតាមបង្គាប់របស់តុលាការ។ វិធីទីមួយក្នុងចំណោមវិធីទាំងបី ពោលគឺការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងមជ្ឈត្តការដែលមានស្រាប់ ត្រូវបានអនុវត្តជាទូទៅបំផុត។

---

[១៨៩] *ដូចមុន* មាត្រា ៥ ។

[១៩០] *ដូចមុន* មាត្រា ៦, ១៩(៣), ១៩(៤), ១៩(៥), ២១(៣), ២២ និង ២៤(៣)។

[១៩១] តុលាការពាណិជ្ជកម្មដែលនិយាយនៅទីនេះ មិនទាន់បង្កើតឡើងនៅឡើយទេ ។

[១៩២] សាលាឧទ្ធរណ៍គឺជាតុលាការជាតិជាន់ទាបបំផុតដែលកំពុងដំណើរការ ដែលមានរៀបរាប់នៅក្នុងមាត្រា ៦ ។

### មជ្ឈត្តការសន្ទាន

*ប្រសិនបើមានវិវាទមួយកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬមានការរំលោភនឹងកិច្ចសន្យានេះ ហើយប្រសិនបើវិវាទមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាដោយផ្ទាល់ទេ គូភាគីយល់ព្រម ព្យាយាមដោះស្រាយវិវាទនោះជាដំបូងដោយសន្ទានកម្ម ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការ អាមេរិក ស្របតាមនីតិវិធីសន្ទានកម្មផ្នែកពាណិជ្ជកម្ម មុនពេលឈានទៅដល់ការធ្វើមជ្ឈត្តការ។ រាល់ការមិនចុះសម្រុងគ្នា ឬការទាមទារដែលមិនអាចដោះស្រាយបានដែលកើតចេញពី ឬទាក់ទង នឹងកិច្ចសន្យានេះ ឬការរំលោភកិច្ចសន្យានេះ ត្រូវដោះស្រាយដោយមជ្ឈត្តការដែលគ្រប់គ្រងដោយ សមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការពាណិជ្ជកម្ម ហើយសាលក្រមស្ដីពីមជ្ឈត្តវិនិច្ឆ័យ ដែលចេញដោយមជ្ឈត្តករ អាចធ្វើឡើងនៅក្នុងតុលាការដែលមានយុត្តាធិការក្នុងការងារនេះ។ ប្រសិនបើគូភាគីទាំងអស់នៃវិវាទយល់ព្រម សន្ទានការីដែលបានដឹកនាំធ្វើសន្ទានកម្មលើវិវាទនោះ អាចធ្វើជាមជ្ឈត្តករបាន។*

### ច) តើវេទិកាមជ្ឈត្តកម្មនឹងមានអំណាចក្នុងការចេញវិធានការបណ្ដោះអាសន្នដែរឬទេ?

ពេលខ្លះ គូភាគីនឹងចង់ឱ្យវេទិកាមជ្ឈត្តកម្មចេញវិធានការបណ្ដោះអាសន្នឬវិធានការបឋមមុនពេល កាត់សេចក្ដីលើវិវាទទាំងមូល។ ឧទាហរណ៍ ភាគីម្ខាងចង់ឱ្យភាគីម្ខាងទៀតឈប់បោះពុម្ពឯកសារមិនពិត ឬដែលនាំឱ្យមានការភ័ន្តច្រឡំ។ នៅក្នុងឧទាហរណ៍នេះ ប្រសិនបើគូភាគីត្រូវរង់ចាំរយៈពេលប្រាំមួយខែ ដើម្បីកាត់សេចក្ដីលើវិវាទទាំងស្រុង នោះវាអាចនឹងមានការយឺតយ៉ាវជ្រុល។ ដូច្នេះ ដើម្បីទប់ស្កាត់ការខូចខាតដែលនឹងមានជាបន្ត វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីនោះឈប់បោះពុម្ពឯកសារទាំងនោះភ្លាមៗ (ពេលខ្លះគេហៅថា "សេចក្ដីបង្គាប់") រហូតដល់វេទិកាមជ្ឈត្តកម្មអាចធ្វើការសម្រេចលើអង្គហេតុទាំងស្រុង។

### វិធានការបណ្ដោះអាសន្ន

*ភាគីនីមួយៗអាចដាក់ពាក្យស្នើសុំទៅមជ្ឈត្តករ ដើម្បីស្វែងរកការចេញសេចក្ដីបង្គាប់ រហូតមជ្ឈត្តវិនិច្ឆ័យត្រូវបានសម្រេចឡើង ឬការមិនចុះសម្រុងគ្នាត្រូវបានដោះស្រាយ។ ដោយមិនបោះបង់ ចោលនូវវិធីដោះស្រាយតាមរយៈកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗក៏អាចស្នើសុំការលើកលែងលើលក្ខខណ្ឌតាមកិច្ចព្រមព្រៀងនេះ ឬស្វែងរកការចេញដីកាបន្ទាន់ ឬដីកាបណ្ដោះអាសន្នពីតុលាការណាដែលមានយុត្តាធិការ ដែលមានភាពចាំបាច់ ដើម្បីការពារសិទ្ធិ ឬទ្រព្យសម្បត្តិរបស់ភាគីនោះ ក្នុងខណៈពេលរង់ចាំបង្កើតវេទិកាមជ្ឈត្តកម្ម (ឬខណៈពេលរង់ចាំការសម្រេចសេចក្ដី លើការមិនចុះសម្រុងគ្នានោះដែលនឹងត្រូវធ្វើឡើងដោយវេទិកាមជ្ឈត្តកម្ម)។*

**ក) ការដាក់ពាក្យរបស់ភាគីប្តឹង**

ប្រសិនបើគូភាគីមានកិច្ចព្រមព្រៀងមជ្ឈត្តការជាមុនស្រាប់ ដែលជាទូទៅគឺជាផ្នែកមួយនៃកិច្ចសន្យាដើម ភាគីម្ខាងត្រូវបង្ហាញដល់ភាគីម្ខាងទៀតនូវសម្មើជាលាយលក្ខណ៍អក្សរ (ពេលខ្លះហៅថា "លិខិតជូនដំណឹង") ដើម្បីធ្វើមជ្ឈត្តការ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សម្មើជាលាយលក្ខណ៍អក្សរនោះត្រូវប្រគល់ដល់ភាគីម្ខាងទៀតដោយផ្ទាល់ ឬទៅដល់កន្លែងអាជីវកម្ម លំនៅស្ថានអចិន្ត្រៃយ៍ ឬអាសយដ្ឋានប្រៃសណីយ៍របស់គាត់។[១៩៣] ភាគីដែលផ្តួចផ្តើមធ្វើមជ្ឈត្តការ គេហៅថា"ភាគីប្តឹង" ហើយភាគីដែលទទួលសម្មើ គេហៅថា "ភាគីឆ្លើយតប"។ ដំណើរការមជ្ឈត្តកម្មចាប់ផ្តើមនៅកាលបរិច្ឆេទដែលភាគីឆ្លើយតបបានទទួលសម្មើ ។[១៩៤]

ប្រសិនបើគូភាគីបានជ្រើសរើសយកវិធានមជ្ឈត្តការរបស់ UNCITRAL[១៩៥] (ដែលត្រូវបានធ្វើការបោះពុម្ពឡើងវិញ និងភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ គ) ឬវិធានមជ្ឈត្តការអន្តរជាតិរបស់សមាគមមជ្ឈត្តការអន្តរជាតិ[១៩៦] ឬវិធានមជ្ឈត្តការរបស់ ICC[១៩៧] នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួន នោះសម្មើ ឬ លិខិតជូនដំណឹងរបស់ពួកគេត្រូវចែងអំពីចំណុចដូចជា:

- ឈ្មោះ និង ព័ត៌មានលម្អិតរបស់គូភាគី
- សេចក្តីបរិយាយអំពីវិវាទ
- សេចក្តីបញ្ជាក់អំពីការស្វែងរកជំនួយ និង
- កិច្ចព្រមព្រៀងពាក់ព័ន្ធទាំងអស់ រួមទាំងកិច្ចព្រមព្រៀងមជ្ឈត្តការ ។[១៩៨]

ប្រសិនបើគូភាគីបានជ្រើសរើសមជ្ឈមណ្ឌលមជ្ឈត្តការជាតិ ("NAC") ពួកគេនឹងត្រូវគោរពតាមវិធានមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការជាតិនោះ ដែលមិនទាន់ត្រូវបានអនុម័តនៅឡើយ នៅពេលដែលសៀវភៅនេះត្រូវបានរៀប

---

[១៩៣] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ៣។

[១៩៤] *ដូចមុន* មាត្រា ២៩។

[១៩៥] **វិធានមជ្ឈត្តការ** UNCITRAL មាត្រា ៣ *មាននៅ* http://1.1.1.1/468278784/468291592T080320091030.txt.binXMysM0dapplication/pdfXsysM0dhttp://www.uncitral.org/pdf/english/texts/arbitration/arb-rules/arb-rules.pdf (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការ UNCITRAL"]។

[១៩៦] សមាគមមជ្ឈត្តការអាមេរិក, **វិធានមជ្ឈត្តការអន្តរជាតិ,** មាត្រា ៣ *មាននៅ* http://www.adr.org/sp.asp?id=33994#INTERNATIONAL%20ARBITRATION%20RULES (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការAAA"]។

[១៩៧] **វិធានមជ្ឈត្តការ** ICC មាត្រា ៤ (*មាននៅ* http://www.iccwbo.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការ ICC"]។

[១៩៨] វិធានទាំងបីបទនេះ ក៏រួមបញ្ចូលនូវ ចំនួន និងជម្រើសមជ្ឈត្តករនៅក្នុងពាក្យរបស់ភាគីប្តឹង ។វិធានមជ្ឈត្តការ AAA មាត្រា ២(៣)(ង) វិធានមជ្ឈត្តការ UNCITRAL មាត្រា ៤(៣)(ង) និងវិធានមជ្ឈត្តការICC មាត្រា ៣(៣)(ង) និងមាត្រា ៤ (ក)-(ខ)។

**ឧបសម្ព័ន្ធ៨**

ការចរចាផ្តល់លទ្ធភាពអោយគូភាគីអាចគ្រប់គ្រងយ៉ាងពេញលេញ ទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើភាគីវិវាទត្រូវធ្វើការចរចារបៀបណា និងថាតើនឹងមានការស្រុះស្រួលឬទេ។ នៅក្នុងការចរចាគេមិនអាចបង្ខំភាគីណាមួយអោយចូលក្នុងដំណើរការ ឬការស្រុះស្រួលណាមួយដោយគ្មានការព្រមព្រៀងពីភាគីណាមួយ។

-រក្សាទំនាក់ទំនង

ការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ អនុញ្ញាតអោយភាគីរៀបចំដំណោះស្រាយមួយដែលអាចរក្សាសម្ព័ន្ធភាពរបស់ពួកគេជាបន្តទៅទៀត។ ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានភាពបដិបក្ខតិចជាងដំណើរការបណ្តឹងនៅតុលាការ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន។

២. គុណវិបត្តិ

-សេចក្តីសំរេច

សេចក្តីសំរេចនៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ មានលក្ខណៈមិនសូវជាផ្លូវការ ហើយមិនមានលក្ខណៈចាប់បង្ខំអោយគូភាគីត្រូវតែគោរពតាមនោះទេ លើកលែងតែមជ្ឈត្តវិនិច្ឆ័យដែលមានលក្ខណៈចាប់បង្ខំ។

-ភាពឯកជន

ដោយសារតែការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការមានលក្ខណៈឯកជនហួសហេតុពេក អាចបណ្តាលអោយភាគីម្ខាងទទួលរងនូវការគំរាមគំហែង ពីភាគីម្ខាងទៀតដែលមានអំណាចធំជាង ដោយសារតែវាមិនតំរូវអោយមានការបើកសវនាការជាសាធារណៈដូចការដោះស្រាយតាមផ្លូវតុលាការ។

-ពេលវេលា